ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត




- ការដោះស្រាយបញ្ហាពីអតីតកាល បោះជំហានឆ្ពោះទៅអនាគត
- ខ្ញុំបាត់បង់ប្តី និង កូនពីរនាក់

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៦០ ខែមេសា ឆ្នាំ២០១៣

# ស្វែងរកការពិត

## ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ១៦០ ខែមេសា ឆ្នាំ២០១៣

## មាតិកា

◆ការដោះស្រាយបញ្ហាពីអតីតកាល ..... ១
◆ការដាក់ទោសទណ្ឌ និងការទប់ស្កាត់ ..... ៩

### ផ្នែកឯកសារ

◆បញ្ជីឈ្មោះ និងរូបថតអ្នកទោសមន្ទីរស-២១ ..... ១០
◆អ្នកនិពន្ធ គ្រឹង ផា ..... ១៤
◆យុវជន យុវនារីបដិវត្តន៍ប្ដេជ្ញា ..... ១៧

### ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ

◆ជនជាតិភាគតិចក្រោល ..... ២១
◆ទួលតក់ស្លុត ..... ២៧
◆កុមារធ្វើការជូនបដិវត្តន៍ ..... ២៩
◆រឿងរ៉ាវដែលខ្ញុំនៅចាំ ..... ៣២

### ផ្នែកច្បាប់

◆កម្មវិធីវិទ្យុសហគមន៍ ៖ ការអត់ឃ្លាន ..... ៣៦

### វេទិកាពិភាក្សាសាធារណៈ

◆ដើមបណ្ដឹងរដ្ឋប្បវេណីចន្លុលឲ្យឃើញ ..... ៤២
◆ចៅក្រមអង្គបុរេជំនុំជម្រះជាតិ និង ..... ៤៥

### ទំព័រស្រាវជ្រាវរកគ្រួសារ

◆ ខ្ញុំបាត់បង់ប្ដី និងកូនពីរនាក់ ..... ៤៨
◆ ជីវិតខ្ញុំពីដើមរៀងមក ..... ៥៦



ជនជាតិកាវ៉ែត នៅភូមិទាកទាម ឃុំសន្តិភាព ស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង ចូលរួមវេទិកាអប់រំសាធារណៈ ស្ដីពីការអប់រំប្រវត្តិសាស្ត្រខ្មែរក្រហម ។

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហាឆ្នាំ១៩៩៩

រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

***ស្នេរលេខនេះ ៖*** អាន ហាញឌុល, លឹម គីមឡេង, លី សុខឃាង, សុខ យ៉ាវ **អ្នកនិពន្ធនិងស្រាវជ្រាវ ៖** ទាវ សារៈមុនិន្ទ, ស៊ិន សុធីតា **អ្នកបកប្រែ ៖** នង ច័ន្ទមល្លិកា និង ភួង ច័ន្ទប្រណិត **និពន្ធនាយកទូទៅ ៖** ឆាំង យុ និង ញាណ សុជាតិ **ជំនួយការនិពន្ធនាយក ៖** សោម ប៊ុនថន **ក្រាហ្វិកកុំព្យូទ័រ ៖** សោម ប៊ុនថន **គ្រប់គ្រងការចែកផ្សាយ ៖** ឆេង វើង Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# ការដោះស្រាយបញ្ហាពីអតីតកាល បោះជំហានឆ្ពោះទៅអនាគត

អាចជាការលំបាកក្នុងការនិយាយឲ្យច្បាស់នូវពាក្យថា "Never Again" ឬជាភាសាខ្មែរថា "មិនកើតឡើងសាជាថ្មីម្តងទៀត" ។ ដោយមានជម្លោះប្រដាប់អាវុធផ្ទៃក្នុងដែលកំពុងបំផ្លិចបំផ្លាញប្រទេសស៊ីរី អស្ថិរភាព និងអំពើហិង្សា ដែលកំពុងញាំញីប្រទេសនៅក្នុងតំបន់អាហ្វ្រិកខាងជើង និងភាពអាចកើតមានឡើងនូវអំពើឧក្រិដ្ឋកម្មធ្ងន់ធ្ងរនៅភាគខាងកើតសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ ពាក្យថា "Never Again" ហាក់ដូចជាស្ថិតក្នុងភាពមន្ទិលសង្ស័យ ។ ការរិះគន់យ៉ាងខ្លាំងអំពីឆន្ទៈរបស់រដ្ឋាភិបាលជាតិ និងសហគមន៍អន្តរជាតិក្នុងការការពារសិទ្ធិមនុស្សជាមូលដ្ឋានកើតឡើងនៅក្នុងប្រទេសកម្ពុជា ។ ក្នុងនាមជាប្រទេសក្រោយអាណានិគម និងជាប្រទេសក្រោយសង្គ្រាម កម្ពុជាស្ថិតនៅចំណុចផ្លូវបំបែកនៃអន្តរាគមន៍ពីបរទេស មនោគមវិជ្ជាជ្រុលនិយម និងរបបផ្តាច់ការដែលបានធ្វើឲ្យអស់ទំនុកចិត្តលើរដ្ឋអំណាច និងការអស់ជំនឿលើអំពើល្អរបស់មនុស្ស ។ ក្នុងន័យនេះ ប្រទេសកម្ពុជាគឺជាមេរៀនដ៏មានឥទ្ធិពលមួយក្នុងប្រវត្តិសាស្ត្រ ។

ប្រទេសនីមួយៗត្រូវតែដោះស្រាយជាមួយនឹងអតីតកាលរបស់ខ្លួន ប្រសិនបើខ្លួនចង់បោះជំហានទៅមុខ ។ វាជាការពុះពារមួយដែលសង្គមងើបចេញពីជម្លោះ បានប្រឈមមុខនឹងបញ្ហានយោបាយ វប្បធម៌ និងស្ថានភាពផ្សេងៗ ។ ជាការពិត ដើម្បីបោះជំហានទៅមុខ យើងត្រូវតែស្រាវជ្រាវពីអតីតកាលឲ្យបានច្បាស់ដោយរំឭកដល់ស្នាដៃរបស់មនុស្សជាតិ ការលះបង់ និងភាពមិនងាយទ្រុឌទ្រោម ថែមទាំងអង្កេត និងរៀនសូត្រពីកំហុស ការបរាជ័យ និងអំពើអាក្រក់របស់មនុស្សជាតិ ។ ការអបអរសាទរចំពោះភាពអស្ចារ្យរបស់សង្គម ពិតជាងាយស្រួល ជាពិសេសនៅពេលដែលភាពអស្ចារ្យនោះផ្សារភ្ជាប់ដោយផ្ទាល់ទៅនឹងភាពស្របច្បាប់របស់អ្នកគ្រប់គ្រងប្រទេស ប៉ុន្តែប្រទេសដែលខ្វះសេចក្តី



ដូនជី ស៊ុម រី នៅវត្តខ្សាច់សរ ខេត្តកំពង់ឆ្នាំង នាំលោក ឆាំង យុ និងគណៈប្រតិភូមកពីសារមន្ទីរហូឡូខសត៍ សហរដ្ឋអាមេរិកមើលទីតាំងសម្លាប់មនុស្សរបស់ខ្មែរក្រហមក្នុងបរិវេណវត្ត កាលពីខែវិច្ឆិកា ឆ្នាំ២០១២ ។ រូបពាក់មួកនៅខាងស្តាំគឺ លោក ម៉ៃឃើល ឈើតូហ្វ អតីតរដ្ឋមន្ត្រីសន្តិសុខមាតុភូមិសហរដ្ឋអាមេរិក ២០០៥-២០០៩

ក្លាហានក្នុងការរៀនសូត្រពីអតីតកាលរបស់ខ្លួន និងមិនមានចិត្តរឹងប៉ឹងដើម្បីប្រឈមនឹងបច្ចុប្បន្នកាល និងអនាគតកាលឡើយ ។

នៅចន្លោះពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ប្រទេសកម្ពុជាត្រូវបានគ្រប់គ្រងដោយរបបប្រល័យពូជសាសន៍ដ៏គួរឲ្យភ័យខ្លាចដែលជារបបកម្ពុជាប្រជាធិបតេយ្យដឹកនាំដោយខ្មែរក្រហម ។ ខ្មែរក្រហមបានប្រើប្រាស់ភាសាពូជសាសន៍និយម ការស្អប់ខ្ពើមជនបរទេស និងការគាបសង្កត់របស់ជនផ្តាច់ការក្នុងការធ្វើឲ្យអំពើឃោរឃៅដ៏គួរឲ្យភ័យខ្លាចមួយចំនួននៅក្នុងប្រវត្តិសាស្ត្ររបស់មនុស្ស មានលក្ខណៈស្របច្បាប់ ។ អ្នកទីក្រុង បញ្ញវ័ន្ត និងអ្នកមានទ្រព្យសម្បត្តិ ត្រូវបានចាត់ទុកថាជាសត្រូវរបស់របបនេះ ។ ជនជាតិវៀតណាម ចាមម៉ូស្លីម និងមនុស្សដទៃ ត្រូវបានចាត់ទុកថាជាជនសង្ស័យ ។ ក្នុងនាមជាសត្រូវរបស់របបនេះតាមការសង្ស័យ ក្រុមសង្គម វប្បធម៌ និងសាសនាផ្សេងៗ ត្រូវបានប្រមូលចូលជំរំលត់ដំការងារធ្ងន់ធ្ងរ ជាទីដែលអ្នកទាំងនោះត្រូវបង្អត់អាហារ ធ្វើបាប និងសម្លាប់ជាច្រើនករណី ។

ក្នុងអំឡុងពេលជាង៤៤ខែ ប្រជាជនជិត២លាននាក់ ត្រូវបានជឿថាបានស្លាប់ក្រោមរបបនោះ ។ ការធ្វើការដោយបង្ខំ ការបង្អត់អាហារ និងការសម្លាប់គឺជាទិដ្ឋភាពតិចតួចនៃជីវិតក្រោមរបបខ្មែរក្រហម ។ ខ្មែរក្រហមបានប្រែក្លាយប្រទេសឲ្យទៅជាជំរំលត់ដំពលកម្មជុំវិញប្រទេសក្រោមទម្រង់កុម្មុយនិស្តដ៏ខ្លាំងក្លា ។ នៅពេលដែលស្ទើរតែមនុស្សគ្រប់គ្នាបានស្លាប់ក្រោមកណ្តាប់ដៃពិឃាត ការអត់ឃ្លាន ជំងឺ និងការបាក់កម្លាំង បានបណ្តាលឲ្យមានការស្លាប់ដូចគ្នា ។

ដូចដែលយើងរំពឹងទុក ការប៉ះទង្គិចផ្លូវចិត្តធ្ងន់ធ្ងរ នៅតែកើតមានឡើងចំពោះអ្នកដែលរស់រានមានជីវិតក្នុងសម័យនេះ ។ នាពេលបច្ចុប្បន្ន មានប្រជាជនកម្ពុជាដែលនៅតែមិនដឹងថាតើអ្វីបានកើតឡើងចំពោះសមាជិកគ្រួសារ ឬប្តីប្រពន្ធរបស់ខ្លួន ។ អ្នកជាទីស្រលាញ់បានបាត់បង់ជីវិត ហើយការឈឺចាប់បន្តកើតឡើងដោយសារក្មេងជំនាន់ក្រោយសួរឪពុកម្តាយរបស់ខ្លួនថាតើរឿងហេតុអ្វីបានកើតឡើង និងមូលហេតុនៃរឿងហេតុទាំងនោះ ។ លើសពីនេះ លទ្ធិប្រជាធិបតេយ្យរបស់ប្រទេសកម្ពុជាមានលក្ខណៈក្មេងខ្ចីផុយស្រួយ និងមិនច្បាស់លាស់ ។ ក្រោមស្ថានភាពបែបនេះ យើងត្រូវបានក្រើនរំឭកអំពីពាក្យចាស់ថា “ដំបៅមិនឈឺ កុំយកឈើរុក” ។

ប៉ុន្តែការកប់អតីតកាល មិនមែនជាចម្លើយនោះឡើយ ។ ដំណើរការនីតិវិធីនាពេលបច្ចុប្បន្ន នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺជាឧទាហរណ៍នៃការតស៊ូប្រឈមមុខរបស់ប្រទេសកម្ពុជាទៅនឹងប្រវត្តិសាស្ត្រដ៏ចម្រូងចម្រាស់របស់ខ្លួន ។ ក្នុងឆ្នាំ២០០៣ អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាបានសម្រេចកិច្ចព្រមព្រៀងបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលមានកាតព្វកិច្ចកាត់ទោសជនដែលដល់ពីបទឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងរបបខ្មែរក្រហម ។ ខណៈដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានវិវឌ្ឍឆ្ពោះទៅរកការបង្កើតកំណត់ត្រាប្រវត្តិសាស្ត្រស្តីពីរឿងរ៉ាវដែលបានកើតឡើង និងមូលហេតុនៃរឿងរ៉ាវទាំងនោះក្នុងរបបខ្មែរក្រហម ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មិនអាចគ្មានការតស៊ូមុតមាំ និងការស្រុះស្រួលបានឡើយ ។ តុលាការបានទទួលរងបញ្ហាផ្សេងៗជាច្រើន ហើយបានតស៊ូជាមួយនឹងបញ្ហាដ៏រ៉ាំរ៉ៃ ដូចជាការប្រមូលថវិកា ភាពស្របច្បាប់ និងការមិនស្រុះស្រួលផ្ទៃក្នុង ។ តុលាការ គឺជាឧទាហរណ៍ដ៏ល្អស្តីពីថាតើការតស៊ូប្រឈមមុខទៅនឹងអតីតកាលរបស់ខ្លួនមានការលំបាកយ៉ាងដូចម្តេច ។ ដូចគ្នាទៅនឹងស្ថាប័នផ្សេងៗដែរ តុលាការមិនមែនល្អឥតខ្ចោះនោះឡើយ ។ ប៉ុន្តែភាពខុសចន្លោះនោះមិនគួរត្រូវបានបកស្រាយថាជាកំហុស ឬជាការបរាជ័យនោះឡើយ ។ តុលាការបានបញ្ចប់ការជំនុំជម្រះអតីតប្រធានមន្ទីរសន្តិសុខដោយជោគជ័យ ហើយការជំនុំជម្រះអតីតមន្ត្រីក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានសារសំខាន់យ៉ាងខ្លាំងក្នុងការជម្នះការលំបាករបស់ប្រទេសកម្ពុជា ដើម្បីស្វែងយល់ដឹងអំពីរឿងរ៉ាវដែលបានកើតឡើង និងមូលហេតុនៃរឿងហេតុទាំងនោះ អំឡុងសម័យកាលដ៏គួរឲ្យភ័យខ្លាច ។ ប៉ុន្តែនៅពេលដែលដំណើរការនីតិវិធីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺជាជំហានដ៏សំខាន់នោះ នៅមានកិច្ចការជាច្រើនដែលត្រូវធ្វើ ។

អស់រយៈពេលជាង៣០ឆ្នាំ ក្រោយពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ប្រទេសកម្ពុជានៅតែកំពុងតស៊ូជាមួយនឹងកេរដំណែលដ៏ឈឺចាប់បន្សល់ទុកពីអំពើប្រល័យពូជសាសន៍



ស្លឹករឹត ដែលអ្នកប្រាជ្ញខ្មែរប្រើដើម្បីកត់ត្រាហេតុការណ៍ និងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រផ្សេងៗ

ការធ្វើទារុណកម្ម និងអំពើឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ។ ខណៈដែលប្រជាជនកម្ពុជា គឺជាប្រជាជនដែលមិនងាយទ្រុឌទ្រោម ដែលស៊ាំទៅនឹងការលំបាកជម្លោះនយោបាយដ៏ស្រួចស្រាវ និងល្បីងជួរចត់ បន្តប៉ះពាល់ដល់អត្តសញ្ញាណជាតិរបស់កម្ពុជា ហើយមានសំណួរជាច្រើនអំពីផលប៉ះពាល់ និងមរតកនៃដំណើរការស្វែងរកយុត្តិធម៌ក្នុងសម័យអន្តរកាល ។ ខណៈដែលយើងមិនត្រូវបន្ទន់ជំហរចំពោះយុត្តិធម៌ដោយសារមូលហេតុនយោបាយ និងភាពជាក់ស្តែង យើងគួរតែមានភាពប្រាកដនិយមចំពោះទស្សនវិស័យរបស់យើង និងនៅតែមានការប្តេជ្ញាចិត្តចំពោះភាពជឿនលឿនទៅមុខ សូម្បីតែនៅពេលដែលស្ថាប័ននយោបាយមិនស្របទៅនឹងការរំពឹងទុករបស់យើងក៏ដោយ ។ យើងត្រូវតែប្រាកដប្រជាក្នុងការស្វែងរកឱកាសដើម្បីធ្វើឲ្យពាក្យថា “Never Again” ក្លាយជាការពិតជាក់ស្តែង ។ ប្រការនេះមានន័យថា ការរួមចំណែកធ្វើការងារប្រកបដោយការស្តាបនាជាមួយស្ថាប័នទាំងឡាយ ដែលរួមចំណែកនៅក្នុងដំណើរការផ្សះផ្សាជាតិ និងការអភិវឌ្ឍក្រោយជម្លោះ និងភាពសកម្មក្នុងការស្វែងរកឱកាសដែលមានលក្ខណៈទទួលយករបត់ផ្លាស់ប្តូររួចជាស្រេច ។ មជ្ឈមណ្ឌលឯកសារកម្ពុជាមានបំណងជំរុញឲ្យសហគមន៍អន្តរជាតិចាប់យកពេលវេលានៅក្នុងដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងដំណើរការទទួលខុសត្រូវនៅកន្លែងដទៃដើម្បីធ្វើការសាកសួរពីប្រវត្តិសាស្ត្របន្ថែម និងលើកស្ទួយការផ្សះផ្សាជាតិជាមួយនឹងអតីតកាលរបស់ជនរងគ្រោះ ។

ការផ្សះផ្សាជាតិ គឺជាពាក្យដ៏មានឥទ្ធិពលដែលអាចមានន័យច្រើនយ៉ាងចំពោះមនុស្សផ្សេងគ្នា ។ ការផ្សះផ្សាជាតិ អាចមានន័យថាជាការប្រឈមមុខទៅនឹងកំហុសឆ្គងធ្ងន់ធ្ងរនៃអតីតកាលផ្ទាល់ខ្លួនរបស់បុគ្គល ឬការស្វែងរកការអត់ឱនឲ្យអ្នកដទៃចំពោះការប្រព្រឹត្តដ៏ឃោរឃៅរបស់អ្នកទាំងនោះ ។ ការផ្សះផ្សាជាតិអាចមានន័យថាជាការសន្ទនាស្តីពីព្រឹត្តការណ៍សោកនាដកម្ម ឬការប្រឹងប្រែងស្តាឡើងវិញ ។ នៅពេលដែលការផ្សះផ្សាជាតិមានអត្ថន័យដែលមានលក្ខណៈពិសេស សម្រាប់មនុស្សគ្រប់គ្នា ពាក្យនោះអាចកំណត់អត្ថន័យមនសិកាជាតិសាជាថ្មីបាន ។ ដូចដែលយើងទាំងអស់គ្នារំពឹងទុក ការផ្សះផ្សាជាតិ គឺមិនងាយស្រួលនោះឡើយ ។

ការផ្សះផ្សាជាតិ ទាមទារឲ្យមានការប្រើភាសាសាជាថ្មី ។ ការផ្សះផ្សាជាតិនោះ ទាមទារឲ្យមានការប្តេជ្ញាចិត្តក្នុងការស្វែងរកការនិយាយអំពីសន្តិភាព ការអត់ឱន និងការគោរពនាពេលសម័យ

ទំនើបនេះ ។ ភាសាស្អប់ខ្ពើម កំហឹង និងការមិនអត់ឱន ត្រូវតែបោះបង់ចោល ហើយពាក្យថ្មីសម្រាប់ផ្ទាល់ខ្លួន សហគមន៍ និងអត្តសញ្ញាណជាតិ ត្រូវតែបង្កើតឡើង ។ ជារួម ការប្រើភាសាថ្មីត្រូវស្របជាមួយនឹងការផ្លាស់ប្តូរវប្បធម៌ ហើយការផ្លាស់ប្តូរវប្បធម៌មិនសម្រេចបានដោយការអន្ទេតមើលអតីតកាលសើរៗ ឬអតីតកាលដែលបានកែប្រែនោះឡើយ ។ ជារឿយៗ សង្គមដែលងើបចេញពីជម្លោះ ពុះពារជាមួយនឹងការយល់ឃើញជាមូលដ្ឋានអំពីថាតើជនដៃដល់គឺជានរណា និងថាតើជនទាំងនោះបានប្រព្រឹត្តយ៉ាងណាខ្លះ ។ សូម្បីតែសង្គមដែលងើបចេញពីជម្លោះយូរមកហើយ នៅទទួលរងការគិតមិនចុះសម្រុងគ្នា ។ មានការជំរុញជាសម្ងាត់ឲ្យប្រើប្រាស់អំពើហិង្សាដើម្បីដោះស្រាយបញ្ហា ទោះបីជាសិទ្ធិមនុស្សជាសកលអាចមានឥទ្ធិពលដល់សាធារណៈមតិក៏ដោយ ។ ជាការពិត បញ្ហានេះមិនមែនជាបញ្ហាដោយឡែកចំពោះសង្គមដែលងើបចេញពីជម្លោះណាមួយនោះឡើយ ប៉ុន្តែអ្វីដែលមិនធ្លាប់មានពីមុនមិនគួរទទួលយកថាជាលេស ហើយទុកឲ្យសង្គមស៊ីវិលប្រឈមមុខទៅនឹងស្ថាប័នសង្គម និងនយោបាយក្នុងការតំណាងឲ្យប្រជាជនទាំងឈ្មោះ និងសកម្មភាព ។ ជាពិសេស សង្គមដែលងើបចេញពីជម្លោះត្រូវការមនសិការជាតិថ្មីមួយ ហើយជារឿយៗជាជាងគ្មានអ្នកចូលរួម សង្គមស៊ីវិលត្រូវដឹកនាំការងារនោះ ។

ចាប់តាំងពីការចាប់ផ្តើមរបស់ខ្លួន ក្នុងនាមជាសង្គមស៊ីវិល មជ្ឈមណ្ឌលឯកសារកម្ពុជា បាននាំមុខក្នុងការចងក្រងឯកសារឧក្រិដ្ឋកម្ម និងអំពើឃោរឃៅជាច្រើនក្នុងសម័យខ្មែរក្រហម ។ នៅពេលដែលមជ្ឈមណ្ឌលឯកសារកម្ពុជា បានផ្តោតលើការប្រមូលភ័ស្តុតាងស្តីពីអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្នុងគោលបំណងបង្កើតកំណត់ត្រាប្រវត្តិសាស្ត្រខ្លួនបានពង្រីកគម្រោងផ្សេងៗ និងកម្មវិធីជាច្រើន ដែលអាចត្រូវបានរៀបចំឡើងនាពេលសព្វថ្ងៃ ក្រោមកេរដំណែល យុត្តិធម៌ និងការចងចាំ ។ យុត្តិធម៌ និងការចងចាំមានសារសំខាន់ស្របទៅនឹងទស្សនៈនៃការផ្សះផ្សាជាតិ ។ យុត្តិធម៌មិនអាចសម្រេចបានដោយគ្មានការចងចាំពីជនរងគ្រោះឡើយ ហើយការចងចាំជនរងគ្រោះមិនអាចកើតឡើងដោយគ្មានភាពពិតប្រាកដនោះឡើយ ។ ដូច្នេះហើយ ការពិត យុត្តិធម៌ និងការចងចាំ គឺជាទស្សនៈចម្បងនៃបេសកកម្មរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា មិនមែនដោយសារការពិត យុត្តិធម៌ និងការចងចាំ គឺជាសសរស្តម្ភនៃប្រទេសកម្ពុជាដែលមានសន្តិភាពថ្កុំថ្កើង និងមានលទ្ធិប្រជាធិបតេយ្យនោះឡើយ ប៉ុន្តែដោយសារ ការពិត យុត្តិធម៌ និងការចងចាំ គឺជំហានដំបូងដើម្បីសម្រេចរឿងនេះ ។

នៅចន្លោះឆ្នាំ២០១៣-២០១៥ មជ្ឈមណ្ឌលឯកសារកម្ពុជា នឹងបន្តបេសកកម្មយូរអង្វែងរបស់ខ្លួន ដើម្បីលើកស្ទួយការចងចាំ យុត្តិធម៌ និងការផ្សះផ្សាជាតិ ។ យើងនឹងបន្តស្វែងរកភ័ស្តុតាងស្តីអំពីអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបន្ថែមទៀត និងអប់រំយុវជនកម្ពុជាឲ្យយល់អំពីការពិតជាប្រវត្តិសាស្ត្រទាក់ទងនឹងរបបខ្មែរក្រហម ។ ការងាររបស់យើងនឹងផ្តោតលើសេចក្តីត្រូវការរបស់ប្រជាជនទូទៅដែលជាជនរងគ្រោះ និងកូនចៅសាច់ញាតិរបស់ជនរងគ្រោះ ដែលជាការចង់បានសម្រាប់ អតីតកាល បច្ចុប្បន្នកាល និងអនាគតកាលរបស់កម្ពុជា ។ ក្រៅពីការគោរពដល់អ្នកដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហម ការងាររបស់យើងមានសារសំខាន់ក្នុងការជួយ និងគាំទ្រប្រជាជនកម្ពុជា ដែលរស់រានមានជីវិត ទាំងនៅក្នុងប្រទេស និងនៅជុំវិញពិភពលោក ។ សេចក្តីសង្ខេបខាងក្រោមនេះ គឺជាយុទ្ធសាស្ត្របង្ហាញនូវផែនការក្នុងការបង្កើតយន្តការជានិរន្ត ដែលអាចជួយជម្នះនូវស្រមោលនៃភាពឃោរឃៅរបស់ខ្មែរក្រហម ចាប់ផ្តើមយល់ដល់ដឹងពីអតីតកាល និងកសាងអនាគតដ៏ត្រចះត្រចង់ក្នុងប្រទេសកម្ពុជា ។

### ១) កេរដំណែលរូបវ័ន្ត

***ការកសាងវិទ្យាស្ថានអចិន្ត្រៃយ៍ស្រាវជ្រាវពីអំពើប្រល័យពូជសាសន៍ :*** មជ្ឈមណ្ឌលឯកសារកម្ពុជា បានចាប់ផ្តើមសាងសង់វិទ្យាស្ថានអចិន្ត្រៃយ៍របស់ខ្លួន ដើម្បីពង្រីកវិសាលភាពការងារ និងធានាឲ្យមានការប្តេជ្ញាយូរអង្វែងចំពោះការគោរពសិទ្ធិមនុស្ស និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា ។ ក្រសួងអប់រំ យុវជន និងកីឡា បានផ្តល់ដីដ៏ធំនៅក្នុងទីក្រុងភ្នំពេញ ទៅឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីកសាងវិទ្យាស្ថាននោះ ។ ផ្ទៃដីនោះមានទំហំសរុបប្រមាណ៤.៨០០ម៉ែត្រការ៉េ មានទីតាំងក្នុងបរិវេណវិទ្យាល័យបឹងត្របែក ។ យើងបានបង្កើតក្រុមជំនាញ

ផ្នែកស្ថាបត្យកម្មនៅក្នុងប្រទេសអង់គ្លេស និងសហរដ្ឋអាមេរិក ដើម្បីគូសប្លង់អគារដែលជាមជ្ឈមណ្ឌលអចិន្ត្រៃយ៍នេះ ។ យើងមានផែនការចាប់ផ្តើមដំណើរការសាងសងអាគារថ្មីនេះនៅក្នុងឆ្នាំ ២០១៨ ។

វិទ្យាស្ថានអចិន្ត្រៃយ៍នេះ នឹងមានឈ្មោះថា «វិទ្យាស្ថានស្លឹករឹត» ។ ឈ្មោះនេះឆ្លុះបញ្ចាំងអំពីគោលដៅចម្បងរបស់យើង ក៏ដូចជាកេរមរតករបស់ប្រទេសកម្ពុជា ។ ស្លឹករឹត គឺជាប្រភេទស្លឹកឈើស្ងួត ដែលព្រះសង្ឃ និងអ្នកប្រាជ្ញនៅក្នុងប្រទេសកម្ពុជាបានប្រើប្រាស់ដើម្បីកត់ត្រាប្រវត្តិសាស្ត្រ ចែករំលែកចំណេះដឹង និងរក្សាវប្បធម៌ ក្នុងសម័យកាលនៃការគ្រប់គ្រងដ៏យោរយៅអស់រយៈពេលជាច្រើនសតវត្សរ៍មកហើយ ។ ស្លឹករឹតតំណាងឲ្យទាំងសោភ័ណភាពនៃចំណេះដឹង និងអំណាចនៃសេចក្តីព្យាយាមរបស់មនុស្សក្នុងសម័យកាលដ៏វឹកវរ ។ វិទ្យាស្ថានអចិន្ត្រៃយ៍នេះនឹងបម្រើដល់មុខងារសំខាន់ៗបីយ៉ាង ៖ ទីមួយ វិទ្យាស្ថាននេះគឺជាបូជនីយដ្ឋានជារូបវន្ត ដែលលើកទឹកចិត្តដល់អ្នកទស្សនាឲ្យគោរព និងចងចាំជនរងគ្រោះដែលបានស្លាប់ទៅ និងអ្នកដែលទទួលរងទុក្ខវេទនានៅក្នុងរបបខ្មែរក្រហម ។ ទីពីរ វិទ្យាស្ថាននេះ នឹងក្លាយទៅជាមជ្ឈមណ្ឌលអប់រំដែលអនុញ្ញាតឲ្យមនុស្សជំនាន់បច្ចុប្បន្ន និងជំនាន់ក្រោយសិក្សាស្វែងយល់ពីអតីតកាលឈឺចាប់របស់ប្រទេសកម្ពុជា ។ ការអប់រំ នឹងធានាថាប្រជាជនកម្ពុជានឹងមិនបំភ្លេចអ្នកដែលបានស្លាប់ទៅដោយអយុត្តិធម៌ និងអ្នកដែលទទួលរងទុក្ខវេទនា ហើយការអប់រំនេះនឹងធ្វើឲ្យប្រជាជនកម្ពុជា មានអំណាចក្នុងការទប់ស្កាត់អំពើរំលោភបំពាន ប្រហាក់ប្រហែលគ្នានេះនាពេលអនាគត ។ ចុងក្រោយ វិទ្យាស្ថាននេះគឺជាមជ្ឈមណ្ឌលសិក្សាស្រាវជ្រាវ ដែលនឹងខិតខំប្រឹងប្រែងក្លាយទៅជាវិទ្យាស្ថាននាំមុខគេមួយ នៅក្នុងទ្វីបអាស៊ីស្តីអំពីការសិក្សាពីអំពើប្រល័យពូជសាសន៍ ដែលជាវិទ្យាស្ថានមួយដែលនឹងធ្វើទំនាក់ទំនងជាមួយអ្នកស្រាវជ្រាវជាន់ខ្ពស់ និងស្ថាប័ននាំមុខផ្សេងទៀតនៅទ្វីបអាស៊ី និងនៅលើសកលលោក ។

## ២) កេរដំណែលនៃការចងចាំ

***ការអប់រំស្តីពីអំពើប្រល័យពូជសាសន៍ ដោយមានកិច្ចសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ៖*** ការអប់រំស្តីអំពីអំពើប្រល័យពូជសាសន៍មានសារសំខាន់ណាស់ ប្រសិនបើប្រជាជនកម្ពុជាចង់ថែរក្សាប្រវត្តិសាស្ត្ររបស់ខ្លួន និងចងចាំអ្នកដែលបានស្លាប់ដោយសារអំពើឃោរឃៅនៅក្នុងរបបខ្មែរក្រហម ។ ការអប់រំស្តីអំពីអំពើប្រល័យពូជសាសន៍ ក៏មានសារសំខាន់ដែរ ប្រសិនបើប្រជាជនកម្ពុជា ចង់យល់ដឹងអំពីមូលហេតុ និងកត្តាដែលបណ្តាលឲ្យកើតមានអំពើប្រល័យពូជសាសន៍ មើលឃើញអំពីផលប៉ះពាល់នៃសោកនាដកម្ម និងដោះស្រាយបញ្ហាប្រឈមដែលនៅតែបន្តកើតមានជាច្រើនបណ្តាលមកពីអំពើប្រល័យពូជសាសន៍ ។

ដោយមានកិច្ចសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងស្ថាប័នស្រាវជ្រាវ មជ្ឈមណ្ឌលឯកសារកម្ពុជា បានបង្កើតកម្មវិធីសិក្សាគោលស្តីពីអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានត្រូវយកទៅបង្រៀននៅតាមសាលា សាកលវិទ្យាល័យ បណ្ឌិត្យសភានគរបាលកម្ពុជា និងវិទ្យាស្ថានកងទ័ពជើងគោក និងវិទ្យាស្ថានជាតិអប់រំ ។ ដោយមានអ្នកជំនាញជាតិនិងអន្តរជាតិ យើងបានផ្តល់វគ្គបណ្តុះបណ្តាលស៊ីជម្រៅដល់មន្ត្រីរាជការនិងគ្រូបង្រៀនរាប់ពាន់នាក់នៅទូទាំង២៤ខេត្ត និងរាជធានីនៅក្នុងប្រទេសកម្ពុជា ។

កម្មវិធីសិក្សានិងកម្មវិធីបណ្តុះបណ្តាលរបស់យើង ប្រើសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ សៀវភៅប្រវត្តិសាស្ត្ររបស់យើងទទួលបានការពេញនិយមពីមជ្ឈដ្ឋានអ្នកអានក្នុងស្រុកនិងអន្តរជាតិ ។ សៀវភៅនេះគឺជាសៀវភៅដំបូងបង្អស់ ដែលអប់រំយុវជនកម្ពុជាអំពីសោកនាដកម្មនៅក្នុងរបបខ្មែរក្រហម បន្ទាប់ពីរយៈពេលបីទសវត្សរ៍នៃភាពស្ងប់ស្ងាត់ អំពីប្រធានបទនេះនៅក្នុងថ្នាក់រៀនរបស់កម្ពុជា ។ សៀវភៅប្រវត្តិសាស្ត្រនេះទទួលបានការពេញនិយមចំពោះការបកស្រាយលើចំណុចរសើប ប៉ុន្តែមានការពិពណ៌នាច្បាស់លាស់ពីប្រវត្តិសាស្ត្រក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយធ្វើឲ្យមានតុល្យភាពរវាងការឆ្លុះបញ្ចាំងអំពីឧក្រិដ្ឋកម្មដ៏សាហាវ ជាមួយនឹងការគោរពសេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះ ។ ការធ្វើឲ្យមានតុល្យភាពរវាងការពិត និងភាពស្រួចស្រាវនៃបញ្ហាគឺជាគុណភាពដ៏សំខាន់នៃកម្មវិធីអប់រំរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលមានបំណងមិនត្រឹមតែធ្វើការអប់រំ ថែមទាំងចងចាំទៀតផង ។ ការអប់រំស្តីអំពីអំពើប្រល័យពូជសាសន៍ ត្រូវតែបម្រើ



គរុសិស្សសាលាគរុកោសល្យភូមិភាគខេត្តតាកែវកំពុងពិភាក្សាក្នុងក្រុមក្នុងអំឡុងវគ្គបណ្តុះបណ្តាលស្តីអំពីវិធីសាស្ត្របង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យកាលពីខែវិច្ឆិកា ឆ្នាំ២០១២ នៅខេត្តតាកែវ

ដល់សេចក្តីត្រូវការជាសាធារណៈសម្រាប់ការយល់ដឹងអំពីសម័យកាលដ៏ឈឺចាប់ ហើយការអប់រំនោះត្រូវតែធ្វើឡើងក្នុងរបៀបមួយដែលគោរព និងផ្តល់អំណាចដល់ជនរងគ្រោះ ។ ក្នុងន័យនេះ ការអប់រំស្តីអំពីអំពើប្រល័យពូជសាសន៍ គឺជាគន្លឹះដ៏សំខាន់ដើម្បីរំដោះជនរងគ្រោះក្នុងរបបខ្មែរក្រហមពីភាពភ័យខ្លាច ហើយធ្វើឲ្យជនរងគ្រោះទាំងនោះឲ្យក្លាយជាអ្នកដឹកនាំក្នុងដំណើរស្វែងរកសិទ្ធិមនុស្ស និងសេចក្តីថ្លៃថ្នូរក្នុងសកលលោក ។

***ការចងចាំជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យ*** : មជ្ឈមណ្ឌលឯកសារកម្ពុជា បានចងក្រងសៀវភៅឈ្មោះអ្នកដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហម ។ សេចក្តីដកស្រង់ខ្លីៗអំពីឈ្មោះនៅក្នុងសៀវភៅនេះនឹងផ្អែកលើការស្រាវជ្រាវរបស់យើង ហើយនឹងទទួលស្គាល់ និងចងចាំអ្នកដែលបានស្លាប់បាត់បង់ជីវិតទៅ ។ រហូតមកដល់ពេលបច្ចុប្បន្ននេះ យើងប្រមូលបានឈ្មោះប្រមាណមួយលាន នៅក្នុងប្រព័ន្ធទិន្នន័យរបស់យើង ហើយឈ្មោះថ្មីៗត្រូវបានបន្តដាក់បញ្ចូលបន្ថែម ។ សៀវភៅនេះនឹងត្រូវបានចែកចាយទៅគ្រប់សាលាឃុំទាំងអស់នៅទូទាំងប្រទេសកម្ពុជាដែលនឹងផ្តល់ឲ្យមនុស្សជំនាន់បច្ចុប្បន្ន និងជំនាន់ក្រោយនូវការចងចាំយ៉ាងជាក់លាក់ចំពោះជនរងគ្រោះដែលបានស្លាប់ក្នុងរបបខ្មែរក្រហម ។ យើងនឹងផ្សព្វផ្សាយសៀវភៅនេះនៅលើគេហទំព័រ ។

## ៣) កេរដំណែលយុត្តិធម៌

***ការផ្សព្វផ្សាយឯកសារនៅជុំវិញពិភពលោក*** : វិធីសាស្ត្រផ្សេងមួយទៀតដែលមជ្ឈមណ្ឌលឯកសារកម្ពុជា នឹងលើកស្ទួយការចងចាំ និងយុត្តិធម៌ ទាំងនៅក្នុងស្រុក និងនៅក្រៅប្រទេស គឺការថតចម្លងឯកសារមីក្រូហ្វីមជាង៩០០ដុំពីបណ្ណសារដ្ឋានរបស់យើងទៅជាឯកសារឌីជីថល ។ បច្ចុប្បន្ននេះ យើងកំពុងសហការជាមួយនឹងសាកលវិទ្យាល័យរ៉ាត់ហ្គ័រ និងមីឈីកែន និងវិទ្យាស្ថានសម្រាប់ការស្រាវជ្រាវបណ្ណាល័យ ដើម្បីសម្រេចឲ្យបាននូវគោលដៅដ៏សំខាន់នេះ និងធ្វើឲ្យសំណុំឯកសារដ៏សំខាន់របស់យើងអាចរកមើលបានតាមប្រព័ន្ធអ៊ីនធឺណិត ។ ការធ្វើបែបនេះនឹងអាចឲ្យអ្នកស្រាវជ្រាវ អ្នកកាសែត បណ្តាញសារព័ត៌មានរដ្ឋាភិបាល សហគមន៍

អន្តរជាតិ ប្រជាជនសាមញ្ញ និងប្រជាជន នៅក្រៅប្រទេសអាចធ្វើការសិក្សាស្រាវជ្រាវអំពីអំពើប្រល័យពូជសាសន៍បានប្រកបដោយប្រសិទ្ធភាព ។ ដើម្បីសម្រេចឲ្យបានផែនការនេះ យើងបានរក្សាកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។

**ការពិនិត្យមើលអំពីឧក្រិដ្ឋកម្មរបស់កម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោម** ៖ គោលបំណងបន្ថែមរបស់យើង គឺដើម្បីពង្រីកកេរដំណែលនៃដំណើរការស្វែងរកយុត្តិធម៌ ដែលកំពុងត្រូវបានអនុវត្តនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ មជ្ឈមណ្ឌលឯកសារកម្ពុជា ធ្វើការសិក្សាស្រាវជ្រាវមួយស្តីអំពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងដោយកម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោម ។ ការសិក្សានឹងស្វែងរកនូវការរំលោភបំពានផ្សេងៗ ដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ដោយពិនិត្យមើលទៅលើចំណុចដែលមានការស្រាវជ្រាវតិចតួចស្តីអំពីរបបនេះ ។ ជាការពិតណាស់ មជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើបទសម្ភាសន៍រាប់ពាន់ ជាមួយនឹងមន្ត្រីជាន់ខ្ពស់ និងអតីតកម្មាភិបាលខ្មែរក្រហមចាប់តាំងពីឆ្នាំ ២០០១មកម្ល៉េះ ដោយមានការគាំទ្រពីក្រសួងមហាផ្ទៃ ។ ការសិក្សានេះនឹងផ្តល់ឲ្យជនរងគ្រោះ ដែលមួយចំនួនមានអារម្មណ៍ថា ខ្លួនត្រូវបានកាត់ផ្តាច់ពីដំណើរការនីតិវិធីដែលកំពុងបន្តនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានូវឱកាសក្នុងការផ្តល់សក្ខីកម្មអំពីបទពិសោធន៍របស់ខ្លួន ដែលអាចឲ្យអ្នកទាំងនេះអាចដោះស្រាយជាមួយអតីតកាលរបស់ខ្លួនបាន ។ ដូចគ្នាទៅនឹងគណៈកម្មការស្វែងរកការពិត និងផ្សះផ្សា នៅក្នុងប្រទេសអាហ្វ្រិកខាងត្បូង ការសិក្សានេះសង្ឃឹមថានឹងមិនផ្តោតទៅលើការស្តីបន្ទោសដល់បុគ្គលណាមួយឡើយ ប៉ុន្តែផ្តល់ឲ្យអ្នកដែលបានរស់រានមានជីវិតពីរបបខ្មែរក្រហមនូវឱកាសនិយាយ និងត្រូវបានស្តាប់ឮពីបទពិសោធន៍ទាំងនោះដែលជាជំហានមួយដ៏សំខាន់ក្នុងដំណើរផ្សះផ្សាជាតិ និងយុត្តិធម៌ ។

**ការរំឭកអំពីច្បាប់សិទ្ធិមនុស្សចម្បងៗ** ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា នឹងស្នើសុំការអនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជាដើម្បីរៀបចំពិធីរំឭកការអនុម័តច្បាប់សិទ្ធិមនុស្សចម្បងៗ ។ ជាពិសេសយើងមានបំណងគូសបញ្ជាក់អំពីអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ដែលជាសន្ធិសញ្ញាដ៏សំខាន់មួយដែលផ្តន្ទាទោស និងហាមឃាត់អំពើប្រល័យពូជសាសន៍កាលពី៦០ឆ្នាំមុន ។ យើងក៏មានបំណងចង់ទាញការចាប់អារម្មណ៍ដល់អនុសញ្ញាស្តីអំពីសិទ្ធិមនុស្សអាស៊ាន ។ យើងសង្ឃឹមថានឹងដឹកនាំវេទិកានេះ ដោយមានកិច្ចសហការជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជាដែលបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍ក្នុងឆ្នាំ ១៩៥០ និងបានចុះហត្ថលេខាលើអនុសញ្ញាស្តីពីសិទ្ធិមនុស្សអាស៊ាន នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៨ ។ ការផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍ តំណាងឲ្យគោលការណ៍ចម្បងមួយនៃច្បាប់សិទ្ធិមនុស្សអន្តរជាតិសម័យទំនើប ហើយការចុះហត្ថលេខាលើអនុសញ្ញាស្តីពីសិទ្ធិមនុស្សអាស៊ានបង្ហាញអំពីការបន្តការប្តេជ្ញារបស់ប្រទេសក្នុងតំបន់ចំពោះសិទ្ធិមនុស្សជាមូលដ្ឋាន និងសេចក្តីថ្លៃថ្នូរ ។

វេទិកាដែលត្រូវបានស្នើឡើងនេះនឹងមានការចូលរួមពីផ្នែកជាតិនិងអន្តរជាតិ ហើយបម្រើដល់ការបន្តការលើកស្ទួយដ៏សំខាន់ដល់សិទ្ធិមនុស្ស និងទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា និងតំបន់ផ្សេងៗទៀត ។ យើងសង្ឃឹមថា វេទិកានេះនឹងបង្កើតបាននូវសហគមន៍អ្នកស្រាវជ្រាវ អ្នកតស៊ូមតិ មន្ត្រីរាជការ និងអ្នកផ្សេងៗទៀត ទាំងក្នុងនិងក្រៅប្រទេសកម្ពុជា ដើម្បីបន្តបេសកកម្មនេះ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាមានបំណងបម្រើជាមជ្ឈមណ្ឌលដ៏សំខាន់នៅទ្វីបអាស៊ី ដើម្បីធានាឲ្យបានថា អំពើឧក្រិដ្ឋកម្មដូចដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមិនកើតឡើងសាជាថ្មីម្តងទៀតឡើយ ។

ពាក្យ "Never Again" គឺជាឃ្លានិមិត្តរូបដែលត្រូវចងចាំទុកក្នុងចិត្តរបស់មនុស្សគ្រប់គ្នាក្នុងពិភពលោកយើងនេះ ។ ឃ្លានោះទាមទារឲ្យមានការសម្រេចចិត្តដ៏ប្រសើរពីរដ្ឋាភិបាល និងវិធានការច្បាស់លាស់ពីតួអង្គសង្គមស៊ីវិល ។ ជាញឹកញាប់ សង្គមស៊ីវិលបានប្រព្រឹត្តខុសសីលធម៌ ដោយមិនធ្វើឲ្យរីកចម្រើនដល់លទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងភាពស្មើគ្នាចំពោះមុខច្បាប់យ៉ាងធំទូលាយ ។ ប៉ុន្តែ ការបរាជ័យចំពោះកិច្ចខិតខំប្រឹងប្រែងនេះមិនមែនជាលេសដែលបាត់បង់ផ្លូវ ការផ្តោតការយកចិត្តទុកដាក់ ឬក្តីសង្ឃឹមតាមមធ្យោបាយផ្សេងៗទៀតឆ្ពោះទៅរកជោគជ័យ ។ យើងត្រូវតែមានះក្នុងការជំរុញឲ្យពិភពលោកស្ថិតក្នុងមាគ៌ាលទ្ធិប្រជាធិប

គេយល់ និងភាពផ្តាច់ការសង្រ្គាម និងសន្តិភាព និងការបរាជ័យ និងភាពជោគជ័យនោះឡើយ ។ ពិភពលោក គឺស្មុគស្មាញជាង ការបង្កុលបង្ហាញពណ៌ខ្មៅ និងពណ៌សទៅទៀត ហើយយើងបានធ្វើឲ្យមនុស្សធម្មតាមានទស្សនៈអាក្រក់ តាមរយៈការបន្តការរិះគន់ ភាពមិនច្បាស់លាស់ ឬការមិនចូលរួមដោះស្រាយបញ្ហា ។ ប្រទេសមួយត្រូវតែដោះស្រាយជាមួយនឹងអតីតកាលរបស់ខ្លួន ប្រសិនបើខ្លួនចង់បោះជំហានទៅមុខ ហើយវប្បធម៌មួយដែលយល់ និងលើកតម្លៃយុត្តិធម៌ ការផ្សះផ្សា និងការចងចាំ គឺមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងវប្បធម៌ដែលឲ្យតម្លៃដល់សិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ និងភាពស្មើគ្នាចំពោះមុខច្បាប់ ។ គម្លាតរវាងវប្បធម៌ទាំងពីរ (យល់ និងលើកតម្លៃ) មិនមានទំហំធំនោះទេ ហើយការដែលយើងធ្វើឲ្យមានការរីកចំរើនកាន់តែខ្លាំងទៅលើវប្បធម៌ទីមួយ នឹងមានឥទ្ធិពលដល់ភាពជោគជ័យនៃវប្បធម៌ទីពីរ ។

**ឆាំង យុ**

*លោក ឆាំង យុ គឺជានាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងជាអ្នករស់រានមានជីវិតពីរបប "វាលពិឃាត" ខ្មែរក្រហម ។ លោកបានក្លាយជានាយកមជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងឆ្នាំ១៩៩៥ នៅពេលដែលមជ្ឈមណ្ឌលនេះត្រូវបានបង្កើតឡើងក្នុងនាមជាការិយាល័យមួយរបស់សកលវិទ្យាល័យយ៉េលនៃកម្មវិធីសិក្សាពីអំពើប្រល័យពូជសាសន៍នៅប្រទេសកម្ពុជាដើម្បីធ្វើការសិក្សាស្រាវជ្រាវ បណ្តុះបណ្តាល និងចងក្រងឯកសារទាក់ទងទៅនឹងរបបខ្មែរក្រហម ។ លោក ឆាំង យុ បន្តដឹកនាំមជ្ឈមណ្ឌលឯកសារកម្ពុជា បន្ទាប់ពីមជ្ឈមណ្ឌលនេះក្លាយជាអង្គការក្រៅរដ្ឋាភិបាលឯករាជ្យមួយនៅប្រទេសកម្ពុជាក្នុងឆ្នាំ១៩៩៧ ហើយបច្ចុប្បន្ននេះ កំពុងតែធ្វើការកសាងលើកិច្ចការរបស់មជ្ឈមណ្ឌលនេះឲ្យទៅជាវិទ្យាស្ថានស្លឹករឹត ដែលជាមជ្ឈមណ្ឌលនាំមុខសម្រាប់ការសិក្សាអំពីអំពើប្រល័យពូជសាសន៍នៅអាស៊ីដែលមានមូលដ្ឋាននៅក្នុងរាជធានីភ្នំពេញ ។ លោក ឆាំង យុ គឺជាអ្នកស្រាវជ្រាវជាន់ខ្ពស់អំពីអំពើប្រល័យពូជសាសន៍នៅឯមជ្ឈមណ្ឌលស្តីពីការសិក្សាអំពើប្រល័យពូជសាសន៍ ការដោះស្រាយជម្លោះ និងសិទ្ធិមនុស្សនៅឯសាកលវិទ្យាល័យរ៉ាត់ហ្គ័រ សហរដ្ឋអាមេរិក ។ លោកគឺជាសហនិពន្ធសៀវភៅ "ស្លាកស្នាមរបួសរបស់កម្ពុជា ៖ ការប៉ះទង្គិចផ្លូវចិត្ត បន្ទាប់ពីរបបខ្មែរក្រហម" ដែលត្រូវបានបោះពុម្ពនៅឆ្នាំ២០១១ ។*



*លោកក៏ជាអ្នកសរសេរអត្ថបទ និងជំពូកនៅក្នុងសៀវភៅជាច្រើនអំពីការស្វែងរកការពិត ការចងចាំ និងយុត្តិធម៌របស់ប្រទេសកម្ពុជា ។ លោកក៏ជានាយកផលិតកម្មខ្សែភាពយន្តឯកសារដែលមានចំណងជើងថា "ក្បង់ទឹកទន្លេ" ផលិតឡើងនៅឆ្នាំ២០១២ ស្តីអំពីការប្រែប្រួលបរិយាកាសសង្គម សេដ្ឋកិច្ច និងបរិស្ថាននៅក្នុងប្រទេសកម្ពុជា ។ ខ្សែភាពយន្តនេះទទួលបានពានរង្វាន់ភាពយន្តពិភពលោកនៅមហោស្រពសាន់ឌេននៅសហរដ្ឋអាមេរិកក្នុងឆ្នាំ២០១៣ ។ លោក ឆាំង យុ បានទទួលពានរង្វាន់សេរីភាពប្រធានាធិបតីសហរដ្ឋអាមេរិក ទ្រូមេន-រីហ្គេន ពីមូលនិធិចងចាំជនរងគ្រោះនៃរបបកុម្មុយនីស្តនៅក្រុងវ៉ាស៊ីនតោន ឌីស៊ី ក្នុងឆ្នាំ២០០០ ។ លោកបានជាប់ជាមនុស្សមួយរូបក្នុងចំណោមវីរជននៅអាស៊ីចំនួន៦០រូបរបស់ទស្សនាវដ្តី "ថែមស៍" ក្នុងឆ្នាំ២០០៦ និងជាមនុស្សមួយរូបក្នុងចំណោមមនុស្ស១០០នាក់ ដែលមានឥទ្ធិពលបំផុតនៅក្នុងពិភពលោកក្នុងឆ្នាំ២០០៧ ចំពោះជំហររបស់លោកក្នុងការប្រឆាំងទៅនឹងនិទណ្ឌភាពនៅក្នុងប្រទេសកម្ពុជា និងតំបន់ផ្សេងទៀតនៃពិភពលោក ។* **ចន ឆរធីអារី សាស្ត្រាចារ្យនៅសកលវិទ្យាល័យមីឈីហ្គេន**

# ការដាក់ទោសទណ្ឌ និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍

កាលពីថ្ងៃទី២៨ ខែកុម្ភៈ ដល់ថ្ងៃទី១ ខែមីនា ឆ្នាំ២០១៣នេះ កម្ពុជាបានធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំវេទិកាទីបលើកទី៤ ក្រោមប្រធានបទ "ការទប់ស្កាត់អំពើប្រល័យពូជសាសន៍" ដោយមានការជួយឧបត្ថម្ភផ្នែកហិរញ្ញវត្ថុពីសំណាក់រដ្ឋាភិបាលប្រទេសស្វីស សហការជាមួយរដ្ឋាភិបាលប្រទេសតង់ហ្សានី និងប្រទេសអាហ្សង់ទីន ។ នាឱកាសកិច្ចប្រជុំថ្នាក់ទីបនេះ មានកិច្ចការសំខាន់មួយដែលត្រូវពិចារណាឲ្យបានដិតដល់គឺថា ដើម្បីដាក់ទោសទណ្ឌ និងទប់ស្កាត់អំពើប្រល័យពូជសាសន៍នាថ្ងៃអនាគត តម្រូវឲ្យមានការចូលរួមពីស្ថាប័ន និងរដ្ឋាភិបាលលើសពីមួយ ។ អំពើប្រល័យពូជសាសន៍ និងអំពើយង់ឃ្នងទាំងឡាយបានកើតឡើងចាប់តាំងពីការកកើតមនុស្សជាតិមកម្ល៉េះ ប៉ុន្តែទើបតែរយៈពេល៧០ឆ្នាំចុងក្រោយនេះតែប៉ុណ្ណោះដែលយើងចាប់ផ្តើមពង្រឹងក្របខណ្ឌគតិយុត្តិដើម្បីដោះស្រាយជំងឺដែលកំពុងតែព្យាបាទមនុស្សជាតិដ៏សំខាន់មួយនេះ ។

កិច្ចប្រជុំវេទិកាទីបលើកទី៤នេះគឺជាកិច្ចខិតខំប្រឹងប្រែងមួយដើម្បីដោះស្រាយបញ្ហាទាំងអស់ខាងលើដោយ នៅក្នុងវេទិកានេះមានការចូលរួម និងពិភាក្សាពីអ្នកតំណាងថ្នាក់ដឹកនាំ និងមន្ត្រីជំនាញជាច្រើនរូបមកពីទូទាំងប្រទេសក្នុងសកលលោកដើម្បីចែករំលែកព័ត៌មានទាំងឡាយ និងដើម្បីលើកកម្ពស់គំនិតច្នៃប្រឌិតថ្នាក់សកលដែលចាំបាច់ក្នុងន័យទប់ស្កាត់មិនឲ្យអំពើឃោរឃៅនានាកើតឡើងជាថ្មីទៀត ។ ក្របខណ្ឌគតិយុត្តិទាមទារឲ្យមានធនធានផ្សេងៗជាច្រើន ដោយសារតុលាការតែឯកឯងមិនអាចវិនិច្ឆ័យត្រឹមតែមានឆន្ទៈរបស់ខ្លួនតែប៉ុណ្ណោះបានទេ ។ ប្រទេសនីមួយៗត្រូវរួបរួមគ្នាទប់ស្កាត់ និងដាក់ទោសទណ្ឌចំពោះអំពើប្រល័យពូជសាសន៍មិនត្រឹមតែតាមរយៈផ្លូវច្បាប់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងតាមរយៈផ្លូវសីលធម៌ក្នុងការធានាឲ្យប្រាកដថាពាក្យ "Never Again" ឬជាភាសាខ្មែរ "មិនកើតឡើងសាជាថ្មីម្តងទៀត" ឆ្លើយតបទៅនឹងអត្ថន័យរបស់ពាក្យនោះ ។ ខ្ញុំសូមអំពាវនាវដល់សាធារណជន បណ្តាញសារព័ត៌មាន និងរដ្ឋាភិបាលទាំងឡាយ ចាប់យកភារកិច្ចជាប្រវត្តិសាស្ត្រនៅចំពោះមុខយើងនេះដើម្បីធានាឲ្យប្រាកដថា ពាក្យ "មិនកើតឡើងសាជាថ្មីម្តងទៀត" ដក់ជាប់ក្នុងស្មារតីរបស់មនុស្សគ្រប់គ្នាជានិច្ច ។ នៅប្រទេសកម្ពុជា សំណើនេះទាមទារឲ្យមានការប្តេជ្ញាចិត្តយ៉ាងមុតមាំដើម្បីបញ្ចប់សំណុំរឿងក្តីដែលមិនទាន់ដោះស្រាយរួចរាល់នៅក្នុងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ការប្តេជ្ញាចិត្តនោះគឺជាការភ្ជាប់ជាមួយនូវក្តីបារម្ភអំពីឯករាជភាពរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនេះដែរ ។

តុលាការណាមួយក៏ដោយ ក៏ត្រូវទទួលរងនូវការរិះគន់ពីសាធារណជនដែរ ។ ការរិះគន់ដែលមានមូលដ្ឋានច្បាស់លាស់សបញ្ជាក់អំពីលទ្ធិប្រជាធិបតេយ្យទូលំទូលាយ ។ ប៉ុន្តែ រដ្ឋាភិបាលទាំងឡាយមានកាតព្វកិច្ចគាំទ្រឯករាជ្យភាពរបស់តុលាការដែលមិនមែនជាការគាំទ្រទាំងងងឹតស្លុបនោះទេ ប៉ុន្តែជាការគាំទ្រក្នុងន័យស្ថាបនា ។ រដ្ឋាភិបាលទាំងឡាយមិនគួរព្រងើយកន្តើយនឹងកិច្ចការរបស់តុលាការឡើយ ប៉ុន្តែគួរតែចូលរួមប្រកបដោយការស្ថាបនាដើម្បីធានាថា តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមត្រូវបានផ្តល់ឱកាសមួយដើម្បីសម្រេចការងារស្វែងរកយុត្តិធម៌របស់ខ្លួន ។ ធនធានដែលមានស្រាប់គួរតែឆ្លើយតបទៅនឹងការចង់ឃើញនូវការបញ្ចប់អាណត្តិរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនេះ យើងមិនគួរអនុញ្ញាតឲ្យបញ្ហានយោបាយមកបង្អាក់ភាពប្តេជ្ញាចិត្តរបស់យើងក្នុងការស្វែងរកយុត្តិធម៌ និងការពិតជូនជនរងគ្រោះក្នុងប្រទេសកម្ពុជារាប់លាននាក់នោះឡើយ ។

**ឆាំង យុ**

- **និយាយពីការរស់នៅក្នុងសម័យខ្មែរក្រហម គឺនិយាយពីការផ្សះផ្សា អប់រំកូនចៅឱ្យអត់ឱន អធ្យាស្រ័យគ្នា**
- **រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គឺរៀនពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍**

# បញ្ជីឈ្មោះនិងរូបថតអ្នកទោសមន្ទីរស-២១ដែល ទទួលបាននៅថ្ងៃទី៩ ខែសីហា ឆ្នាំ២០១២

អ្នកកត់ត្រា ៖ ឆាំង យុ, ញាណ សុជាតិ និង ស៊ីរិ សាវីណា

(តពីលេខមុន)

| ល.រ | ឈ្មោះ | ភេទ | លេខរូបថត | រឿងរ៉ាវទាក់ទងនឹងប្រវត្តិរូបសង្ខេប |
|---|---|---|---|---|
| ៥៣៧ | ម៉ៅនី-រី | ស្រី | ៧៥ | ៨.៣.៧៨ |
| ៥៣៨ | នូពុំ-ប៉ូពុំ | ប្រុស | ៧១ | ៨.៣.៧៨ |
| ៥៣៩ | តាត់ ស្រ៊ិន | ប្រុស | ៧៣ | ៨.៧.៧៨ |
| ៥៤០ | ស៊ាង ខាន-ឃន | ប្រុស | ៥៨៤ | ៣០.៣.៧៨ |
| ៥៤១ | ឈំហ -ធាន | ប្រុស | ៥៨៥ | ៣០.៣.៧៨ |
| ៥៤២ | អ៊ួនឃិន ដួន | ប្រុស | ៣៧ | ១.៤.៧៨ |
| ៥៤៣ | សឆយ ណាមសម | ប្រុស | ៥៩៣ | ៣០.៣.៧៨ |
| ៥៤៤ | ហេង សំអាន | ប្រុស | ៥៨៧ | ២៣.៨.៧៨ |
| ៥៤៥ | សេក ស៊ាង | ប្រុស | ៥៦៩ | ២៣.៦.៧៨ |
| ៥៤៦ | ឃី សាមាន | ប្រុស | ៥៦០ | ២៣.៦.៧៨ |
| ៥៤៧ | ពុត ឆៃ | ប្រុស | ៥៦១ | ២៣.៦.៧៨ |
| ៥៤៨ | តុល ទូចហ៊ាង | ប្រុស | ៤០ | ១.៤.៧៨ |
| ៥៤៩ | ឈុន គ្រី | ប្រុស | ៤០៦ | ២៦.៦.៧៨ |
| ៥៥០ | សាយ ឆានរីម | ប្រុស | ១៤ | ១.៤.៧៨ |
| ៥៥១ | អ៊ី តុង | ប្រុស | ២០ | ៤.៣.៧៨ |
| ៥៥២ | ឡេ យ៉ាំងពិច | ប្រុស | ? | ១៤.៣.៧៨ |
| ៥៥៣ | គីម សង | ប្រុស | ៣២១ | ១២.៥.៧៨ |
| ៥៥៤ | ទិត ច័ន្ទណារី | ស្រី | ៥២១ | ២១.៦.៧៨ |
| ៥៥៥ | ម៉ា អ៊ុម | ស្រី | ៥២២ | ២១.៦.៧៨ |
| ៥៥៦ | សិរិត សុខឿន | ស្រី | ៥២៣ | ២១.៦.៧៨ |
| ៥៥៧ | ព្រាប ភាន់ | ប្រុស | ៨០ | ១១.៧.៧៨ |
| ៥៥៨ | សួន ស៊ុនហេង | ប្រុស | ៨៣ | ១១.៧.៧៨ |
| ៥៥៩ | ឡេ ឡាំ | ប្រុស | ៨៩ | ១១.៧.៧៨ |
| ៥៦០ | អ៊ិន់ យឿម | ប្រុស | ៩០ | ១១.៧.៧៨ |

| | | | | |
|---|---|---|---|---|
| ៥៦១ | គង់ សុអួន | ប្រុស | ៨៨ | ១១.៧.៧៨ |
| ៥៦២ | ឆាន ថា | ប្រុស | ៨៤ | ១១.៧.៧៨ |
| ៥៦៣ | ធន់ ឌឹម | ប្រុស | ៨៧ | ១១.៧.៧៨ |
| ៥៦៤ | ភ៉ាត វី | ប្រុស | ៨៦ | ១១.៧.៧៨ |
| ៥៦៥ | ហែម មឿន | ប្រុស | ៨៥ | ១១.៧.៧៨ |
| ៥៦៦ | ភួង កែម | ប្រុស | ៨១ | ១១.៧.៧៨ |
| ៥៦៧ | គី អ៊ាវ | ប្រុស | ៨២ | ១១.៧.៧៨ |
| ៥៦៨ | លឹម ភេង | ប្រុស | ៥៦៧ | ៣០.៣.៧៨ |
| ៥៦៩ | ឃ្វិប ភិន-ការ | ប្រុស | ៥៦៨ | ៣០.៣.៧៨ |
| ៥៧០ | ឃិន ហុង | ប្រុស | ៣៩៥ | ២១.៦.៧៨ |
| ៥៧១ | ជួប សាមឿន | ប្រុស | ៣៨៦ | ២១.៦.៧៨ |
| ៥៧២ | មាគ សារូន | ប្រុស | ៣៨៤ | ២១.៦.៧៨ |
| ៥៧៣ | ទេព អ៊ុម | ប្រុស | ៦៥៧ | ២៨.៦.៧៨ |
| ៥៧៤ | ម៉ៅ សេមឃួន | ប្រុស | ១៤៨ | ១៤.៣.៧៨ |
| ៥៧៥ | មេន អឿន | ប្រុស | ៥៩៨ | ៣០.៣.៧៨ |
| ៥៧៦ | សៅ មាន | ប្រុស | ៥៦៥ | ២៣.៦.៧៨ |
| ៥៧៧ | មាឃ សិម-ដុន | ស្រី | ៧៣ | ៨.៣.៧៨ |
| ៥៧៨ | ខ្លែម រឿ-រឿម | ស្រី | ៧៤ | ៨.៣.៧៨ |
| ៥៧៩ | ព្រុំ សាអុន | ប្រុស | ៥៦៦ | ២៣.៣.៧៨ |
| ៥៨០ | ឈុន ឡាយគង់ | ប្រុស | ៤១ | ១.៤.៧៨ |
| ៥៨១ | ភ៉ា សារឿន | ប្រុស | ៤០៤ | ២១.៦.៧៨ |
| ៥៨២ | ឈុន គ្រី | ប្រុស | ៤០៦ | ២១.៦.៧៨ |
| ៥៨៣ | ភ៉ា សារឿន | ប្រុស | ៤០៤ | ២១.៦.៧៨ |
| ៥៨៤ | យើយ ខុម-ខាន | ប្រុស | ៥៧១ | ៣០.៣.៧៨ |
| ៥៨៥ | យ៉ៅ យុំ | ប្រុស | ៧៥៩ | ២០.៤.៧៨ |
| ៥៨៦ | ពុត អ៊ួម-សំអោន | ប្រុស | ៧៦០ | ២០.៤.៧៨ |
| ៥៨៧ | មុំ ឈន | ប្រុស | ៧៦១ | ២០.៤.៧៨ |
| ៥៨៨ | ប៉ក់ គ្រឿន | ប្រុស | ២៧២ | ១៣.៦.៧៨ |
| ៥៨៩ | វាន យន | ប្រុស | ៥០៣ | ២១.៦.៧៨ |
| ៥៩០ | ឈឹម ហ៊ាម | ប្រុស | ៤៨២ | ២១.៦.៧៨ |
| ៥៩១ | ឡុង វ៉ា | ប្រុស | ៤៨៣ | ២១.៦.៧៨ |
| ៥៩២ | ប៉ែន ពោន | ប្រុស | ៤៨៤ | ២១.៦.៧៨ |

| | | | | |
|---|---|---|---|---|
| ៥៩៣ | ប៊ូ វ៉ា | ប្រុស | ៤៨៥ | ២១.៦.៧៨ |
| ៥៩៤ | មាស សារន | ប្រុស | ៤៨៦ | ២១.៦.៧៨ |
| ៥៩៥ | ខាន់ និល | ប្រុស | ៤៨៧ | ២១.៦.៧៨ |
| ៥៩៦ | អ៊ិន សំអឿន | ប្រុស | ៤៨៨ | ២១.៦.៧៨ |
| ៥៩៧ | ហ៊ីង យ៉ុម | ប្រុស | ៤៨៩ | ២១.៦.៧៨ |
| ៥៩៨ | ហ៊ាន ផន | ប្រុស | ៤៩០ | ២១.៦.៧៨ |
| ៥៩៩ | ស៊ាន ហួយ | ប្រុស | ៤៩១ | ២១.៦.៧៨ |
| ៦០០ | សំ ប៉ុល | ប្រុស | ៤៩២ | ២១.៦.៧៨ |
| ៦០១ | ស៊ុន ឡាយ | ស្រី | ៧៨៣ | ២០.៤.៧៨ |
| ៦០២ | ពៅ សារ | ប្រុស | ៧៧៧ | ២០.៤.៧៨ |
| ៦០៣ | សូ ចាន់ | ប្រុស | ៧៧៩ | ២០.៤.៧៨ |
| ៦០៤ | យិន ហុង | ប្រុស | ៣៩៥ | ២១.៦.៧៨ |
| ៦០៥ | ឡូត ស៊ុន | ប្រុស | ២៥៥ | ១១.៦.៧៨ |
| ៦០៦ | ស៊ាម ឆាយ | ប្រុស | ៣៨៣ | ២១.៦.៧៨ |
| ៦០៧ | មាត សារួន | ប្រុស | ៣៨៤ | ២១.៦.៧៨ |
| ៦០៨ | ខៀវ ឈិន | ប្រុស | ៥៣៨ | ២៣.៦.៧៨ |
| ៦០៩ | ឡេ យ៉ាំងកែវ | ប្រុស | ១១ | ១២.១០.៧៨ (២) ជនជាតិវៀតណាមមានចំណារលើរូបថត |
| ៦១០ | ឡេ យ៉ាំងវេ | ប្រុស | ១២ | ១២.១០.៧៨ (២) ជនជាតិវៀតណាម |
| ៦១១ | ក្រឹង ធីប៉ែ | ស្រី | ១៣ | ១២.១០.៧៨ (២) ជនជាតិវៀតណាម |
| ៦១២ | វិន យ៉ាំងអ៊ី | ប្រុស | ១០ | ១២.១០.៧៨ (២) ជនជាតិវៀតណាម |
| ៦១៣ | អៀវ ហាយហ៊ត | ប្រុស | ៣៩៩ | ២១.៣.៧៨ |
| ៦១៤ | គ្រី តុងហួន | ប្រុស | ៧៨៤ | ២០.៤.៧៨ |
| ៦១៥ | ឆេង ស្រ៊ុយ | ប្រុស | ៧៨៥ | ២០.៤.៧៨ |
| ៦១៦ | សួស វិរិទ្ធ-ស៊ូ | ប្រុស | ៧៨៨ | ២០.៤.៧៨ (រូបរាងដូចជាក្មេង) |
| ៦១៧ | ឈួន ហេង | ប្រុស | ៧៨៧ | ២០.៤.៧៨ |
| ៦១៨ | ភោគ សេថា-ថា | ប្រុស | ៧៨៨ | ២០.៤.៧៨ |
| ៦១៩ | ឌុក គាន់ | ប្រុស | ៧៩០ | ២០.៤.៧៨ |
| ៦២០ | គីម អឿន | ប្រុស | ៧៨៩ | ២០.៤.៧៨ |
| ៦២១ | ឡេ គីងធុយ | ប្រុស | ? | ៥.៩.៧៨ ជនជាតិវៀតណាមមានចំណារលើរូបថត |
| ៦២២ | ឈៀក លាងស្រេង | ប្រុស | ៩៣ | ១១.៧.៧៨ |
| ៦២៣ | ទឹម ឃួន-សុ | ប្រុស | ៩៤ | ១១.៧.៧៨ |
| ៦២៤ | ខន ខុម-នី | ប្រុស | ៩៥ | ១១.៧.៧៨ |

| | | | | |
|---|---|---|---|---|
| ៦២៥ | សួន សារឿន | ប្រុស | ៩៦ | ១១.៧.៧៨ |
| ៦២៦ | សេង ប៉ាវ | ប្រុស | ៩២ | ១១.៧.៧៨ |
| ៦២៧ | ហេ ហេង | ប្រុស | ៩១ | ១១.៧.៧៨ |
| ៦២៨ | ផ្លោក ឈិន | ប្រុស | ៥៦២ | ៣០.៣.៧៨ |
| ៦២៩ | ហ៊ីវ ញ៉ៀ | ស្រី | ៣ | ៤.៩.៧៨ |
| ៦៣០ | ជឿង ពី | ប្រុស | ៤ | ៤.៩.៧៨ |
| ៦៣១ | សេង ធឿន- យន | ប្រុស | ៥ | ៤.៩.៧៨ |
| ៦៣២ | ដឹម ចន | ប្រុស | ៧២១ | ៣០.៦.៧៨ |
| ៦៣៣ | ? សារឿន | ប្រុស | ២៤ | ២.៦.៧៨ |
| ៦៣៤ | អ៊ុត ឈាង-សារ៉ាត | ប្រុស | ២៥ | ២.៦.៧៨ |
| ៦៣៥ | ព្រុំ ចាន់សំណាង | ប្រុស | ២៦ | ២.៦.៧៨ |
| ៦៣៦ | មុត ម៉េ | ប្រុស | ២៧ | ២.៦.៧៨ |
| ៦៣៧ | គីមលិញ វិន | ប្រុស | ២៨ | ២.៦.៧៨ |
| ៦៣៨ | រេ អុម | ប្រុស | ២៩ | ២.៦.៧៨ |
| ៦៣៩ | ព្រុំ ភាន | ប្រុស | ៣០ | ២.៦.៧៨ |
| ៦៤០ | ? សារេន | ប្រុស | ៣១ | ២.៦.៧៨ |
| ៦៤១ | វ៉ាន់ ផង | ប្រុស | ៣២ | ២.៦.៧៨ |
| ៦៤២ | ចច នេ | ប្រុស | ៣៣ | ២.៦.៧៨ |
| ៦៤៣ | សុន ម៉េ | ប្រុស | ១៣៤ | ១២.៨.៧៨ |
| ៦៤៤ | អុនយោគ-អាន | ប្រុស | ៣៥ | ២.៦.៧៨ |
| ៦៤៥ | មាក ដន | ប្រុស | ៣៦ | ២.៦.៧៨ |
| ៦៤៦ | ប៉ុល អឿន-ភាព | ប្រុស | ៣៧ | ២.៦.៧៨ |
| ៦៤៧ | ទុយ សារ៉េត | ប្រុស | ៣៨ | ២.៦.៧៨ |
| ៦៤៨ | ឡោ សេម | ប្រុស | ៣៩ | ២.៦.៧៨ |
| ៦៤៩ | ជម ស្រ៊ាន | ប្រុស | ៤០ | ២.៦.៧៨ |
| ៦៥០ | កៅ ឆេសារី-សាន | ប្រុស | ៤១ | ២.៦.៧៨ |
| ៦៥១ | សរិត សុខឿន | ស្រី | ៥២៣ | ២១.៦.៧៨ |
| ៦៥២ | សេក ស៊ាង | ប្រុស | ៥៦៩ | ២៣.៦.៧៨ |
| ៦៥៣ | ដៃ ស៊ាង | ប្រុស | ៦៧៣ | ២៨.៦.៧៨ |
| ៦៥៤ | ព្រុំ សាខុន | ប្រុស | ៥៦៦ | ២៣.៦.៧៨ |
| ៦៥៥ | ណៅយោគ-វ៉ាន | ប្រុស | ៧២ | ៨.៣.៧៨ |
| ៦៥៦ | នាង សុមន | ប្រុស | ១៥៨ | ៧.៦.៧៨ **(នៅមានត)** |

# អ្នកនិពន្ធ ត្រឹង ងា នៅមន្ទីរស-២១

## ដកស្រង់ចេញពីឯកសារខ្មែរក្រហម J០០៣៦៣

ឯកសារសរុបចម្លើយរបស់ ត្រឹង ងា មានកម្រាស់ ១២ទំព័រ វាយជាអក្សរលីលេខ ប៉ុន្តែមិនមានការចុះហត្ថលេខា ឬស្នាមមេដៃរបស់សាមីខ្លួន ទីកន្លែងចាប់ខ្លួន និងកាលបរិច្ឆេទទេ ។ ខាងក្រោមនេះ ជាការដកស្រង់សេចក្តីចេញពីចម្លើយរបស់ ត្រឹង ងា ដែលនៅក្របមុខសរសេរថា សេចក្តីរាយការណ៍លើកទីមួយ និងមានចំណារថា ចម្លើយត្រួស ត្រឹង ងា សមាជិក ហុលរ៉ូ ដែលមានន័យពេញថា "រណសិរ្សរួបរួមដើម្បីរំដោះជនជាតិភាគតិចដែលទទួលរងការជិះជាន់" ។

**ក) អំពីប្រវត្តិផ្ទាល់ខ្លួន ៖**

១) ឈ្មោះ ត្រឹង ងា ជនជាតិកម្ពុជាក្រោម អាយុ៣៨ឆ្នាំ កើតនៅស្រុកឃិញចូវ ខេត្តពលលាវ កម្ពុជាក្រោម ។

២) កំរិតវប្បធម៌ និងមុខតំណែង

◆ ក្នុងឆ្នាំ១៩៥៤ ប្រឡងជាប់មធ្យមសិក្សាបឋមភូមិ

◆ ក្នុងឆ្នាំ១៩៥៦ ចូលមកប្រទេសកម្ពុជា

◆ ក្នុងឆ្នាំ១៩៥៦ ប្រឡងជាប់បញ្ញាប័ត្រមធ្យមសិក្សាភាគទី១

◆ ក្នុងឆ្នាំ១៩៥៧ ប្រឡងជាប់សញ្ញាប័ត្រមធ្យមសិក្សាភាគទី២

◆ ក្នុងឆ្នាំ១៩៥៧ ធ្វើសាស្ត្រាចារ្យនៅខេត្តបាត់ដំបង

◆ ក្នុងឆ្នាំ១៩៦១ ផ្លាស់ពីបាត់ដំបងមកភ្នំពេញ

**ខ) សកម្មភាពនយោបាយ ៖**

◆ ឆ្នាំ១៩៥៩ សមាជិកសង្គមនិយម ។

◆ ឆ្នាំ១៩៦២ បានស្គាល់ លន់ នល់ តាមរយៈ ថាច់ ចាន់

◆ ឆ្នាំ១៩៦៣ ចូលរួមសន្និសីទតណ្ឌចិនមាន សម្តេច សីហនុ ជាប្រធាន ។

◆ ឆ្នាំ១៩៦៧ -៦៨ ចូលរួមចលនាតស៊ូកម្ពុជាក្រោម មាន លន់ នល់ ជាប្រធាន ។ សមាជិកដែលចូលរួមមាន ៖ ទី១) គីម ង្វនត្រាច ទេសាភិបាលធនាគារជាតិ ទី២) ថាច់ ប៉ូច វរសេនីយឯក ទី៣) ថាច់ ជា សាស្ត្រាចារ្យ ទី៤) ដៀន កៀន វេជ្ជបណ្ឌិត និង ទី៥) ម៉ាច សម្បត្តិ ឱសថបណ្ឌិត ។ ក្នុងការប្រជុំ លន់ នល់ បានវាយផ្នែកនយោបាយលើខ្មែរក្រហម

◆ ឆ្នាំ១៩៧១ សមាជិកគណៈកម្មាធិការតាក់តែងរដ្ឋធម្មនុញ្ញ "ធម្មនុញ្ញ លន់ នល់"

◆ ឆ្នាំ១៩៧២ ត្រឹង ងា ទៅប្រទេសថៃ ភូមា ឥណ្ឌូណេស៊ី ម៉ាឡេស៊ី សឹង្ហបូរី ដើម្បីស្រាវជ្រាវព័ត៌មានពីប្រទេសនោះ ។ សមាជិកដែលទៅជាមួយមាន ៖ ទី១) ហូ តុងលិម ទី២) ថាច់ គ្មាន ទី៣) ដួង សារិន ទី៤) អ៊ិត សារ៉េត ស័ក្តិ៥) ទី៥) អែល ប្រហ៊ីម ទី៦) សន ថាត និងទី៧) អ៊ុម យូហៃ ។

◆ ឆ្នាំ១៩៧៤ ធ្វើប្រធានសមាគមខ្មែរកម្ពុជា

◆ ឆ្នាំ១៩៧៤ ត្រឹង ងា សុំលុយ លន់ នល់ ចំនួន ៦.០០០.០០០រៀល បោះពុម្ពសៀវភៅប្រវត្តិសាស្ត្រខ្មែរ

◆ ឆ្នាំ១៩៧៥ ក្រោយពីទូតអាមេរិកាំងចេញពីកម្ពុជាហើយ លន់ នល់ ទៅបរទេស ត្រឹង ងា បានចូលប្រជុំតាមរយៈ គីម ង្វនត្រាច នៅទេសាភិបាលធនាគារជាតិ ។

បញ្ជាក់នៅក្នុងប្រវត្តិរូប

◆ នៅថ្ងៃទី៨ ខែ៣ ឆ្នាំ១៩៧០ ហង់ ធន់ហាក់ ហៅ ត្រឹង ងា ទៅសម្ភាសន៍នៅក្នុងទូរទស្សន៍ពីរឿងសម្តេច សីហនុ ។

◆ ឆ្នាំ១៩៧០ ហង់ ធន់ហាក់ ហៅ ត្រឹង ងា, ឈូក មឹងម៉ៅ, ប៉ាង ខាត់ (លោកសង្ឃ) , គង់ អ៊ិន, ទួន ខឿន, ថាច់ ជា, ដួង សារិន ដើម្បីប្រជុំ ។

◆ នៅឆ្នាំ១៩៧៤ ត្រឹង ងា បានចូលរួមធ្វើសង្គ្រាមនយោបាយនៅចម្ការមន ។

◆ ក្រោយពីមានលេចបាតុកម្មសិស្ស និស្សិត នល់ នល់ បានជ្រើសរើសមនុស្សមួយចំនួនដែលជំនិតដើម្បីឲ្យកាន់ក្រសួង

នានា ។ អ្នកដែលបានតែងតាំងមាន ៖ ទី១) ថាច់ ដា ក្រសួងអប់រំ ទី២) គង់ នឿន ទី៣) គាម ទត ទី៤) គង់ ង៉ែត និងទី៥) ស៊ូ វ៉ន ។

**ក) អំពីប្រពន្ធ**

១) ប្រពន្ធឈ្មោះ ឡាយ ហ៊ុនគី អាយុ៣៨ឆ្នាំ កើតនៅឃុំទឹកជោរ ស្រុកព្រះនេត្រព្រះ ខេត្តបាត់ដំបង (បច្ចុប្បន្នខេត្តបន្ទាយមានជ័យ) ។

២) កំរិតវប្បធម៌ ៖

◆ ឆ្នាំ១៩៤៧ រៀននៅបឋមសិក្សា

◆ ឆ្នាំ១៩៥៧ ធ្វើគ្រូបង្រៀន

◆ ឆ្នាំ១៩៦២ ចូលរៀននៅវិទ្យាស្ថានជាតិគរុកោសល្យ ផ្នែកអប់រំសាស្ត្រាចារ្យ

◆ ឆ្នាំ១៩៦៨ ជាប់បរិញ្ញាប័ត្រអក្សរសាស្ត្រ

◆ ឆ្នាំ១៩៧៤ ធ្វើសាស្ត្រាចារ្យនៅសាលាស៊ីសុវត្ថិ

◆ ឆ្នាំ១៩៧៥ បានទទួលតំណែង ជានាយកវិទ្យាល័យនារី រហូតដល់រំដោះ

៣) សកម្មភាពនយោបាយ ៖

◆ ឆ្នាំ១៩៥២-៥៣ ចូលរួមចលនាប្រឆាំងបារាំង នៅភ្នំពេញ

◆ ឆ្នាំ១៩៥៩ ចូលជាសមាជិកសង្គមនិយម

◆ ឆ្នាំ១៩៧២ ចូលក្នុងគណបក្សស្ត្រីខ្មែរ

◆ ឆ្នាំ១៩៧៤ សមាជិកសង្គហនារី

**ឃ) អំពីឪពុកម្តាយបង្កើត**

◆ ឪពុកឈ្មោះ ឡាំ សុង ជាតិខ្មែរ អាយុ៦១ឆ្នាំ (មុនរំដោះនៅភ្នំពេញ) ។ គាត់គ្មានមុខរបរ កាលពីដើមធ្វើទាហានបារាំង ក្រោយមកធ្វើប៉ូលីសវៀតណាមខាងត្បូង ។ គាត់មករស់នៅភ្នំពេញ ឆ្នាំ១៩៦៥ ។ គាត់កើតនៅភូមិជ្រៃជាប់ (ឃុំមិនច្បាស់) ស្រុកថាញ់ហ៊ឹង ខេត្តពលលាវ កម្ពុជាក្រោម ។

◆ ម្តាយឈ្មោះ ទិន សៀម ជាតិខ្មែរ អាយុ៦០ឆ្នាំ ធ្វើមេផ្ទះតាំងពីដើមមក ។ មុនរំដោះ គាត់នៅភ្នំពេញជាមួយ ត្រឹង ង៉ា ។ គាត់មានស្រុកកំណើតដូចប្តី ។

**ង) អំពីបងប្អូនបង្កើត ៖** មានបងប្អូនបីនាក់ គឺ ត្រឹង ធីហ៊ួន, ត្រឹង ង៉ា និង ត្រឹង ថាច់

១) ត្រឹង ធីហ៊ួន អាយុ៤៣ឆ្នាំ

កើតនៅភូមិព្រែកជ្រៅ (ឃុំមិនចាំ) ស្រុកថាច់ហ៊ឹង ខេត្តពលលាវ កម្ពុជាក្រោម ។

◆ ក្នុងឆ្នាំ១៩៥៦ គាត់បានទឹងឪពុកម្តាយ រត់ពីកម្ពុជាក្រោម មកនៅភ្នំពេញ

◆ ក្នុងឆ្នាំ១៩៥៧ គាត់បានទៅនៅជាមួយ ត្រឹង ង៉ា នៅបាត់ដំបង

◆ ក្នុងឆ្នាំ១៩៦០ គាត់រៀបការជាមួយមិត្តរបស់ ត្រឹង ង៉ា ឈ្មោះ ថាច់ ថន

២) ត្រឹង ង៉ា

៣) ត្រឹង ថាញ់ ស្លាប់កាលពីអាយុ៩ឆ្នាំ

**ច) អំពីកូនបង្កើតរបស់ ត្រឹង ង៉ា ៖** មានចំនួន៤នាក់

១) ត្រឹង បញ្ញារិទ្ធិ ភេទប្រុស អាយុ១៦ឆ្នាំ រៀនថ្នាក់ទី៧

២) ត្រឹង សុគន្ធាវ៉ារី ភេទស្រី អាយុ១៥ឆ្នាំ រៀនថ្នាក់ទី៨

៣) ត្រឹង បញ្ញារុណ ភេទប្រុស អាយុ៨ឆ្នាំ រៀនថ្នាក់ទី៩

៤) ត្រឹង សុន្តារា ភេទប្រុស អាយុ៧ឆ្នាំ រៀនថ្នាក់ទី១១

កូនទាំងអស់នៅក្នុងបន្ទុកឪពុកម្តាយ

**ចំណុចដែលសាមីខ្លួនសារភាព**

**ក) ការអនុវត្ត ៖**

១) នៅក្នុងឆ្នាំ១៩៧៥ ត្រឹង ង៉ា បានទទួលផែនការក្បត់សម្រាប់ប្រឆាំងខ្មែរក្រហមពីវរសេនីយ៍ឯក ដាញ់ វឌ្ឍនា ។ កន្លែងទទួលផែនការវិទ្យាស្ថានខ្មែរ មន ។

២) បក្សពួកដែលទទួលផែនការ មាន ទី១) យឹម កែវ អាយុប្រមាណ៣៥ឆ្នាំ ធ្វើគ្រូបង្រៀន ទី២) ម៉ែន រស់ អាយុប្រមាណ៤៥ឆ្នាំ គ្រូបង្រៀន ទី៣) កោ ខែមម៉ារី អាយុ២២ឆ្នាំ នៅលីវ ទី៤) ត្រឹង ង៉ា

៣) ខ្លឹមសារ ដាញ់ វឌ្ឍនា ណែនាំ ៖

◆ ទោះបីភ្នំពេញយើងចាញ់ខ្មែរក្រហមក៏ដោយ ក៏សាធារណរដ្ឋខ្មែរយើងពុំព្រមចុះចាញ់ខ្មែរក្រហមដែរ ។

◆ យើងត្រូវប្រឆាំងខ្មែរក្រហមវិញដាច់ខាត ព្រោះសព្វថ្ងៃយើងមានគម្រោងវាយបកខ្មែរក្រហមវិញ ដោយមានសឹង ង៉ុកថាញ់ និងកងទ័ព ចាន់ រង្សី ។

◆ ត្រូវតែខំបំផុសបំផុលរាស្ត្រ និងរដ្ឋការគ្រប់ផ្នែក ។

**១) អំពីផែនការ ដាញ់ វឌ្ឍនា ស័ក្តិ៥**

◆ ឲ្យបំផុសប្រជារាស្ត្រ និងរដ្ឋការទូទៅឲ្យស្រឡាញ់របបសាធារណរដ្ឋ កុំឲ្យជឿការឃោសនារបស់ខ្មែរក្រហម ហើយត្រៀមប្រឆាំងខ្មែរក្រហម នៅពេលណាកងទ័ព សឹង ផ៉ុកថាញ់ និងកងទ័ព ចាន់ រង្សី ព័ទ្ធខ្មែរក្រហមពីក្រៅ ។

◆ ឲ្យចាត់តាំងដៃដើងបន្ត សម្រាប់ជួយអនុវត្តផែនការក្បត់ ។

◆ ចាំពិនិត្យចំណុចខ្សោយរបស់ខ្មែរក្រហម ដើម្បីឆ្កឹះឡើងឲ្យរាស្ត្រស្អប់ ។

**ត្រឹង ឆា បានអនុវត្តផែនការចំនួនបីគឺ**

១) ការអនុវត្តដោយវិធីឃោសនា ។

២) បំផុសបំផុលពីចំណុចខ្សោយរបស់ខ្មែរក្រហម ដូចជាឲ្យស៊ីអង្ករខាំ, ឲ្យស៊ីមិនគ្រប់គ្រាន់, ប្រើបង្ខំដូចគោ ក្របី, បំបិទសិទ្ធិសេរីភាព ។

៣) ចលនាបំផុស ច្រើនធ្វើនៅវាលស្រែ ស្ទូងដក ។

**អ្នកដែល ត្រឹង ឆា អប់រំ**

១) ឈ្មោះ រស់ អាយុប្រមាណ៤០ឆ្នាំ ធ្វើគ្រូបង្រៀន

២) ឈ្មោះ គិន អាយុប្រមាណ៣៥ឆ្នាំ ថៅកែលក់ដូរថ្មពិលភ្នំពេញ ។

៣) ឈ្មោះ មុយ អាយុប្រមាណ៤៥ឆ្នាំ ថៅកែស៊ីក្លូពីសង្គមចាស់ ។

៤) ឈ្មោះ សែម អាយុប្រមាណ៣៥ឆ្នាំ ជាងជួសជុលវិទ្យុ ។ **សោម ប៊ុនថន**

# ខ្សែភាពយន្តឯកសាររឿង “ក្បង់ទឹកទន្លេ”



“ក្បង់ទឹកទន្លេ” គឺជាខ្សែភាពយន្តឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលទទួលបានការគាំទ្រ និងទិដ្ឋាការពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ ភាពយន្តឯកសារនេះក៏ទទួលបានពានរង្វាន់លំដាប់ពិភពលោក នៅសហរដ្ឋអាមេរិក នៅក្នុងឆ្នាំ២០១៣ ។ “ក្បង់ទឹកទន្លេ” បង្ហាញនូវដំណើរជីវិតមួយដ៏វិសេសវិសាលនិងមិនធ្លាប់មានពីមុនមក ដែលផ្តើមចេញពីតំបន់ជនបទចុងកាត់មាត់ញក ព្រៃភ្នំ និងភូមិនេសាទនៅលើផ្ទៃទឹករបស់តួអង្គទាំងបី ។ សាវ សាម្ងួន រស់នៅកណ្តាលព្រៃភ្នំដាច់ស្រយាលនៃភាគឦសានប្រទេសកម្ពុជា ។ ម៉ុក ខៀវ ដើម្បីរកលុយសងបំណុល ត្រូវបង្ខំចិត្តមកធ្វើការនៅរោងចក្រនៅភ្នំពេញ ។ សារី ម៉ាត់ ដើម្បីសម្រួលបន្ទុកគ្រួសារត្រូវឈប់រៀនមកជួយនេសាទត្រីឪពុក ។ ខ្សែភាពយន្តឯកសារនេះមានចាក់បញ្ចាំងជូនរាល់ថ្ងៃសុក្រនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។

ព័ត៌មានបន្ថែមសូមទាក់ទងកញ្ញា សា ហ្វាទីលី តាមរយៈទូរស័ព្ទលេខៈ ០១២ ៥១១ ៩១៤

អ៊ីម៉ែល : *truthfatily.s@dccam.org* គេហទំព័រ : *www.ariverchangescourse.com*

# យុវជន យុវនារីបដិវត្តន៍ប្តេជ្ញាវាយសម្រុករដូវវស្សានេះ ឱ្យខ្លាំងក្លាបំផុតដើម្បីសម្រេច៣តោន ១ហិចតា ឱ្យបានដាច់ខាត

***ដកស្រង់ចេញពីសៀវភៅ យុវជន និងយុវនារីបដិវត្តន៍នៃកម្ពុជាប្រជាធិបតេយ្យលេខ៥ ខែឧសភា ឆ្នាំ១៩៧៦***

ក្រោយរំដោះប្រទេសជាតិ និងរំដោះប្រជាជនកម្ពុជាបានទាំងស្រុងជាស្ថាពរហើយ ប្រជាជនកម្មករ កសិករ និងយុវជនយុវនារីកម្ពុជាយើងមានភារកិច្ចការពារប្រទេស និងកសាងប្រទេសឲ្យបានរឹងប៉ឹងខ្លាំងពូកែក្តុំក្តើងរុងរឿងឆាប់រហ័សបំផុតទៅតាមទិសថ្មីនៃបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយមរបស់បក្សដាច់ខាត ។

ក្នុងរយៈពេលពេញមួយឆ្នាំកន្លងទៅ យុវជនយុវនារីកម្ពុជាក្រោមការដឹកនាំដ៏ត្រឹមត្រូវ និង ភ្លឺស្វាងនៃបក្សកុម្មុយនីស្តកម្ពុជាបានរួបរួមសាមគ្គីយ៉ាងជិតស្និទ្ធជាធ្លុងមួយជាមួយប្រជាជនកម្មករកសិករទូទាំងប្រទេស ខិតខំវាយសម្រុកបំពេញភារកិច្ចបដិវត្តន៍រៀងៗខ្លួន ដែលបក្សប្រគល់ឲ្យយ៉ាង សស្រាក់សស្រាំខ្លាំងក្លាបំផុត មិនថាថ្ងៃឬយប់ឡើយ រួមចំណែកយ៉ាងសកម្មក្នុងកិច្ចការពារប្រទេស និងកិច្ចកសាងប្រទេសដណ្តើមជ័យជម្នះធំៗថ្មីទៀតជាបន្តបន្ទាប់ ។ អាស្រ័យហេតុនេះហើយ បានជាក្នុងរយៈតែមួយឆ្នាំក្រោយសង្គ្រាមវិនាសកម្មយើងអាចឧបត្ថម្ភខ្លួន ដោយឯករាជ្យ ម្ចាស់ការ បានជាមូលដ្ឋាន ។ ក្នុងរយៈពេលមួយឆ្នាំកន្លងទៅនេះ យើងការពារប្រទេសក៏បានល្អប្រសើរ ហើយកសាងប្រទេសក៏បានលឿនលោតផ្លោះលើគ្រប់ផ្នែក បើប្រៀបធៀបទៅនឹងទុនដ៏ខ្សត់ខ្សោយដែលយើងមាន ។ យើងទាំងអស់គ្នាសប្បាយរីករាយ ហើយមានមោទកភាពបដិវត្តន៍យ៉ាងត្រឹមត្រូវចំពោះជ័យជម្នះដ៏ធំធេងថ្មីនេះ ដែលយើងទទួលបានក្នុងរយៈមួយឆ្នាំកន្លងទៅ ប៉ុន្តែភារកិច្ចការពារ កសាងប្រទេសរបស់យើងនៅវែងឆ្ងាយ នៅធ្ងន់ធ្ងរច្រើនតទៅទៀត ។ ឯជ័យជម្នះដែលយើងទទួលបានក្នុងមួយឆ្នាំកន្លងទៅនេះ ទោះបីជាមានទំហំធំប៉ុណ្ណា ទោះបីជាមានលក្ខណៈលោតផ្លោះលឿនយ៉ាងណា ក៏គ្រាន់តែជាជ័យជម្នះជំហានដំបូងមួយប៉ុណ្ណោះ ។

ដូច្នេះដើម្បីការពារប្រទេស និងកសាងប្រទេសឲ្យបានរឹងប៉ឹង ខ្លាំងក្លា និងក្តុំក្តើងរុងរឿងឆាប់រហ័ស សមស្របតាមពាក្យស្លោករបស់បក្សដែលថា "មហាលោតផ្លោះ មហាអស្ចារ្យ" នោះ យើងទាំងអស់គ្នាចាំបាច់ត្រូវវាយសម្រុកឲ្យខ្លាំងក្លាបំផុត និងជាប់ជានិច្ចជាបន្តទៀត ។


កងយុវជនដែលជាសសរទ្រូងរបស់បដិវត្តន៍កំពុងជីកប្រឡាយក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

នៅឆ្នាំ១៩៧៦នេះ បក្សបានលើកទិសជំរុញចលនាបង្កបង្កើនផលស្រូវឲ្យបានបីតោនក្នុងមួយហិចតា គិតជាមធ្យម និងជាទូទៅពេញទាំងប្រទេសកម្ពុជា ។

តើបីតោនមួយហិចតា ឆ្នាំ១៩៧៦នេះមានន័យយ៉ាងណាខ្លះ?

បីគោនមួយហិចតា នៅឆ្នាំ១៩៧៦នេះ មិនមែនមានន័យត្រឹមតែសេដ្ឋកិច្ចប៉ុណ្ណោះទេ តែវាមានន័យយុទ្ធសាស្ត្ររបស់វា ។ ពោលគឺ បីតោនមួយហិចតា ដើម្បីការពារប្រទេស ។ បីតោនមួយហិចតា ដើម្បីដោះស្រាយជីវភាពប្រជាជន ។ បីតោនមួយហិចតាដើម្បីកសាងប្រទេសឲ្យបានឆាប់រហ័ស ។ បីតោនមួយហិចតាដើម្បីប្រមូលកម្លាំងមិត្តលើសកលលោកឲ្យបានច្រើន ។ បីតោនមួយហិចតាដើម្បីបដិវត្តន៍យើងជាគំរូក្នុងបដិវត្តន៍សកលលោក ។

ក្នុងឆ្នាំ១៩៧៦នេះ បើយើងសម្រេចទិសដៅបីតោនមួយហិចតាបានជាបឋម គឺយើងមានស្បៀងបរិបូរណ៍ ដើម្បីដោះស្រាយ និងលើកស្ទួយជីវភាពប្រជាជនយើងឲ្យកាន់តែរីកចម្រើនធូរធារឡើងថែមទៀត ។ ប្រជាជនយើងនឹងមានជីវភាពរស់នៅធូរធារ មានស៊ីចុកឆ្អែតគ្រប់គ្រាន់ មានសុខភាពល្អ និងមានកម្លាំងពលំមាំទាំ សម្រាប់វាយសម្រុកបង្កបង្កើនផលនៅឆ្នាំតៗទៅមុខទៀត បានកាន់តែខ្លាំងក្លាឡើងជាលំដាប់ ។ ដូច្នេះប្រជាជនយើងសប្បាយរីករាយពេញចិត្តពេញថ្លើម មានការរកក់ក្តៅ និងជំនឿជឿជាក់លើរបបបដិវត្តន៍ថ្មីនេះ ។ ដូច្នេះទោះបីខ្មាំងឃោសនា មួលបង្កាច់ ប្តុញុះញង់ បំបែកបំបាក់យ៉ាងណា ក៏គ្មានប្រសិទ្ធភាពដែរ ព្រោះប្រជាជនជឿជាក់លើរបបថ្មីនេះថា ល្អ ត្រឹមត្រូវ ស្អាតស្អំ បម្រើ និងការពារផលប្រយោជន៍ដ៏ពិសិដ្ឋរបស់ខ្លួនមែន ។ គេជឿជាក់ ព្រោះគេឃើញផ្ទាល់នឹងភ្នែក ថាការដែលគេខំបញ្ចេញកម្លាំងកាយចិត្ត វាយសម្រុកលើកប្រព័ន្ធភ្លឺ និងជីកប្រឡាយថ្មីក្តី ឬវាយសម្រុកបង្កបង្កើនផលក្តី គឺពិតជាពុំមែនដើម្បីនរណា ពុំមែនដើម្បីវណ្ណៈណាមួយឡើយ តែគឺពិតជាដើម្បីកែប្រែ និងកសាងជនបទថ្មី កសាងប្រទេស និងដើម្បីលើកស្ទួយជីវភាពប្រជាជនខ្លួនឯងពិតប្រាកដ ហើយព្រមជាមួយគ្នានេះ គេឃើញផលបានច្រើន ហើយគេទទួលផលនេះ ដោយផ្ទាល់ដៃគេតែម្តង ។ ការពេញចិត្ត ពេញថ្លើម និងជំនឿជឿជាក់យ៉ាងមុតមាំលើរបបថ្មីនេះរបស់ប្រជាជនយើង ជាកម្លាំង ខ្លាំងក្លាមហិមាណាស់ គ្មានអ្វីអាចរាំងស្កាត់ទប់បានឡើយ ។ កម្លាំងប្រជាជននេះ អាចការពារប្រទេស ក៏បានរឹងប៉ឹង ខ្លាំងក្លា និងល្អប្រសើរ កសាងប្រទេសក៏មានសន្ទុះផុលផុសខ្លាំងក្លា ហើយលឿនលោតផ្លោះទៀត ។

តាមរយៈការដោះស្រាយ និងលើកស្ទួយជីវភាពប្រជាជនឲ្យបានកាន់តែល្អប្រសើរឡើងនេះ បីតោនមួយហិចតា វាមានន័យការពារប្រទេស និងកសាងប្រទេសនៅក្នុងនេះស្រេចទៅហើយ ។

ន័យទីពីរ បានសេចក្តីថា បើក្នុងឆ្នាំ១៩៧៦នេះ យើងសម្រេចទិសដៅ បីតោនមួយហិចតា បានជោគជ័យនោះយើងនឹងមានទុនម្យ៉ាងសម្រាប់វាយសម្រុកនៅឆ្នាំ១៩៧៧-៧៨ តទៅមុខទៀតបានកាន់តែខ្លាំងក្លា ។ ហើយម្យ៉ាងទៀត ដោយយើងមានស្រូវច្រើនដឹកទៅលក់នៅបរទេសនោះ យើងនឹងមានទុនទិញគ្រឿងចក្រ និងប្រដាប់ប្រដាចាំបាច់ផ្សេងៗ មកពង្រឹងពង្រីកកសិកម្ម និងឧស្សាហកម្ម កសាងប្រទេសយើងបានកាន់តែឆាប់រហ័សផង ។

ន័យទីបី បើយើងសម្រេចបីតោនមួយហិចតាក្នុងឆ្នាំ១៩៧៦នេះបាន យើងនឹងមានស្រូវច្រើនដឹកនាំចេញទៅបរទេស ។ ការនេះនឹងធ្វើឲ្យសកលលោកមានការភ្ញាក់ផ្អើលខ្លាំង ។ តាមរយៈនេះ សកលលោកនឹងឃើញច្បាស់ថា ប្រទេសកម្ពុជាជាប្រទេសក្រីក្រ ហើយតូចមែនពិត តែប្រជាជនកម្ពុជាក្រោមការដឹកនាំដ៏ត្រឹមត្រូវរបស់បក្សកុម្មុយនីស្តកម្ពុជាមានវីរភាពអង់អាចក្លាហានបំផុត ហើយនឹងមានសមត្ថភាពខ្ពង់ខ្ពស់ណាស់ ក្នុងការវាយចក្រពត្តិ និងបរិវារ ក៏ដូចជាក្នុងការកសាង និងការពារប្រទេសដែរ ។ ក្នុងរយៈតែពីរឆ្នាំក្រោយសង្គ្រាមវិនាសសកម្ម ប្រជាជនកម្ពុជាមិនគ្រាន់តែអាចឧបត្ថម្ភខ្លួន ដោយឯករាជ្យ ម្ចាស់ការទាំងស្រុង អាចការពារប្រទេស ដោយខ្លួនឯង បានល្អប្រសើរប៉ុណ្ណោះទេ តែប្រជាជនកម្ពុជានៅបានផលិតស្រូវជាច្រើនសម្រាប់ហូប និងដឹកចេញទៅបរទេសទៀត ។ ការនេះនឹងធ្វើឲ្យប្រជាជនសកលលោក ហើយពិសេស ប្រទេសជាមិត្តជិតឆ្ងាយនៅលើសកលលោកទាំងមូល គោរពស្ញប់ស្ញែង កោតសរសើរចំពោះកម្ពុជាយើងជាខ្លាំង ។ ប្រទេសក្រីក្រ និងប្រទេសក្នុងលោកទីបី ទាំងអស់នឹងយកកម្ពុជាធ្វើជាគំរូ គំរូក្នុងការវាយចក្រពត្តិអាមេរិក រំដោះប្រទេសជាតិខ្លួន ហើយគំរូក្នុងការកសាងប្រទេសដោយគោលជំហរឯករាជ្យ ម្ចាស់ការ ខ្លួនឧបត្ថម្ភខ្លួនខ្ពស់បំផុតទៀត ។ ដូច្នេះប្រជាជនសកលលោក និងប្រទេសជាមិត្តជិតឆ្ងាយក្នុងសកលលោកទាំងមូល កាន់តែមានសមានចិត្តចំពោះយើង ហើយឧបត្ថម្ភគាំទ្រយើងនៅលើឆាកអន្តរជាតិកាន់តែខ្លាំងក្លា កាន់តែសកម្មថែមទៀត ។ តាមរយៈ បីតោនមួយហិចតា មានន័យការពារប្រទេសផង លើកស្ទួយអត្តភាព កិត្តិយសជាតិយើងផង ប្រជាជាតិ ប្រជាជនបដិវត្តន៍ និងបក្សកុម្មុយនីស្តកម្ពុជាឲ្យលេចត្រដែតត្រដឹម ទាំងក្នុង

ប្រទេស ទាំងនៅលើឆាកអន្តរជាតិទាំងមូលផង ។

ដូច្នេះសរុបមកវិញ បីគោនមួយហិចតា មានន័យជាយុទ្ធសាស្ត្រ ការពារប្រទេសបានរឹងប៉ឹងល្អប្រសើរផង កសាងប្រទេសបានលឿនផង ហើយលើកស្ទួយអត្តភាព និងកិត្តិយសជាតិខ្ពស់ត្រដែតត្រដឹមទាំងនៅក្នុងប្រទេស ទាំងនៅលើឆាកអន្តរជាតិផង ។

ដោយជ្រួតជ្រាប និងក្តាប់ជាប់នូវអត្ថន័យជាយុទ្ធសាស្ត្រនៃបីគោនមួយហិចតារបស់បក្សឆ្នាំ១៩៧៦ យ៉ាងច្បាស់លាស់ដូចពោលខាងលើនេះ យុវជន យុវនារីកម្ពុជាយើងប្តេជ្ញាវាយសម្រុក រដូវវស្សានេះឲ្យខ្លាំងក្លាបំផុត និងជាប់ជានិច្ច រួមចំណែកសម្រេចទិសដៅបីគោនមួយហិចតាឲ្យបានដាច់ខាត ។

ជាក់ស្តែងនៅតាមសហករណ៍ និងតាមមូលដ្ឋាននានាទូទាំងប្រទេស យុវជនយុវនារីបដិវត្តន៍ យើងប្តេជ្ញាចុះប្រឡូកឲ្យជាប់ជិតស្និទ្ធជាមួយប្រជាជនសហករណ៍ក្នុងមហាចលនាត្រៀមរៀបចំវាយសម្រុករដូវវស្សា និងក្នុងមហាចលនាវាយសម្រុកបង្កបង្កើនផលរដូវវស្សានេះឲ្យបានខ្លាំងក្លាបំផុត ។

ជាក់ស្តែង យុវជនយុវនារីបដិវត្តន៍យើងត្រូវយកចិត្តទុកដាក់ឲ្យអស់ពី លទ្ធភាព និងសមត្ថភាព ជួយដោះស្រាយរកពូជធាល្អៗដែលផ្លែច្រើន ជួយរកជី ប្រមែប្រមូលសន្សំជី ជួយពិសោធន៍ស្រាវជ្រាវ ធ្វើជីធម្មជាតិផ្សេងៗឲ្យបានច្រើនបំផុត និងកាន់តែមានប្រសិទ្ធភាពខ្ពស់ឡើងជានិច្ច រួមពិសោធន៍ធ្វើថ្នាំកំចាត់សត្វល្អិត រួមដាក់ស្តែងតាមគ្រប់វិធីក្នុងការកំចាត់សត្វល្អិត ការពារផលដំណាំឲ្យបានជាអតិបរមា ។ ក្រៅពីនេះ យុវជន យុវនារីបដិវត្តន៍យើងត្រូវចុះប្រឡូក គិតគូរ ជួយដោះ ស្រាយបញ្ហាទឹកឲ្យម្ចាស់ការកម្រិតខ្ពស់ក្នុងពេលរាំងស្ងួត ក៏ដូចជាពេលមានទឹកជំនន់ធំ ។ កាលពីរដូវប្រាំងយុវជន យុវនារីបដិវត្តន៍យើងបានចុះប្រឡូកយ៉ាងពេញទំហឹងជាមួយប្រជាជនសហករណ៍ក្នុងគ្រប់ការដ្ឋាន វាយសម្រុកលើកប្រព័ន្ធភ្លឺថ្មីនិងជីកប្រឡាយយ៉ាងសស្រាក់សស្រាំ ទាំងយប់ទាំងថ្ងៃ រហូត ដល់បានសម្រេចផែនការរដូវប្រាំងនេះដោយជោគជ័យ ។ នេះក៏ជាការរួមចំណែកដោះស្រាយបញ្ហាទឹកជូនប្រជាជនសហករណ៍បង្កបង្កើនផលដែរ ។ ឥឡូវរដូវវស្សាចូលមកដល់ហើយ ភ្លៀងចាប់ផ្តើមធ្លាក់ជាបន្តបន្ទាប់ ប៉ុន្តែយើងពុំអាចម្ចាស់ការលើបញ្ហាភ្លៀងនេះបានឡើយ ព្រោះពេលខ្លះក៏មានភ្លៀងច្រើន ពេលខ្លះក៏មានភ្លៀងតិច ហើយពេលខ្លះទៀតក៏អត់ភ្លៀងជាយូរថ្ងៃ ។ នៅកន្លែងខ្លះ ខ្វះទឹកភ្លៀង ហើយនៅកន្លែងខ្លះទៀតភ្លៀងច្រើនពេក រហូតដល់បណ្តាលឲ្យមានទឹកជំនន់លិចលង់ ខូចខាតអន្តរាយផលដំណាំ អស់ក៏មានដែរ ។ អាស្រ័យហេតុនេះហើយ បានជាថាយើងត្រូវម្ចាស់ការលើបញ្ហាទឹកគ្រប់ពេលវេលា ។ ម្ចាស់ការម្យ៉ាង ដោយយុវជនយុវនារីយើងចាត់តាំងកម្លាំងជួយឃាមកាមថែទាំប្រព័ន្ធសំណង់ទឹកដែលមានហើយ កុំឲ្យវាបាក់ វាស្រុត ឬធុះធ្លាយ ហូរហៀរទឹកចោលអសារឥតការ ។ ពេលមានភ្លៀង កម្លាំងយុវជន យុវនារីយើងត្រូវរៀបចំទប់ទឹកឲ្យដក់ជាប់ក្នុងទំនប់ប្រឡាយ ភ្លឺ កុំឲ្យទឹកមួយដំណក់ហូរចេញទៅទន្លេបាន ។ បើកន្លែងណាទឹកច្រើនពេក ត្រូវបង្ហូរបញ្ចូលទៅស្រែដែលមិនសូវមាន ។ ដូច្នេះពេលមានភ្លៀង កម្លាំងយុវជនយុវនារីយើងត្រូវត្រៀមចាំប្រយុទ្ធជាប់នៅលើសមរភូមិស្រែធ្វើយ៉ាងណាការពារទឹក ទប់ទឹក រក្សាទឹកឲ្យជាប់ក្នុងស្រែ ។ ពេលរាំងស្ងួត ក៏យុវជន យុវនារី យើងត្រូវចុះប្រឡូកជួយធាក់ទឹកបាចទឹកបញ្ចូលស្រែ ប្រឡាយចិញ្ចឹមសំណាប សន្ទូងឲ្យបានគ្រប់គ្រាន់ ឬជួយចាត់ចែងបើកទំនប់ ជីកប្រឡាយនាំទឹកពីអាងមកបញ្ចូលស្រែឲ្យបានទាន់ពេលវេលា ។ ក្រៅពីនេះ យុវជន យុវនារីយើង ត្រូវរួមដោះស្រាយបញ្ហាស្បៀងឲ្យប្រជាជនសហករណ៍យើងបានហូបឆ្អែតគ្រប់គ្រាន់មានកម្លាំងវាយសម្រុកធ្វើស្រែវស្សានេះបានពេញទំហឹង ។ ម្យ៉ាងយុវជន យុវនារី យើងជួយរកត្រីសាច់ បន្លែបង្ការឧបត្ថម្ភសហករណ៍រួមចំណែកធ្វើស្រូវស្រាលឲ្យបានច្រើនគ្រប់ទីកន្លែងចលនាដាំពោតដំឡូង សណ្តែក ដើម្បីដោះស្រាយ និងកែប្រែជីវភាពប្រជាជនសហករណ៍យើងកុំឲ្យដាច់ស្បៀងក្នុងពេលកំពុងវាយសម្រុកខ្លាំង ។ ម្យ៉ាងទៀតយុវជន យុវនារីយើងត្រូវយកចិត្តទុកដាក់ជួយថែទាំទុកដាក់មើលអស់មើលគង់ និងសន្សំសំចៃខ្ពស់បំផុតទាំងស្បៀងអាហារ ទាំងរបស់របរ ទ្រព្យសម្បត្តិរួមរបស់អង្គការឲ្យបានគត់មត់ល្អជាអតិបរមា ។ ព្រមជាមួយនេះ យុវជនយុវនារីយើងក៏ត្រូវចុះប្រឡូកវាយសម្រុកឲ្យអស់ពីកម្លាំងចិត្តកាយ ភ្លូរពាស់ សាបព្រោះ ដក ស្ទូង ឲ្យខ្លាំងក្លាជានិច្ច ។

នេះជាការរួមចំណែកវាយសម្រុកខ្លាំងក្លាបំផុត នៅរដូវវស្សានេះរបស់យុវជនយុវនារីយើង ដើម្បីសម្រេចទិសដៅបីគោនមួយហិចតាឲ្យបានជោគជ័យទាំងស្រុង ។ ខាងរោងចក្រឧស្សាហកម្មនានា

យុវជន យុវនារីយើង ត្រូវវាយសម្រុកផលិតឧបករណ៍កសិកម្មផ្សេងៗ ជាម៉ាស៊ីនបូមទឹកក្ដី ជាម៉ាស៊ីនបោកបែនស្រូវក្ដី ជាចប ផាល កាំបិត ផ្គាក់ ពូថៅក្ដី ឲ្យបានលឿនឆាប់រហ័សឲ្យបានច្រើន និងមានគុណភាពជាប់ល្អដើម្បីបម្រើសំណូមពរផលិតកម្មកសិកម្មឲ្យបានជាអតិបរមា ។ ព្រមជាមួយនេះ យុវជន យុវនារីកម្មករយើង ក៏ត្រូវវាយសម្រុកបង្កើនផលិតផលជារបស់របរប្រើប្រាស់ចាំបាច់ផ្សេងៗឲ្យបានច្រើនដើម្បីបម្រើដោះស្រាយ និងកែប្រែជីវភាពសហករណ៍យើងឲ្យកាន់តែចម្រើនធូរធារ ។

ចំណែកយុវជន យុវនារីយើង ខាងស្រែអំបិលត្រូវវាយសម្រុកត្រៀមរៀបចំពង្រីងស្រែអំបិលឲ្យបានកាន់តែធំ កាន់តែល្អសម្រាប់បង្កើនផលអំបិលនៅឆ្នាំ១៩៧៦នេះ ឲ្យបានច្រើនបំផុតប្រមូលទុកដាក់ ថែទាំ និងការពារអំបិលក្នុងឃ្លាំងដែលមានហើយឲ្យបានគត់មត់ល្អសម្រាប់ផ្ដល់ជូនប្រជាជនសហករណ៍យើងឲ្យបានហូបគ្រប់គ្រាន់ ។

ផ្នែកខាងយុវជន យុវនារីកំពង់ផែ និងដឹកជញ្ជូននានាត្រូវវាយសម្រុកលើកដាក់ លីសែង ឲ្យបានច្រើនឲ្យបានឆាប់រហ័សបំផុតដើម្បីបម្រើការវាយសម្រុកធ្វើស្រែរដូវវស្សានេះ ឲ្យបានខ្លាំងក្លា និងទាន់ពេលវេលា ។

រីឯយុវជនយុវនារីតាមមន្ទីរ ក្រសួងនានាត្រូវវាយសម្រុកបំពេញភារកិច្ចស្នូល ភារកិច្ចបច្ចេកទេសផ្សេងៗរបស់ខ្លួនឲ្យបានខ្លាំងក្លា និងប្រសើរបំផុត រួមចំណែកជំរុញចលនាវាយសម្រុករដូវវស្សានេះឲ្យបានខ្លាំងក្លាបំផុត ។

ខាងផ្នែកយុវជន យុវនារីពេទ្យ និងសង្គមកិច្ចក៏ត្រូវវាយសម្រុកធ្វើថ្នាំ ទាំងថ្នាំសម័យ ទាំងថ្នាំ បូរាណ ឲ្យបានច្រើន ឲ្យបានលឿន និងមានប្រសិទ្ធភាពកាន់តែខ្ពស់ ទុកព្យាបាល និងថែរក្សាសុខភាពប្រជាជនសហករណ៍យើង កុំឲ្យឈឺច្រើនដើម្បីមានកម្លាំងពលំមាំទាំវាយសម្រុករដូវវស្សានេះបានខ្លាំងក្លាជាប់ជានិច្ច ។ ចំណែកយុវជន យុវនារីពេទ្យ នៅតាមមន្ទីរពេទ្យនានា ត្រូវយកចិត្តទុកដាក់បំរើអ្នកជំងឺ ថែទាំ និងព្យាបាលអ្នកជំងឺឲ្យបានល្អ ដោយស្មារតីទទួលខុសត្រូវខ្ពស់ធ្វើយ៉ាងណាឲ្យអ្នកជំងឺយើងឆាប់ជាសះស្បើយ មានកម្លាំងត្រឡប់ទៅវាយសម្រុករដូវវស្សានេះបានទាន់ពេលវេលា ។

រីឯយុវជនយុវនារីនៃកងទ័ពបដិវត្តន៍យើង ម្យ៉ាងត្រូវលើកកម្ពស់ស្មារតីប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់ជាប់ជានិច្ច ត្រៀមប្រយុទ្ធការពារព្រំដែនទឹក គោក សមុទ្រ កោះ និងផ្ទៃក្នុងប្រទេសឲ្យបានរឹងប៉ឹង និងល្អប្រសើរបំផុត ដើម្បីធានាសន្តិសុខឲ្យប្រជាជនសហករណ៍យើងវាយសម្រុករដូវវស្សានេះបានខ្លាំងក្លាគ្រប់ពេលវេលា ហើយម្យ៉ាងទៀត យុទ្ធជន យុទ្ធនារីនៃកងទ័ពបដិវត្តន៍យើង ក៏ចាំបាច់ត្រូវចុះប្រឡូកធ្វើស្រែជាមួយប្រជាជនសហករណ៍យើងនៅតាមគ្រប់មូលដ្ឋានឃុំ ភូមិ ស្រែ ដែលនៅជិតទីតាំងអង្គភាព ។

នេះជាភារកិច្ចជាក់ស្ដែងរបស់យុវជន យុវនារីយើងដើម្បីរួមចំណែកវាយសម្រុករដូវវស្សានេះឲ្យបានខ្លាំងក្លាបំផុតឈានទៅសម្រេចទិសដៅបីតោនមួយហិចតាដាច់ខាត ។

យើងមានលទ្ធភាពសម្រេចទិសដៅបីតោនមួយហិចតាឆ្នាំ១៩៧៦នេះបានពេញទី ព្រោះម្យ៉ាង យើងមានបក្សដឹកនាំចុះជាប់ជិតស្និទ្ធនឹងមូលដ្ឋាន តាមមាគ៌ាត្រឹមត្រូវ និងភ្លឺស្វាង ។ ម្យ៉ាងទៀត យុទ្ធជន យុទ្ធនារី កម្មាភិបាលបដិវត្តន៍ និងប្រជាជនកម្មករ កសិករយើងជ្រួតជ្រាបមាគ៌ារបស់បក្ស ជ្រួតជ្រាបអំពីអត្ថន័យជាយុទ្ធសាស្ត្រនៃផែនការបីតោនមួយហិចតាយ៉ាងច្បាស់លាស់ ហើយមានសេចក្ដីប្ដេជ្ញាចិត្តខ្ពស់ សម្រេចទិសដៅបីតោនមួយហិចតានេះឲ្យបានជោគជ័យទាំងស្រុង ហើយម្យ៉ាងទៀតយើងក៏មានការត្រៀមរៀបចំលក្ខណៈសម្បត្តិគ្រប់បែបយ៉ាងឲ្យម្ចាស់ការជាមុនស្រេច ដើម្បីវាយសម្រុកយកបីតោនមួយហិចតាឲ្យបានដាច់ខាត ។

យុវជន យុវនារីបដិវត្តន៍យើងក៏ប្ដេជ្ញាខ្ពស់ ធ្វើពលីកម្មគ្រប់បែបយ៉ាង ពុះពារឧបសគ្គតូច-ធំ និងការលំបាកសព្វមុខចុះប្រឡូកយ៉ាងជាប់ជិតស្និទ្ធជាមួយប្រជាជនសហករណ៍វាយសម្រុកបំពេញភារកិច្ចបដិវត្តន៍គ្រប់បែបយ៉ាងឲ្យបានខ្លាំងក្លាបំផុត និងជាប់ជានិច្ចក្នុងរដូវវស្សានេះ ដើម្បីរួមចំណែកវាយផ្ដាច់យកបីតោនមួយហិចតា ក្នុងឆ្នាំ១៩៧៦នេះឲ្យបានដាច់ខាត ។ នេះជាភារកិច្ចស្នូលរបស់យុវជន យុវនារីកម្ពុជាយើងក្នុងរដូវវស្សានេះ ហើយក៏ជាកិត្តិយស និងជាសុភមង្គលដ៏ថ្លៃថ្លារបស់យុវជន យុវនារីបដិវត្តន៍យើងដែរ ។ សម្រេចបីតោនមួយហិចតាក្នុងឆ្នាំ១៩៧៦នេះ គឺជាអនាគតភ្លឺស្វាងរបស់ប្រទេសជាតិ និងបដិវត្តន៍កម្ពុជា ហើយក៏ជាអនាគតភ្លឺស្វាងរបស់យុវជនយុវនារីយើងគ្រប់រូបដែរ ។

# ជនជាតិភាគតិចក្រោល

ក្រោលគឺជាឈ្មោះជនជាតិភាគតិចមួយក្នុងចំណោមក្រុមជនជាតិភាគតិចចំនួនម្ភៃបួនផ្សេងទៀតក្នុងប្រទេសកម្ពុជា ។ ក្រុមជនជាតិទាំងនេះភាគច្រើនរស់នៅតំបន់ឦសាន មានដូចជាខេត្តស្ទឹងត្រែង ខេត្តរតនគិរី ខេត្តមណ្ឌលគិរី ខេត្តក្រចេះ និងខេត្តព្រះវិហារជាដើម ។ ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៣ ក្រុមការងារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានធ្វើការរៀបចំវេទិកាមួយនៅក្នុងឃុំស្រែជិះ ខេត្តក្រចេះ ជាកន្លែងដែលក្រុមជនជាតិភាគតិចទាំងនោះរស់នៅ ។ ជនជាតិក្រោលប្រហែលជាកៅសិបភាគរយរស់នៅក្នុងឃុំនេះ ។ គួរបញ្ជាក់ថា វេទិកានេះធ្វើឡើងគឺដើម្បីលើកទឹកចិត្តឲ្យអ្នកភូមិទាំងអស់ ចែករំលែកនូវរាល់បទពិសោធរឿងប្រវត្តិខ្មែរក្រហមទៅកាន់ក្មេងៗជំនាន់ក្រោយឲ្យបានដឹង និងការយល់ឃើញរបស់អ្នកភូមិទាំងអស់ទៅលើដំណើរការកាត់ទោសមេដឹកនាំជាន់ខ្ពស់នៅក្នុងរបបនោះ ។

គោលដៅសំខាន់ជាងគេរបស់របាយការណ៍នេះគឺផ្តល់សំឡេង មតិ និងការលើកទឹកចិត្តដល់ជនជាតិភាគតិច ។ ដើម្បីឲ្យគោលដៅនេះសម្រេចទៅបាន ជាដំបូងនៅក្នុងរបាយការណ៍នេះនឹងឆ្លុះបញ្ចាំងអំពីរឿងរ៉ាវសង្ខេបរបស់ក្រុមជនជាតិភាគតិចប្រវត្តិរូបរបស់ជនជាតិក្រោល និងបទពិសោធរបស់គេក្នុងអំឡុងពេលវៀតមិញ (សម្ព័ន្ធឯករាជ្យវៀតណាម) ឈ្លានពានមកពីវៀតណាមខាងជើង ។ ទាំងនេះគឺជាការផ្សាភ្ជាប់ទៅនឹងលទ្ធផលរបស់វេទិកាដែលមានការចូលរួមពីសំណាក់អ្នកភូមិប្រមាណជាពីររយនាក់ មកធ្វើការពិភាក្សាអំពីរឿងរ៉ាវប្រវត្តិសាស្ត្រខ្មែរក្រហមនិងការយល់ឃើញរបស់អ្នកទាំងនោះទៅលើចំណុចខ្លាំង និងចំណុចខ្សោយរបស់តុលាការខ្មែរក្រហម ។ ចុងក្រោយនៃរបាយការណ៍នេះចង់បង្ហាញអំពីការនាំយកបណ្តឹងខទូរណ៍របស់ជនជាតិក្រោលទៅកាន់រាជរដ្ឋាភិបាល ដើម្បីជួយអភិវឌ្ឍសហគមន៍ ។

## ប្រវត្តិរូប ៖ ដើមកំណើតជនជាតិក្រោល

ពឿន សារ៉ាយ ជាជនជាតិក្រោល ភេទប្រុស និងជាជំទប់



ស្ត្រីជនជាតិក្រោល ពរកូននៅខាងមុខផ្ទះ ស្ថិតនៅក្នុងភូមិស្រែជិះ ឃុំស្រែជិះ ស្រុកសំបូរណ៍ ខេត្តក្រចេះកាលពីខែកុម្ភៈ ឆ្នាំ២០១៣

ទីមួយ នៅក្នុងឃុំស្រែជិះ បានប្រាប់ថា យាយរបស់គាត់ប្រាប់គាត់ថាពាក្យ "ក្រោល" នេះ មានអត្ថន័យថា "ក្រោលសត្វ" ។ បើយោងទៅតាមរឿងរ៉ាវប្រវត្តិសាស្ត្រវិញ នៅពេលដែលមានការវាយប្រហារជាញឹកញាប់ពីពួកសៀម (ស្គាល់សព្វថ្ងៃថាជាជនជាតិថៃ) ជនជាតិក្រោលព្យាយាមរត់គេចខ្លួនពីទិសបូព៌ាមកកាន់ប្រទេសកម្ពុជា ដោយការធ្វើដំណើរតាមព្រៃស្តុក និងក្រាស់ៗ ។ ជនជាតិក្រោលភាគច្រើនរត់គេចខ្លួន ពីសៀមបានជោគជ័យតាមភ្នំបាំងថ្ងៃ ប៉ុន្តែក៏មានអ្នកមួយចំនួនត្រូវធ្លាក់ចូលក្នុងកណ្តាប់ដៃសត្រូវរបស់ខ្លួនដែរ ។ អ្នកដែលរស់នៅក្នុងព្រៃស្តុកទាំងនោះបន្សាំខ្លួនទៅនឹងជីវិតដែលគ្មានម្ហូបអាហារ និងសម្លៀកបំពាក់ត្រឹមត្រូវ ។ ដើម្បីរស់រានមានជីវិត គេញុំាដីប្រៃ ឬហៅថា ដីលខ្វាយ ហើយនឹងរស់នៅលើដើមឈើដូចជាបក្សាបក្សី ។ នៅខណៈពេលដែលគេរស់នៅក្នុងព្រៃ មានកងកម្លាំងមួយព្យាយាមនាំយកអ្នកទាំងនោះត្រឡប់ចូលទៅក្នុងសង្គមកម្ពុជាវិញ ។ គេបានដាក់ស្ករជានុយនៅក្បែរមែកឈើមួយ ហើយគេបានសង់ក្រោលមួយ ដូចជា ក្រោលសេះនៅក្នុងស្រុកកោះញែក ខេត្តមណ្ឌលគិរី ដើម្បីបង្ខឹកជនជាតិក្រោលទាំងនោះ ។ អ្នកដែលរស់នៅក្នុងក្រោលត្រូវបានគេបង្ហឹកឲ្យចេះស្លៀកពាក់ និងរស់នៅដោយសមរម្យនៅក្នុងសហគមន៍ ហើយបន្ទាប់មក គេបញ្ជូនអ្នកទាំងនោះទៅកាន់ឃុំស្រែជិះ ។ ប៉ុន្តែមានស្ត្រីដែលមានផ្ទៃពោះម្នាក់មិនបានចូលអន្ទាក់នេះទេ នេះជាហេតុដែលធ្វើឲ្យ ពឿន សន្និតថាជនជាតិក្រោលដើម ឬហៅថាមនុស្សព្រៃនៅតែមានរហូតមកដល់សព្វថ្ងៃនេះ ។

ពឿន និយាយរៀបរាប់ពីសង្គ្រាមវៀតណាមកំឡុងឆ្នាំ១៩៥៤-៧៥ នៅពេលដែលទាហានវៀតមិញឈ្លានពាននាំឲ្យរំខានដល់ការរស់នៅរបស់ជនជាតិក្រោល ។ ទាហានវៀតមិញកសាងមូលដ្ឋានទ័ពនៅក្បែរឃុំស្រែជិះ ហើយជាញឹកញាប់តែងតែស្នើសុំម្ហូបអាហារ និងធនធានផ្សេងទៀតពី ប្រជាជនដែលរស់នៅទីនោះ ។

សមាជិកជាន់ខ្ពស់មួយចំនួននៅក្នុងសហគមន៍ក្រោល បានរាយការណ៍ជាសម្ងាត់អំពីសកម្មភាពរបស់ក្រុមវៀតមិញទៅកាន់ (រាជរដ្ឋាភិបាល នៅក្រោមការដឹកនាំរបស់សម្តេចព្រះបាទ នរោត្តម សីហនុ) ។ ភ្លាមៗនោះរាជរដ្ឋាភិបាលបានបញ្ជូនក្រុមស៊ើបការណ៍របស់គេទៅធ្វើការស៊ើបអង្កេតមួយរំពេច ។ ពឿន សារ៉ាយ បានរំឭកថា បន្ទាប់ពីធ្វើការស៊ើបអង្កេតហើយនោះ សម្តេចព្រះបាទ នរោត្តម សីហនុ ក៏បានដឹកនាំកម្លាំងកងទ័ពមកកាន់ឃុំស្រែជិះ ហើយនៅឆ្នាំ១៩៥៣ យើងបានដកកងកម្លាំងទាហានវៀតមិញបានជោគជ័យ ។ ដើម្បីរំឭកពីភាពជោគជ័យនេះ គេបានសាងសង់ជារូបសំណាកគោថ្ម ដូចដែលយើងបានឃើញរហូតមកដល់ពេលសព្វថ្ងៃនេះ ។

### ***វេទិកា : ការពិពណ៌នា***

ជនជាតិក្រោល ពិតជាចង់រៀបរាប់អំពីបទពិសោធផ្ទាល់របស់គេអំពីរឿងរ៉ាវនៅក្នុងសម័យ ខ្មែរក្រហមដែលធ្វើឲ្យប៉ះពាល់ដល់ការរស់នៅ និងសហគមន៍របស់គេទៅកាន់ក្មេងៗជំនាន់ក្រោយ និងអ្នកជិតខាងរបស់គេទាំងអស់ ។ ជនជាតិក្រោល



សិស្សសាលាបឋមសិក្សាស្រែជិះ ក្នុងសហគមន៍ជនជាតិក្រោលចូលរួមស្តាប់វេទិកាប្រវត្តិកម្ពុជាប្រជាធិបតេយ្យ

បានសង្កេតឃើញថា ក្មេងៗជំនាន់ក្រោយមួយចំនួន ជឿលើរបបសម្លាប់កំណាចឃោរឃៅនេះ នៅពេលដែលមានក្មេងជំនាន់ក្រោយមួយចំនួននៅតែមិនជឿថាមានរបបនេះកើតឡើង ។ ពឿន បញ្ជាក់ថា ក្មេងៗជាច្រើននៅតែមិនជឿថាមានរបបមួយដែលសម្លាប់មនុស្សច្រើនដល់ថ្នាក់នេះ ហើយមានមនុស្សជាច្រើននៅតែមិនចាប់អារម្មណ៍អំពីដំណើរការកាត់ទោសរបស់តុលាការលើរបបខ្មែរក្រហមនេះទេ ។ ដោយសារតែការព្រួយបារម្ភពីការកើតឡើងម្តងទៀតនូវរបបនេះ បានជាអ្នកភូមិសម្រេចចិត្តចូលរួមក្នុងវេទិកាដែលរៀបចំឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជានេះ ហើយនាំសិស្សានុសិស្សមកពីសាលាផ្សេងៗ ចំនួន៦០សាលាទៅសិក្សាស្វែងយល់ ដើម្បីបណ្តុះបណ្តាលស្មារតីក្មេងៗជំនាន់ក្រោយ ។

នៅព្រឹកថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៣ ពឿន បានបញ្ជាក់ថា ជនជាតិក្រោលជាងពីររយនាក់ ដែលរួមបញ្ចូលទាំងក្មេងៗដែលមកពីសាលាចំនួនហុកសិប បានមកជួបជុំគ្នានៅក្នុងវត្តក្នុងឃុំស្រែជិះ ។ វេទិកានេះចាប់ផ្តើមនៅវេលាម៉ោង៩ព្រឹក ហើយអ្នកចូលរួមទាំងអស់ត្រូវបានបែងចែកជាបួនក្រុម ។ អ្នកសម្របសម្រួល និងអ្នកសង្កេតការណ៍មកពីមជ្ឈមណ្ឌលឯកសារកម្ពុជាទាំងអស់ ជាអ្នកដឹកនាំក្រុម ។ ក្រុមនីមួយៗត្រូវជ្រើសរើសតំណាងរបស់ខ្លួន ចំនួនពីបួនទៅប្រាំរូប ដើម្បីធ្វើអត្ថាធិប្បាយទៅលើប្រធានបទចំនួនបី គឺទីមួយអំពីបទពិសោធរបស់គេនៅក្នុងរបបខ្មែរក្រហម ទីពីរគឺការយល់ឃើញទៅលើដំណើរការកាត់ក្តីរបស់តុលាការ និងទីបីគឺបញ្ហាសុខភាពរបស់ជនជាប់ចោទក្នុងរបបខ្មែរក្រហមទាំងអស់ ។

នី បិន និង ធីម លៀត និយាយប្រាប់ទៅកាន់ក្រុមរបស់គាត់អំពីចលនាក្រុមឥស្សរៈ វត្តមានរបស់កងកម្លាំងវៀតមិញនៅក្នុងឃុំស្រែជិះ និងការទម្លាក់គ្រាប់ផ្លោងចន្លោះឆ្នាំ១៩៧៣ និង១៩៧៤ ។ យឹម ផាន តំណាងឲ្យក្រុមដែលបានចូលរួម បានរៀបរាប់ថា “ប៉ុល ពត ដែលក្រោយមកត្រូវបានគេស្គាល់ថាជាមេដឹកនាំក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ចាប់ផ្តើមចលនារបស់គេគៀងគរប្រជាជនចាប់តាំងពីឆ្នាំ១៩៧០ ។ នៅឆ្នាំ១៩៧៤ ចលនាខ្មែរក្រហមបានបង្កើតនូវសមូហភាពដោយត្រូវលុបបំបាត់ចោលនូវរាល់ទ្រព្យសម្បត្តិឯកជនទាំងអស់ ។ រវាងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ របបខ្មែរក្រហមបានសម្លាប់ប្រជាជនស្លូតត្រង់ប្រមាណជាមួយលានប្រាំពីរសែននាក់ ដោយប្រជាជនទាំងនោះធ្វើការធ្ងន់ហួសកម្លាំង ស្លាប់ដោយសារការអត់ឃ្លាន និងការយកទៅសម្លាប់ ។ ការអប់រំត្រូវបានលុបបំបាត់ចោល ប្រជាជនតម្រូវឲ្យធ្វើការងារតាមកម្លាំងពលកម្ម ។ សាសនាត្រូវបានហាមឃាត់ មិនមានតុលាការយុត្តិធម៌ទេ ។ ការសម្លាប់កើតមាននៅគ្រប់ទីកន្លែង គ្រួសារត្រូវបែកបាក់គ្នា ហើយហាមមិនឲ្យមានការរអ៊ូរទាំទេ” ។ បន្ទាប់ពី យឹម ផាន បានធ្វើការរៀបរាប់អំពីរឿងរបស់គាត់អំឡុងពេលខ្មែរក្រហមកាន់កាប់ហើយនោះ ឌុយ ថា ជាតំណាងក្រុមមួយរូបទៀត បានចែករំលែកពីបទពិសោធផ្ទាល់របស់គាត់ទៅកាន់សមាជិកក្រុម ហើយពោលថា “នៅឆ្នាំ១៩៧២ មិនមានមន្ទីរពេទ្យគ្រប់គ្រាន់សម្រាប់ព្យាបាលអ្នកជំងឺនោះទេ” ។

ដូចជាតំបន់ផ្សេងៗនៅទូទាំងប្រទេសកម្ពុជា ឃុំស្រែជិះគឺបានទទួលរងនូវបទពិសោធជាច់ខាតលើការគ្រប់គ្រងក្នុងរបបខ្មែរក្រហម ចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ។ ប្រជាជនត្រូវបានបង្ខំឲ្យ ធ្វើការងារធ្ងន់ ហើយអ្នកទាំងនោះស្លាប់ដោយសារការស្រេកឃ្លានផង និងការយកទៅសម្លាប់ចោលផង ។ ពឿន ប្រាប់ថា ខ្មែរក្រហមមានគម្រោងបម្រុងនឹងជម្លៀសប្រជាជនដែលរស់នៅក្នុងឃុំស្រែជិះនេះទាំងអស់ទៅកន្លែងមួយនៅក្នុងខេត្តកំពង់ធំ ។ សមាជិកជាន់ខ្ពស់នៅក្នុងសហគមន៍ក្រោល មានការព្រួយបារម្ភថាពេលទៅដល់ខេត្តនោះប្រជាជនក្រោលនឹងគ្មានស្បៀងអាហារហូបចុក ហេតុដូច្នេះហើយបានជាគេស្នើសុំឲ្យពន្យារពេលការជម្លៀសនេះ ។ បន្ទាប់ពីវៀតណាម ឈ្លានពានចូលមកខ្មែរក្រហមបានចាកចេញពីតំបន់នោះ ប៉ុន្តែការគម្រាមកំហែងនៅតែបន្តកើតមានដោយសារអ្នកទាំងនោះពួនស្ទាក់នៅជុំវិញ ហើយគម្រាមយកអាហារពីប្រជាជនក្នុងភូមិ ។ ការបញ្ចប់សង្គ្រាមស៊ីវិលដែលកើតឡើងចាប់ពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩៨ បាននាំមកនូវស្ថិរភាពសុខសន្តិភាពដល់អ្នកភូមិ ស្រែជិះម្តងទៀត ។

## វេទិកា ៖ ការយល់ឃើញរបស់ប្រជាជន

អ្នកចូលរួមភាគច្រើន រួមទាំងសិស្សានុសិស្សដែលបានចូលរួមឆ្លុះបញ្ចាំងថាវេទិកាភូមិសាធារណៈ គឺជាឧបករណ៍ដ៏សំខាន់សម្រាប់ពង្រីកចំណេះដឹងរបស់ប្រជាជនទាក់ទងនឹងប្រវត្តិសាស្ត្រ



ជនជាតិក្រោល ចូលរួមវេទិកាពិភាក្សាពីរឿងរ៉ាវរបបខ្មែរក្រហមនៅសាលាឆាន់ក្នុងវត្តស្រែជិះ ភូមិស្រែជិះ ឃុំស្រែជិះ ស្រុកសំបូរណ៍ ខេត្តក្រចេះ ដែលរៀបចំដោយគម្រោងវេទិកាអប់រំសាធារណៈតាមភូមិស្តីពី "ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ" របស់មជ្ឈមណ្ឌលឯកសារកម្ពុជាកាលពីខែកុម្ភះ

ខ្មែរក្រហម ហើយអ្នកទាំងនោះបានលើកឡើងថាគួរតែមានវេទិកាដូច្នេះនៅទូទាំងប្រទេស ។ មុី បៀន ដែលជាអនុភូមិ អំពក ព្រមទាំង លេន ភ័ក្រ្ត ជាមេភូមិ ភ្នំពីរ បង្ហាញពីចំណាប់អារម្មណ៍ចំពោះវេទិកានេះថា វេទិកានេះមានតួនាទីក្នុងការអប់រំដល់ក្មេងៗជំនាន់ក្រោយអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ។ អ្នកទាំងពីរគាំទ្រទៅលើការបង្កើតជាវេទិកាដូច្នេះនៅទូទាំងប្រទេស ហើយថែមទាំងចង់ឲ្យមានការពង្រីកឲ្យបានកាន់តែទូលំទូលាយជាងនេះ ហើយចុងក្រោយយើងអនុញ្ញាតឲ្យអ្នកភូមិទាំងអស់ជួបជាមួយអ្នកជំនាញលើប្រវត្តិសាស្ត្រខ្មែរក្រហម ។ អ្នកចូលរួមដទៃទៀត ដូចជា ជួិត ពាធ បានកោតសរសើរលើការខិតខំប្រឹងប្រែងជាវេទិកានេះឡើង គាត់យល់ឃើញថា ការបង្កើតជាវេទិកានេះឡើង គឺអាចជាទុនដល់ក្មេងៗជំនាន់ក្រោយស្គាល់ពីប្រវត្តិសាស្ត្រប្រទេសរបស់ខ្លួនបានរឹងមាំ ដើម្បីកសាងអនាគតសង្គមកម្ពុជា ។

សិស្សស្រីពីររូប បាននិយាយថាយើងគួរតែប្រើវេទិកានេះ គឺជាគំរូក្នុងការរៀបរាប់ពីប្រវត្តិសាស្ត្រខ្មែរ ។ គៀ ស្រីទូច ជាសិស្សថ្នាក់ទី៩ បាននិយាយថានេះគឺជាឱកាសមួយដ៏ល្អដែលនាងខ្ញុំបានចូលរួមជាលើកដំបូងក្នុងការស្តាប់ពីការយល់ឃើញរបស់អ្នកជិតខាងទៅលើប្រវត្តិសាស្ត្រខ្មែរក្រហម ។ នៅខណៈពេលដែល ស្រីទូច ផ្សាភ្ជាប់ថា ឪពុករបស់គាត់ក៏ជាសមាជិកម្នាក់នៅក្នុងរបបខ្មែរក្រហម គាត់បានស្នើសុំឲ្យមានការបង្កើតវេទិកាបែបនេះឲ្យបានច្រើនដើម្បីបន្តការពិភាក្សាអំពីរបបដ៏ឃោរឃៅមួយនេះ និងអំពីដំណើរការរបស់សាលាក្តីខ្មែរក្រហម ។ យោបល់របស់ ស្រីទូច បានឆ្លុះបញ្ចាំងអំពីការព្រួយបារម្ភទៅពីមិត្តរួមថ្នាក់គាត់ដែលភាគច្រើនគឺសឹងតែមិនបានឮពីការសម្លាប់រង្គាលនៅក្នុងសម័យខ្មែរក្រហមពីមុនមកទេ ។ ដា កាថា ជាសិស្សថ្នាក់ទី៨ បន្ទាប់ពីបានស្តាប់រឿងរ៉ាវមួយចំនួនអំពីរបបខ្មែរក្រហម គាត់ពិតជាមានភាពតក់ស្លុតដែលឮថាមានការសម្លាប់ដ៏ព្រៃផ្សៃ ដោយសារគាត់មិនដែលបានឮពីឪពុកម្តាយគាត់ ឬពីគ្រូរបស់គាត់និយាយអំពីរឿងនេះពីមុនមក ហើយកាថាមានគម្រោងថានឹងសាកសួរឪពុកម្តាយរបស់គាត់ពីបទពិសោធដែលពួកគាត់បានជួបប្រទះក្នុងរបបខ្មែរក្រហម ។

ដោយឡែក អ្វីដែលជាបញ្ហាប្រឈមនៅក្នុងវេទិកានោះគឺ

សិស្សានុសិស្សមានភាពស្ទាក់ស្ទើរនៅក្នុងការចោទជាសំណួរ ។ អាស្រ័យហេតុដូច្នេះ ឃឹម ផាន បានស្នើសុំទៅកាន់អ្នកចូលរួមនៅក្នុងវេទិកានេះឲ្យសិស្សានុសិស្សចំណាយពេលអានសៀវភៅទាក់ទងទៅនឹងប្រវត្តិសាស្ត្រខ្មែរក្រហមឲ្យបានច្រើន ហើយគាត់បានបន្ថែមទៀតថា គាត់សង្ឃឹមថានឹងមានវេទិកានេះជាបន្តបន្ទាប់ ព្រោះថាការធ្វើឡើងតែម្តងមិនគ្រប់គ្រាន់ក្នុងការបណ្តុះការយល់ដឹងពីរបបនេះបានទេ ។ ផាន ទទួលស្គាល់ថាផ្នែកមួយដែលជាបញ្ហាគឺថា ឪពុកម្តាយមិនដឹងពីវិធីក្នុងការចែករំលែកបទពិសោធរបស់គាត់នៅក្នុងសម័យខ្មែរក្រហម ។ បញ្ហាមួយទៀត គឺថាសហគមន៍ជនជាតិភាគតិចស្រែជិះប្រើភាសាពីរ ។ អ្នកខ្លះនិយាយតែភាសាក្រោល ហើយអ្នកខ្លះទៀតនិយាយតែភាសាខ្មែរសុទ្ធសាធធ្វើឲ្យពិបាកក្នុងការប្រើភាសានិយាយទំនាក់ទំនងគ្នា ។ លើសពីនេះទៅទៀត អ្នកចូលរួមមួយចំនួន យល់ភាសាក្រោលជាជាងភាសាខ្មែរ ។

## ប្រភពបញ្ហា ៖ ការទទួលបានព័ត៌មានស្តីពីដំណើរការសាលាក្តីខ្មែរក្រហមនៅមានកម្រិត

ការទទួលបានព័ត៌មានស្តីពីដំណើរការសាលាក្តីខ្មែរក្រហម នៅតែជាបញ្ហាសម្រាប់សហគមន៍ជនជាតិក្រោល ។ យោងតាមការសម្ភាសន៍ជាមួយមន្ត្រីក្នុងស្រុក និងសមាជិកចំណាស់នៅក្នុងសហគមន៍ប្រាប់ថាប្រជាជនភាគច្រើននៅទីនេះ មិនមានលទ្ធភាពនៅក្នុងការតាមដានដំណើរការនីតិវិធីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការខ្មែរក្រហម ។ ទោះបីជាអ្នកមួយចំនួនព្យាយាមតាមដានដំណើរការសាលាក្តី តែភាគច្រើនគឺមិនបានដឹង និងមិនមានការចាប់អារម្មណ៍លើរឿងនេះឡើយ ។ ធឹម ធៀម អតីតក្រុមប្រឹក្សាឃុំស្រែជិះរៀបរាប់ថា ឃុំស្រែជិះគឺជាតំបន់ដាច់ស្រយាល ដូច្នេះហើយធ្វើឲ្យប្រជាជននៅទីនេះ មានការលំបាកទទួលបាននូវព័ត៌មាន ។ ធៀម ប្រាប់បន្ថែមទៀតថា គាត់តែងតែតាមដាននូវដំណើរការកាត់ក្តីជាប្រចាំ ហើយក៏មានការព្រួយបារម្ភអំពីដំណើរការយឺតយ៉ាវនៃនីតិវិធីតុលាការ ។ គាត់ចង់មានន័យថា ប្រសិនតុលាការបន្តដំណើរការកាត់ក្តីមេដឹកនាំខ្មែរក្រហមជាដំណាក់ៗដូចនេះ អ្នកទាំងនោះនឹងស្លាប់មុនពេលការធ្វើសេចក្តីសម្រេច ។ គាត់មានប្រសាសន៍ថា វាជាការសំខាន់នៅក្នុងការបង្ហាញពីលទ្ធផលនៃការកាត់ទោសមេដឹកនាំខ្មែរក្រហមនៅក្នុងតុលាការ ។

## សេចក្តីសរុប

នៅមុនពេលបិទអង្គវេទិកា យើងបានធ្វើការសរុបសេចក្តីនៃការពិភាក្សាដូចតទៅ ៖ ស្រែជិះ ដែលជាសហគមន៍ដាច់ស្រយាលនៅក្នុងខេត្តក្រចេះ គឺបានជួបប្រទះនឹងបញ្ហាប្រឈមកន្លងមកជាយូរមកហើយ ។ ការប្រឈមទាំងនេះរួមមាន អវត្តមានទាំងស្រុងនៃប្រវត្តិសាស្ត្រខ្មែរក្រហមបញ្ចូលទៅក្នុងកម្មវិធីសិក្សា កង្វះខាតការយល់ដឹងអំពីប្រវត្តិសាស្ត្រ នៅក្នុងរង្វង់ក្មេងៗជំនាន់ក្រោយដោយសារតែប្រព័ន្ធផ្សព្វផ្សាយមិនទូលំទូលាយ និងចុងក្រោយមិនបានដឹងពីដំណើរការមកដល់នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ នៅក្នុងដែនសមត្ថកិច្ចនៃអង្គវេទិកា មន្ត្រីប៉ូលីស និងប្រជាជនក្នុងសហគមន៍ ដែលបានចូលរួមបានសង្កត់ធ្ងន់ទៅលើសារសំខាន់នៃការពិភាក្សារវាងឪពុកម្តាយ លោកគ្រូអ្នកគ្រូ សិស្សានុសិស្ស និងកូនៗជំនាន់ក្រោយ ។ ដំណើរការពិភាក្សាសំខាន់ផ្តោតទៅលើប្រធានបទ ការចងចាំអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងដំណើរការកាត់ក្តីមេដឹកនាំខ្មែរក្រហម ។ អ្នកភូមិទាំងអស់ជឿជាក់ថាគួរតែបន្តមានវេទិកានៅទីនេះ អនុញ្ញាតឲ្យសមាជិកសហគមន៍ចូលរួម និងដឹកនាំការពិភាក្សាប្រធានបទជាក់លាក់ណាមួយដែលពាក់ព័ន្ធទៅនឹងសហគមន៍របស់ខ្លួន និងបញ្ចេញនូវការព្រួយបារម្ភជាឯកជន ។ អ្នកចូលរួមក៏បានស្នើសុំអ្នករៀបចំមកពីមជ្ឈមណ្ឌលឯកសារកម្ពុជាបញ្ជូនសំណើទៅកាន់រាជរដ្ឋាភិបាលកម្ពុជាដើម្បីពង្រីកប្រព័ន្ធអប់រំនៅក្នុងឃុំ និងការសាងសង់ផ្លូវដើម្បីជួយសម្រួលក្នុងការធ្វើដំណើរ ។

បញ្ហាមួយទៀតដែលយើងទទួលស្គាល់គឺ អក្ខរជននៅមានកម្រិតទាបនៅក្នុងឃុំស្រែជិះ ។ នេះក៏ដោយសារតែឃុំនេះមានសាលាបឋមសិក្សាតែមួយ ដូច្នេះហើយបានជាសិស្សភាគច្រើនបោះបង់ចោលការសិក្សាឪពុកម្តាយពុំមានលទ្ធភាពឲ្យកូនបន្តទៅកាន់អនុវិទ្យាល័យ ឬវិទ្យាល័យ ស្ថិតនៅរលួស ដែលមានចម្ងាយឆ្ងាយពីឃុំស្រែជិះប្រមាណ១២គីឡូម៉ែត្រ ឬទៅកាន់ទីរួមខេត្តក្រចេះ ។ យើងក៏ទទួលស្គាល់ដែរថាដោយសារតែភាពក្រីក្រ បានធ្វើឲ្យឪពុកម្តាយមួយចំនួនមិនមានទឹកចិត្តឲ្យកូនរបស់ខ្លួនបន្តការសិក្សា បែរជាលើកទឹកចិត្តឲ្យកូនរបស់ខ្លួនចេញទៅរកប្រាក់

ចំណូលផ្គត់ផ្គង់គ្រួសារ ។ ដំណោះស្រាយដំបូងដែលបានលើកឡើងដោយអាជ្ញាធរក្នុងតំបន់គឺត្រូវធ្វើប្រសើរឡើងនូវប្រព័ន្ធអប់រំ ដោយការដាក់បញ្ចូលនូវកម្រិតអនុវិទ្យាល័យ ដែលផ្តល់ឲ្យសិស្សានុសិស្សមានភាពងាយស្រួលក្នុងការបន្តការសិក្សារបស់គេ ។

អ្នកចូលរួមក៏បានលើកឡើងផងដែរអំពីហេដ្ឋារចនាសម្ព័ន្ធដែលនៅមានកម្រិតដែលរារាំងអ្នកទាំងនោះ ក្នុងការធ្វើដំណើរទៅកាន់ឃុំរលួស ។ អ្នកភូមិបានពោលដូចតទៅថា «ប្រជាជននៅក្នុងភូមិនេះមិនទាន់មានភាពរីករាយទៅនឹងផ្លូវថ្នល់ និងស្ពានដែលគេមាននៅឡើយទេ» ដោយគេបានពន្យល់អំពីការធ្វើដំណើរនៅរដូវប្រាំងមិនសូវមានបញ្ហាដោយឡែកនៅខែវស្សា ការធ្វើដំណើរនៅទីនេះគឺលំបាកខ្លាំងណាស់ ។ នេះបង្ហាញភ្លាមៗអំពីភាពរារាំងការធ្វើដំណើររបស់សិស្សានុសិស្សដែលចង់រៀន ។ សមាជិកភាគច្រើនធ្លាប់ទទួលរងបទពិសោធនូវការលំបាកដោយសារខ្វះខាតផ្លូវដោយអ្នកទាំងនោះបានចំណាយពេលលើសមួយម៉ោងក្នុងការធ្វើដំណើរនៅលើផ្លូវដីអាក្រក់ពីឃុំស្រែជិះទៅកាន់ឃុំរលួស ។

ផ្លូវបានធ្វើឲ្យប៉ះពាល់ដល់សុខុមាលភាពរបស់ប្រជាជនដូចជានៅខណៈពេលដែលមានមនុស្សឈឺ អ្នកជំងឺនោះមិនអាចត្រូវបញ្ជូនទៅកាន់មន្ទីរពេទ្យបានទាន់ពេលវេលា ។ អ្នកភូមិជាច្រើនរំឭកព្រឹត្តិការណ៍នៅក្នុងឆ្នាំ២០១០ ដែលមានស្ត្រីស្លាប់ដោយសារឆ្លងទន្លេមិនរួចចំនួន៣០នាក់ ហើយដោយយោងទៅតាមអ្នកស្លាប់ដោយសារជំងឺរាគមួលហើយយកទៅមន្ទីរពេទ្យមិនបានទាន់ពេលវេលានោះក៏មានចំនួនច្រើនដែរ ។ លើសពីនេះទៀតការបញ្ជូនអ្នកជំងឺទៅកាន់មន្ទីរពេទ្យគឺធ្វើឡើងតាមបែបបុរាណបំផុត ដោយការដាក់អ្នកជំងឺនៅក្នុងអង្រឹង ហើយសែងដោយបុរសដែលរស់នៅក្នុងភូមិនោះទៅកាន់មណ្ឌលសុខភាពនៅរលួស ។ គួរសង្កត់ធ្ងន់ផងដែរថា អ្នកចូលរួមទាំងអស់បានលើកឡើងពីបញ្ហាការស្ថាបនាផ្លូវត្រឹមត្រូវដើម្បីភាពងាយស្រួលក្នុងការធ្វើដំណើរ និងការសាងសង់ស្ពាននឹងជាដំណោះស្រាយនូវរាល់បញ្ហាផ្សេងៗទាំងអស់ដែលអ្នកភូមិបាននឹងកំពុងជួបប្រទះទាំងផ្នែកអប់រំនៅក្នុងឃុំស្រែជិះក៏ដូចជាការធ្វើឲ្យប្រសើរឡើងនូវសុខុមាលភាពរបស់ប្រជាជននៅក្នុងភូមិស្រែជិះ ។

**លី សុខឃាង**



ជនជាតិក្រោលដែលបានចូលរួមវេទិកាអប់រំសាធារណៈកំពុងអានសៀវភៅ«ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ១៩៧៥ - ១៩៧៩»

# ទួលតក់ស្លុត

ពេលទស្សនាសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងកាលពីខែធ្នូ ឆ្នាំ២០១២ ស៊ុំ សុខន អតីតយុទ្ធជនខ្មែរក្រហមមួយរូបបាននិយាយថា «ខ្ញុំបានមកទីនេះច្រើនលើកច្រើនសាមកហើយ តែខ្ញុំនៅតែតក់ស្លុតពេលដែលខ្ញុំឈានជើងចូលដល់ទីនេះម្តងៗ និងនឹកឃើញរាល់ការឈឺចាប់ទាំងឡាយ ។ មិត្តភក្តិជាច្រើនរបស់ខ្ញុំត្រូវចាប់ខ្លួន និងសម្លាប់នៅទីនេះ ។ ការលំបាកវេទនា និងការឈឺចាប់បានផុសឡើងនៅចំពោះមុខខ្ញុំ ហើយរឿងរ៉ាវទាំងប៉ុន្មានដែលបានកើតឡើងនៅរបបខ្មែរក្រហមហាក់ដូចជាទើបតែកើតឡើងកាលពីម្សិលមិញអ៊ីចឹង» ។

ស៊ុំ សុខន អតីតយុទ្ធជនមួយរូបបានអះអាងថា ចាញ់បោកការឃោសនារបស់ខ្មែរក្រហមក្នុងការចូលរួមធ្វើបដិវត្តន៍ប្រឆាំងនឹងរបប លន់ នល់ ដើម្បីទាមទារឲ្យសម្តេចឪត្រឡប់មកគ្រប់គ្រងប្រទេសវិញ ។ ប៉ុន្តែក្រោយពេលដែលខ្មែរក្រហមទទួលជ័យជម្នះ អ្វីគ្រប់យ៉ាងមិនដូចជាអ្វីដែលបានសន្យាចំពោះប្រជាជនដែលចូលរួមធ្វើបដិវត្តន៍នោះទេ ។

សុខន ជាកូនគ្រួសារកសិករដែលរស់នៅស្រុកព្រៃឈរ ខេត្តកំពង់ចាម ។ គាត់រៀនបានត្រឹមថ្នាក់ទី៨ នៅសាលាត្រពាំងអំពិល ។ ក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ នៅក្នុងភូមិស្រុករបស់ សុខន មានចលនាខ្មែរក្រហមដែលពេលនោះហៅថា ខ្មែររំដោះ បានចូលមកឃោសនាដល់យុវជនក្នុងភូមិឲ្យចូលរួមធ្វើកងទ័ព ដើម្បីទាមទារឲ្យសម្តេចឪ ត្រឡប់មកគ្រប់គ្រងប្រទេសវិញ ។ ស្ថិតក្នុងវ័យ១៣ឆ្នាំ សុខន បានស្ម័គ្រចិត្តចូលធ្វើកងទ័ពតាមការឃោសនា ។ គាត់បានចូលធ្វើកងទ័ពនៅភូមិភាគឧត្តរ នៅក្នុងកងពលទី១ ដោយមាននាទីជាយុទ្ធជន ។ ការហ្វឹកហាត់ទៀតសោត គឺមានជំនាញការវៀតណាម មកបង្ហាត់ ប៉ុន្តែក្រោយមក នៅអំឡុងឆ្នាំ១៩៧៣ សុខន មិនបានឃើញជំនាញការវៀតណាមមកបង្ហាត់ទៀតទេ ។ រហូតដល់ឆ្នាំ១៩៧៤ ទើបកងពលរបស់ សុខន ឡើងមកវាយនៅភ្នំពេញតាមផ្លូវលង្វែក រហូតមកតាមផ្លូវព្រែកព្នៅ និងទំនប់កប់ស្រូវ ។ កងពលរបស់គាត់វាយរុលចូលតាមព្រែកព្នៅ រហូតដល់ថ្ងៃ ១៧ មេសា ឆ្នាំ ១៩៧៥ ទើបវាយបែកភ្នំពេញ ។

ក្រោយជ័យជម្នះថ្ងៃ១៧ មេសា អង្គការបានចាត់តាំងឲ្យកងពលរបស់ សុខន មកនៅម្តុំវត្តភ្នំ ប៉ុន្តែបីខែក្រោយមក មិនដឹងជាមានរឿងអ្វីកើតឡើងនោះទេ មានបញ្ជាពីថ្នាក់លើមកឲ្យដកហូតអាវុធទាំងអស់ និងផ្តល់មកវិញនូវ ចប បង្គី និងកាំបិត ជំនួសវិញ ។ បន្ទាប់មក កងពលរបស់គាត់ត្រូវផ្លាស់ឲ្យទៅធ្វើស្រែនៅខាងបឹងប្រយាប ។ ការហូបចុក និងធ្វើស្រែនៅទីនោះលំបាកណាស់ ទោះបី សុខន ជាយុទ្ធជនក៏ដោយ ។ សុខន ទទួលបានបបរតែពីរពេលប៉ុណ្ណោះ ហើយពេលខ្លះត្រូវធ្វើការរហូតដល់ម៉ោង១១យប់ ឬ១២យប់ ។ គាត់បានរំឭកថា អំឡុងឆ្នាំ១៩៧៦ ដល់ ១៩៧៧ នៅក្នុងកងពលរបស់គាត់មានការផ្លាស់ប្តូរមេក្រុម និងមេកងជាញឹកញាប់ ហើយអ្នកទាំងនោះ ភាគច្រើនត្រូវអង្គការលើប្រាប់ថា យកទៅរៀនសូត្រ ហើយក៏មិនដែលឃើញត្រឡប់មកវិញម្តងណាទេ ។

សុខន និយាយថា «ប្រសិនបើខ្ញុំនៅទីនេះយូរបន្តិចទៀត



ស៊ុំ សុខន ពេលផ្តល់បទសម្ភាសន៍នៅទួលស្លែងកាលពីខែធ្នូ ឆ្នាំ២០១២

ប្រហែលជាមានវាសនាមិនខុសពីអ្នកទាំងនោះឡើយ គឺត្រូវយកមកសម្លាប់នៅគុកទួលស្លែងនេះពុំខាន» ។ រយៈពេលជាងបីឆ្នាំក្នុងរបបខ្មែរក្រហម សុខន ធ្លាប់ឮពីមន្ទីរស-២១ ប៉ុន្តែមិនដឹងថាជាកន្លែងអ្វីនោះទេ ។ ប៉ុន្មានឆ្នាំក្រោយការដួលរលំរបស់របបខ្មែរក្រហមទើបដឹងថា មន្ទីរស-២១ ជាម៉ាស៊ីនសម្លាប់មនុស្សដ៏សាហាវ ជាពិសេសគាត់បានឃើញផ្ទាល់នូវរូបថតមិត្តភក្តិដែលធ្វើការនៅកងពលជាមួយគ្នាទៅទីនេះ ។ ទាំងនេះធ្វើឲ្យគាត់នឹកដល់ពេលដែលកម្មាភិបាលខ្មែរក្រហមមកយកមនុស្សនៅក្នុងកងពលរបស់គាត់ម្តងៗ ហើយប្រាប់ថាយកទៅរៀនសូត្រនោះ តាមការពិតគឺយកមកធ្វើទារុណកម្ម និងសម្លាប់នៅគុកទួលស្លែងនេះ ។

នៅដើមឆ្នាំ១៩៧៨ កងពលរបស់ សុខន ត្រូវអង្គការចាត់តាំងឲ្យធ្វើការនៅការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង រហូតដល់ថ្ងៃដែលវៀតណាមរំដោះប្រទេសតែម្តង ។

ក្រោយថ្ងៃ៧ មករា ឆ្នាំ១៩៧៩ កងពលរបស់ សុខន បែកគ្នាអស់ និងខ្លះនាំគ្នារត់ចូលព្រៃ ក្នុងនោះក៏មានគាត់ដែរ ។ ចូលព្រៃបានមួយរយៈ ដោយកងទ័ពវៀតណាមស្ទាក់វាយគ្រប់ទីកន្លែង សុខន ក៏សម្រេចចិត្តរត់គេចពីក្រុមរបស់ខ្លួន ដើម្បីត្រឡប់ទៅស្រុកកំណើតវិញ ។ ក្នុងការធ្វើដំណើរនេះ សុខន និងគ្នីគ្នាប្រហែលដប់ប្រាំនាក់ទៀតបានធ្វើដំណើររហូតដល់ស្រុកបារាយណ៍ ខេត្តកំពង់ធំ ហើយក៏បានសារភាពចុះចូលជាមួយកងទ័ពរដ្ឋាភិបាលនៅស្រុកបារាយណ៍នោះតែម្តង ។ ក្រោយពីបានចុះចូលហើយ សុខន ត្រូវខាងកងទ័ពរដ្ឋាភិបាលស្នើឲ្យត្រឡប់ទៅវិញ ដើម្បីអូសទាញអ្នកដែលនៅសេសសល់ដទៃទៀត គាត់បានគិតក្នុងចិត្តថា ប្រសិនបើគាត់ត្រឡប់ទៅវិញ ប្រាកដជាស្លាប់មិនខាន ។ គាត់បដិសេធ និងស្នើសុំទៅផ្ទះ ដើម្បីជួបជុំគ្រួសារវិញ ព្រោះបែកគ្នាជាងដប់ឆ្នាំមកហើយ តាំងពីបងប្អូនប្រុសទាំងបួនរបស់គាត់ចូលបម្រើបដិវត្តន៍ម្ល៉េះ ។ កងទ័ពរដ្ឋាភិបាលក៏មិនបដិសេធអ្វីដែរ សុខន បានចំណាយពេលពីរយប់បីថ្ងៃទើបបានទៅដល់ស្រុកកំណើត និងបានឃើញមុខឪពុកម្តាយវិញ ។

បន្តដោយសំឡេងអួលដើមក «បងប្អូនខ្ញុំបួននាក់បានចូលបម្រើបដិវត្តន៍នៅពេលនោះ តែពេលនេះមានតែខ្ញុំម្នាក់ប៉ុណ្ណោះដែលមានជីវិតមកជួបឪពុកម្តាយវិញ ខ្ញុំមិនដឹងថាមានរឿងអ្វីកើតឡើងចំពោះអ្នកទាំងបីទេ» ។

ពេលដំបូងដែលទៅដល់ផ្ទះវិញ សុខន មិនជឿថា មានការកាប់សម្លាប់ប្រជាជននោះ ព្រោះខាងយោធា អង្គការមិនដែលប្រាប់ពីរឿងអ្នកដែលរស់នៅសមរភូមិក្រោយរស់នៅពិបាកវេទនាអ្វីនោះទេ គ្រាន់តែប្រាប់ថា ម៉ែឪ បងប្អូន របស់បងប្អូនសុខសប្បាយទេ អង្គការយកចិត្តទុកដាក់ថែទាំណាស់ ហើយគិតតែខំតស៊ូការពារប្រទេសបានហើយ ។ ក្រោយពីបានទៅស្តាប់ការរៀបរាប់របស់បងប្អូនក្នុងភូមិ ឃើញផ្ទាល់ភ្នែកនូវរណ្តៅសាកសពជាពិសេសគ្រួសារឪពុកមារបស់គាត់ដែលមានសមាជិក ជាងដប់ត្រូវបានសម្លាប់ ទើបគាត់ជឿរឿងទាំងនេះ ។

ទោះបីជា សុបិនអាក្រក់ទាំងនេះកន្លងផុតទៅជាងសាមសិបឆ្នាំហើយក៏ដោយ ប៉ុន្តែនៅតែដិតដាមក្នុងចិត្ត សុខន ជានិច្ច ។ គ្រប់ពេលដែលគាត់ទៅកាន់កន្លែងណាដែលធ្លាប់ធ្វើការ និងទៅនៅសម័យខ្មែរក្រហមនោះ រូបភាពអតីតកាលទាំងនោះបានផុសឡើងនៅចំពោះមុខគាត់ ធ្វើឲ្យគាត់មានអារម្មណ៍ទុក្ខព្រួយ ឈឺចាប់ចំពោះអ្វីៗដែលបានកើតឡើងនៅពេលនោះ ជាពិសេស មន្ទីរស-២១ ឬគុកទួលស្លែងនេះ ។ ពេលដែល សុខន សម្លឹងមើលរូបថតជនរងគ្រោះដែលបិទនៅតាមជញ្ជាំង កែវភ្នែក ដែលសម្លឹងមកគាត់ មើលទៅហាក់បីដូចជាបង្កប់នូវភាពភ័យខ្លាចជាខ្លាំង ។ រូបថតជនរងគ្រោះ សម្លៀកបំពាក់ ឧបករណ៍ធ្វើទារុណកម្មទាំងអស់នេះ តែងតែធ្វើឲ្យ សុខន មានអារម្មណ៍ក្តុកក្តួលនឹកឃើញដល់មិត្តភក្តិ បងប្អូន ដែលបានស្លាប់ក្នុងរបបខ្មែរក្រហម ។

បច្ចុប្បន្ននេះ ស៊ុំ សុខន មានអាយុ ៥៨ឆ្នាំ មានប្រពន្ធនិងកូនបួននាក់ ។ សព្វថ្ងៃគ្រួសាររបស់ សុខនរស់នៅស្រុកព្រៃឈរ ខេត្តកំពង់ចាម ដោយប្រកបមុខរបរធ្វើស្រែ ។

ចំពោះតុលាការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហម សុខន សង្ឃឹមថា តុលាការនឹងរកយុត្តិធម៌ ហើយគោលបំណងគាត់ផ្ទាល់ដែលជាជនរងគ្រោះមួយរូប គាត់ចង់ឲ្យតុលាការរកយុត្តិធម៌ឲ្យលម្អិត ព្រោះប្រជាជនយើងស្លាប់ច្រើនណាស់ ។ ការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហមនេះ គឺជាគំរូមួយ ដើម្បីកុំឲ្យអ្នកជំនាន់ក្រោយយកតម្រាប់តាម ។

**ធាច សារៈមុនិន្ទ**

# កុមារធ្វើការជូនបដិវត្តន៍


យ៉ង់ តាំងកួយ

ធម្មនុញ្ញរបស់របបកម្ពុជាប្រជាធិបតេយ្យ បានចែងថា "មានកម្ពុជាប្រជាធិបតេយ្យ គឺបងប្អូនប្រជាជនទាំងអស់គ្នានឹងមានការងារធ្វើគ្រប់ៗគ្នា ការរស់នៅស្មើគ្នា មិនមានអ្នកមានមិនមានអ្នកក្រ និងគ្មានវណ្ណៈសក្តិភូមិជិះជាន់ កេងប្រវ័ញ្ចទៀតឡើយ" ។

ពិតណាស់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ សូម្បីតែកុមារអាយុចាប់ពីប្រាំឆ្នាំឡើងទៅ ក៏ត្រូវធ្វើការដូចមនុស្សពេញវ័យដែរ លើកលែងតែកុមារដែលទើបតែចេះវារ ឬដើរប៉ុណ្ណោះ ។ កុមារជាច្រើនត្រូវស្លាប់ដោយជំងឺ ការបង្ខំឲ្យធ្វើការហួសកម្លាំង និងការអត់ឃ្លាន ។ យ៉ង់ តាំងកួយ គឺជាកុមារម្នាក់ក្នុងចំណោមកុមារដទៃទៀតដែលមានសំណាងមានជីវិតរស់ពីរបបខ្មែរក្រហម ដែលកាលណោះគាត់ទើបតែមានវ័យប្រាំបីឆ្នាំប៉ុណ្ណោះ ។ តាំងកួយ ជាកូនទីបួនក្នុងចំណោមបងប្អូនប្រុសស្រីបួននាក់ក្នុងគ្រួសារកសិករមួយនៅភូមិភ្លៀត ដែលមានឪពុកឈ្មោះ យ៉ង់ គី និងម្តាយឈ្មោះ ប៉ុង ព្រាប ។ ដោយសារតែភូមិភ្នាតជាភូមិមួយដាច់ស្រយាល គាត់មិនបានរៀនសូត្រនោះទេ ព្រោះគ្មានសាលានៅក្បែរផ្ទះ ។

អំឡុងឆ្នាំ១៩៧៤ ខ្មែរក្រហមបានរំដោះភូមិស្រុកដែល តាំងកួយ រស់នៅ ។ រហូតដល់ឆ្នាំ១៩៧៥ ក្រោយពេលដែលខ្មែរក្រហមកាន់កាប់ប្រទេសទាំងស្រុងថ្ងៃ១៧ មេសា គ្រួសាររបស់ តាំងកួយ ត្រូវអង្គការជម្លៀសទៅនៅភូមិសូភី ឃុំចង្ហួរ ស្រុកអូរជ្រៅ (អតីតខេត្តបាត់ដំបង) ។ គាត់និងគ្រួសារត្រូវចំណាយពេលធ្វើដំណើរតាមរទេះគោមួយថ្ងៃទើបទៅដល់ភូមិសូភី ។ ពេលទៅដល់ទីនោះភ្លាម បងៗរបស់ តាំងកួយ ត្រូវអង្គការចាត់តាំងឲ្យទៅធ្វើការនៅកងចល័តឆ្ងាយពីគ្នា ហើយក៏បែកគ្នាចាប់តាំងពីពេលនោះមក ។ ចំណែកឪពុកម្តាយរបស់គាត់ ត្រូវអង្គការចាត់តាំងឲ្យធ្វើស្រែនិងដកស្ទូងនៅក្នុងភូមិ ។ ដោយសារតែ តាំងកួយ មានវ័យក្មេង ទើបអង្គការចាត់តាំងគាត់ឲ្យធ្វើនៅកងកុមារក្នុងភូមិសូភី ។ គាត់បន្តថា ទោះបីជាយើងជាកុមារពិតមែន ប៉ុន្តែការងារដែលធ្វើគឺដូចជាមនុស្សពេញវ័យអ៊ីចឹងដែរ ការងារលើកភ្លឺស្រែពិតជាពិបាកណាស់សម្រាប់យើងជាកុមារដែលមានកម្លាំងខ្សោយ ហើយត្រូវធ្វើការជាច្រើនម៉ោងដើម្បីប្តូរយករបបបបររាវតែមួយវែកប៉ុណ្ណោះ ។ កុមារទាំងអស់ ក្រោយពេលដែលធ្វើការរួចនៅពេលល្ងាចគឺមានសិទ្ធិទៅជួបឪពុកម្តាយវិញនៅភូមិ ប៉ុន្តែត្រូវត្រឡប់មកកន្លែងវិញឲ្យបានទាន់ពេលវេលា ។ ដកដង្ហើមធំមុននឹងបន្ត តាំងកួយ នៅចាំយ៉ាងច្បាស់នូវអនុស្សាវរីយ៍ដ៏ឈឺចាប់ដោយមានពេលមួយដោយសារនឹកឪពុកម្តាយខ្លាំងពេក ក្រោយពេលសម្រាកពីការងារនៅពេលល្ងាច គាត់បានទៅជួបឪពុកម្តាយនៅឯផ្ទះ និងបានសម្រាកនៅទីនោះមួយយប់ ហើយដោយសារគេងស្កប់ស្កល់ពេក គាត់ត្រឡប់ទៅកងវិញយឺតពេល ។ ពេលទៅដល់ មេក្រុមឈរចាំនៅកន្លែងរួចជាស្រេច ហើយគ្រាន់តែឃើញ តាំងកួយ ភ្លាម មេកងនោះក៏ស្ទុះទៅធាក់គាត់មួយជើង ហើយបញ្ជាគាត់ឲ្យលោតជើងមួយជុំវិញសសរកន្ទោងនៅក្នុងផ្ទះ ។ កាលណោះ កងកុមាររបស់ តាំងកួយ ត្រូវបានអង្គការឲ្យស្នាក់នៅផ្ទះ

បុរាណមួយ ។ គាត់បន្តថា វាមិនមែនជារឿងងាយស្រួលទេ ដែលត្រូវលោតជើងមួយជុំវិញសសរ ពេលដែលលោតគឺមានមេក្រុមមេកងចាំវាយទាត់យើងទៀត ។ ពេលដែលគាត់លោតបានតែបន្តិចមេក្រុមរបស់គាត់បានធាក់គាត់ឲ្យដួលទៅនឹងដី ហើយអ្នកឯទៀតក៏ស្ទុះមកវាយទាត់បន្ថែមទៀត ។ បើដួលភ្លាម យើងក្រោកឲ្យលឿនទើបរួចខ្លួនពីការវាយដំប្រំធាក់ពីអ្នកទាំងនោះ ។ នេះគឺជាការពិន័យមួយដែលនៅតែដក់ជាប់ក្នុងអារម្មណ៍របស់កុមារម្នាក់នេះរហូតដល់បច្ចុប្បន្ន ។

ជាងនេះទៅទៀត ការងារនៅការដ្ឋានរបស់ តាំងកួយ គឺត្រូវតែធ្វើការដោយមានភាពស្វាហាប់ ព្រោះមានមេកង មេក្រុមនៅឈរចាំសង្កេតមើល ប្រសិនបើនរណាម្នាក់ធ្វើការយឺតយ៉ាវ ឬស្ពឹកស្រពន់ប្រាកដជាមេក្រុម មេកងវ័យក្មេងទាំងនោះ វាយមិនខាន ។ ថ្ងៃមួយ តាំងកួយ គ្រុនក្តៅយ៉ាងខ្លាំងមិនអាចងើបធ្វើការរួចដោយឃើញគាត់ឈឺពិតប្រាកដមែន ទើបមេក្រុមអនុញ្ញាតឲ្យទៅសម្រាក នៅមន្ទីរពេទ្យនៅក្នុងសាលារៀនសូភី ។ ពេលទៅដល់មន្ទីរពេទ្យ តាំងកួយ ឃើញអ្នកជំងឺជាច្រើន ចំណែកឯគ្រូពេទ្យមានចាស់ មានក្មេង ប៉ុន្តែដូចជាមិនបានពិនិត្យអ្វីទេ ទោះបីជាឈឺអ្វីក៏ឲ្យថ្នាំតែមួយប្រភេទដូចគ្នា ដែលហៅថា ថ្នាំអាចម៍ទន្សាយ ។ ដោយនៅមន្ទីរពេទ្យពិបាក និងគ្មានរបបហូបចុកគ្រប់គ្រាន់ ប្រាំមួយថ្ងៃក្រោយមកគាត់បានចេញពីមន្ទីរពេទ្យ ហើយត្រឡប់មកជួបឪពុកម្តាយនៅភូមិវិញ ។ នៅក្នុងសម័យខ្មែរក្រហមគ្មានអ្វីសំខាន់ជាងអំបិល ស្ករ អង្ករ នោះទេ ។ ថ្ងៃដែល តាំងកួយ ត្រឡប់ទៅផ្ទះ ម្តាយរបស់គាត់បានយកមាសពីរជីដែលគាត់បានលាក់ទុកតាំងពីថ្ងៃជម្លៀស ទៅដូរបានអំបិលច្រើនល្មម ដើម្បីទុកដូរម្ហូបជាមួយអ្នកដទៃខ្លះ និងហូបខ្លួនឯងខ្លះ ។ រឿងដែលនឹកស្មានមិនដល់បានកើតឡើងនៅពេលព្រឹកមួយ គឺពេលនោះម្តាយរបស់គាត់ទៅយកអំបិលដែលដូរបានដើម្បីយកទៅដូរម្ហូបខ្លះ តែពេលទៅបើកយកអំបិលនៅកន្លែងដែលលាក់ទុក ស្រាប់តែមានអ្នកផ្សេងមកលួចអំបិលទាំងនោះអស់រលីង ។ នេះជាការបាត់បង់ដ៏គួរឲ្យសោកស្តាយមួយសម្រាប់គ្រួសារ តាំងកួយ ព្រោះអំបិលនៅពេលនោះគឺពិតជាមានសារសំខាន់ខ្លាំងណាស់ក្នុងរយៈពេលជាងពីរឆ្នាំដែល តាំងកួយ ធ្វើការនៅក្នុងកងកុមារភូមិសូភី ។

នៅចុងឆ្នាំ១៩៧៧ តាំងកួយ មានវ័យ និងកម្ពស់ខ្ពស់បន្តិចអង្គការក៏បានចាត់តាំងគាត់ឲ្យទៅធ្វើនៅក្នុងកងចល័តយុវជនភូមិសូភីវិញ ដោយមិនបានទៅធ្វើការទីណាឆ្ងាយពីភូមិទេ ។ ចំពោះការងារទៀតសោត មានការលំបាកជាងកងកុមារឆ្ងាយណាស់ គឺត្រូវទៅលើកទំនប់ ជីកប្រឡាយ និងលើកភ្លឺស្រែ ហើយត្រូវអង្គការកំណត់ឲ្យធ្វើឲ្យបានគ្រប់ផែនការសម្រាប់មួយថ្ងៃៗ បើធ្វើមិនហើយទេត្រូវតែនៅធ្វើរហូតដល់ហើយ ទើបមានសិទ្ធិសម្រាកនិងហូបបបរ ។ ពិតជារឿងពិបាកណាស់សម្រាប់យុវជន ដែលត្រូវការហូប និងសម្រាកគ្រប់គ្រាន់ ប៉ុន្តែនៅក្នុងរបបខ្មែរក្រហមការហូប និងការសម្រាកគ្រប់គ្រាន់ គឺពិតជាមិនអាចទៅរួចទេម្នាក់ៗត្រូវធ្វើការជាច្រើនម៉ោងដើម្បីប្តូរមកវិញនូវរបបអាហារដ៏តិចតួចបំផុត ។ ជាក់ស្តែងដូចជា តាំងកួយ នៅម៉ោងសម្រាកពីការងារ បានឆ្លៀតពេលលួចចូលទៅក្នុងព្រៃដើម្បីរកផ្លែឈើ ឬបន្លែណាដែលអាចហូបបាន ដើម្បីបំពេញបន្ថែមលើរបបអាហារដែលទទួលបានដ៏តិចនោះ ។ ថ្ងៃមួយ គាត់បានលួចចូលព្រៃ ហើយប្រទះឃើញផ្លែសង្ស័រដែលមានរាងល្អិតៗ ដូចផ្លែម្រេច និងមានរស់ជាតិផ្អែម ដោយសារតែស្រេកឃ្លានពេក គាត់ហូបអស់ជាច្រើន ជាហេតុធ្វើឲ្យគាត់ចុកពោះដេវរពុំរួច ហើយក៏បានអ្នកនៅកងជាមួយគ្នាសែងយកមកសម្រាកនៅកង រហូតដល់ល្ងាចទើបធូរស្រាល និងអាចទៅធ្វើការបានវិញ ។

នៅដើមឆ្នាំ១៩៧៩ នៅក្នុងភូមិសូភី មានការច្របូលច្របល់ជាខ្លាំង តាំងកួយ ឃើញប្រជាជនមកពីភូមិផ្សេងៗបានធ្វើដំណើរកាត់តាមភូមិរបស់គាត់ ។ ចំណែកប្រធានភូមិ និងកម្មាភិបាលខ្មែរក្រហមនៅភូមិរបស់គាត់ខ្លះបាននាំគ្រួសាររត់ ហើយអ្នកខ្លះទៀត ត្រូវបានសម្លាប់ដោយកំហឹងរបស់ប្រជាជន ។ ស្ថានភាពនៅពេលនោះ គឺលែងមានអង្គការចាត់តាំងអ្វីទៀតហើយ ម្នាក់ៗឈប់ធ្វើការ និងធ្វើដំណើរពីភូមិមួយទៅភូមិមួយដើម្បីស្វែងរកគ្រួសារ និងញាតិមិត្តរបស់ខ្លួន ។ ក្រោយមកទើបគាត់ដឹងថា កងទ័ពវៀតណាមបានរំដោះ និងទទួលជោគជ័យលើខ្មែរក្រហមទាំងស្រុង ។ ប៉ុន្មានថ្ងៃក្រោយមក គ្រួសាររបស់ តាំងកួយ ទាំងអស់បានជួបជុំគ្នាវិញ ដោយមិនមានបាត់បង់សមាជិកណាម្នាក់ឡើយ ហើយក៏បាននាំគ្នាធ្វើដំណើរមកកាន់ភូមិភ្នៀតដែលជាផ្ទះ និងស្រុក

កំណើតរបស់ខ្លួនវិញ ។ នៅតាមផ្លូវធ្វើដំណើរត្រឡប់មកផ្ទះ គាត់បានឃើញសាកសពជាច្រើន ដែលជាជនស៊ីវិល និងកម្មាភិបាលខ្មែរក្រហម ។ គាត់គិតថា ខ្មែរក្រហមខ្លះអាចត្រូវបានកងទ័ពវៀតណាមសម្លាប់ ហើយខ្លះទៀតអាចត្រូវបានប្រជាជនសម្លាប់ដោយសារកំហឹង និងការសងសឹកចំពោះការធ្វើបាបដែលអ្នកទាំងនោះប្រព្រឹត្តក្នុងអំឡុងពេលដែលគ្រប់គ្រងអំណាច ។ តាំងកួយ និងគ្រួសារបានចំណាយពេលមួយថ្ងៃកន្លះទើបទៅដល់ផ្ទះ ។ ប៉ុន្តែពេលទៅដល់ ផ្ទះរបស់គាត់ត្រូវខ្មែរក្រហមកាត់សសរចេញអស់ ។ គ្រួសាររបស់គាត់បានរៀបចំផ្ទះជាថ្មី និងចាប់ផ្តើមកសាងជីវិតថ្មីដោយបាតដៃទទេជាមួយនឹងរបរជាកសិករដដែល ។

ប៉ុន្មានឆ្នាំក្រោយ ដោយស្រឡាញ់ការសិក្សា តាំងកួយ បានចូលរៀននៅសាលាភូមិភ្លៀត ហើយបានបន្តការសិក្សារហូតដល់បញ្ចប់ថ្នាក់បាក់ឌុប ។ បន្ទាប់មក គាត់បានប្រលងចូលធ្វើការនៅមន្ទីរឃោសនាការ និងព័ត៌មាន ដោយធ្វើការនៅផ្នែករដ្ឋបាល ។ នៅឆ្នាំ១៩៩៨ មន្ទីរបានបំបែកចេញជាពីរ គឺមន្ទីរឃោសនាការ និងមន្ទីរវប្បធម៌ ហើយ តាំងកួយ ក៏ផ្លាស់មកធ្វើនៅខាងមន្ទីរវប្បធម៌វិញ ។

សព្វថ្ងៃនេះ តាំងកួយ រស់នៅក្រុងសេរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។ ពីអតីតកុមារម្នាក់ក្នុងរបបខ្មែរក្រហម មកជាប្រធានការិយាល័យសារមន្ទីរខេត្តបន្ទាយមានជ័យ ក្រោយពីការខិតខំតស៊ូរៀនសូត្រ និងធ្វើការងាររអស់រយៈពេលជាច្រើនឆ្នាំមក ។ គាត់មានប្រពន្ធ និងមានកូនប្រុសស្រីបីនាក់ ។ ចំពោះតាំងកួយ ផ្ទាល់ ការដែលនិយាយពីប្រវត្តិសាស្ត្រខ្មែរក្រហមទៅកាន់ក្មេងៗជំនាន់ក្រោយ គឺពិតជាមានសារសំខាន់ខ្លាំងណាស់ ។ ប្រវត្តិសាស្ត្រខ្មែរក្រហមគឺជាប្រវត្តិសាស្ត្រដ៏ឈឺចាប់មួយសម្រាប់ប្រជាជាតិកម្ពុជាដែលមិនអាចបំភ្លេចបាន ។ ជារឿងពិតមួយសម្រាប់ តាំងកួយ ផ្ទាល់ នៅពេលដែលគាត់លើកយកប្រវត្តិនិងជីវិតរស់នៅក្នុងខ្មែរក្រហមមកនិយាយប្រាប់កូន ហើយកូនៗតែងតែសើច និងនិយាយថាមិនជឿនោះទេ ដោយលើកឡើងថាមិនដែលមានមនុស្សឯណាសម្លាប់និងធ្វើបាបមនុស្ស ដូចគ្នាយ៉ាងព្រៃផ្សៃដូចនេះទេ ។ ប៉ុន្តែក្រោយពីគាត់ខស្សាហ៍និយាយ និងការដែលពុកពីចាស់ទុំដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមនិយាយប្រាប់ការដឹងតាមរយៈប្រព័ន្ធផ្សព្វផ្សាយនានា ជាក់ស្តែងដូចជាតុលាការខ្មែរក្រហម ជាពិសេស តាមរយៈលោកគ្រូអ្នកគ្រូដែលគាត់ធ្លាប់ឆ្លងកាត់ និយាយប្រាប់ និងមាននៅក្នុងសៀវភៅសិក្សា ទើបកូនៗរបស់គាត់ជឿថា ពិតជាមានរបបខ្មែរក្រហម និងមានការកាប់សម្លាប់ដូចនោះមែន ។

**ផាង សារៈមុនិន្ទ**

## អានទស្សនាវដ្តីតាមគេហទំព័រ

ទស្សនាវដ្តីស្វែងរកការពិតទាំងអស់ត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ http://d.dccam.org/Projects/Magazines/Magazine_Searching.htm ។ ព័ត៌មានបន្ថែម សូមទាក់ទង ញាណ សុជាតិ ទូរស័ព្ទលេខ ០១៦ ៨៧៦ ៦៩២ ឬ ០២៣ ២១១ ៨៧៥ ។

## ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាមានកម្មវិធីសំឡេងអំពើប្រល័យពូជសាសន៍ ៖ យុត្តិធម៌ និងការអត់ឃ្លាន ដែលចាប់ផ្តើមផ្សាយពីថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៣ រៀងរាល់ថ្ងៃអាទិត្យ ។

ប្រិយមិត្តដែលរស់នៅរាជធានីភ្នំពេញ និងនៅខេត្តអាចស្តាប់កម្មវិធីវិទ្យុសហគមន៍របស់យើងខ្ញុំតាមរយៈ ៖

◆ វិទ្យុជាតិកម្ពុជា AM 918KHz រាជធានីភ្នំពេញ វេលាម៉ោង៩ព្រឹក និងម៉ោង៧និង៣០នាទីល្ងាច ។

◆ វិទ្យុខេត្តកំពត FM 93.25 MHz វេលាម៉ោង៧ព្រឹក និងម៉ោង៧ល្ងាច ។

◆ វិទ្យុខេត្តព្រះវិហារ FM 99 MHz វេលាម៉ោង៧:៣០ព្រឹក និងម៉ោង៤រសៀល ។

◆ វិទ្យុខេត្តបាត់ដំបង FM 103.25 MHz វេលាម៉ោង៨ព្រឹក និងម៉ោង៤រសៀល ។

# រឿងរ៉ាវដែលខ្ញុំនៅចាំ

សី ទូច ជាអនុប្រធានមន្ទីរវប្បធម៌ និងសិល្បៈខេត្តមណ្ឌលគិរី ទទួលបន្ទុកសារមន្ទីរ ។ ទូច មានអាយុបានប្រាំមួយខែប៉ុណ្ណោះ មុនពេលខ្មែរក្រហមធ្លាក់ពីអំណាចនៅខែមករា ឆ្នាំ ១៩៧៩ ។ ប៉ុន្តែ ទោះបីពេលនោះគាត់នៅក្មេងក៏ដោយ ក៏គាត់នៅចងចាំពីរឿងរ៉ាវក្រុមគ្រួសារតាមការពណ៌នាប្រាប់ពីឪពុកម្តាយ និងបងប្អូនគាត់ដែរ ។

ទូច កើតនៅភូមិតាកែវ ឃុំពាមមុន្ទា ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ។ គាត់ជាកូនទីបួនក្នុងចំណោមបងប្អូនបង្កើតទាំងអស់ប្រាំពីរនាក់ ។ ទូច មានឪពុកឈ្មោះ សី ប៊ុន្នី ដែលរៀនបានដល់ថ្នាក់ឌីប្លូម នៅវិទ្យាល័យកំពង់ត្របែក ។ នៅពេលរដ្ឋប្រហារឆ្នាំ ១៩៧០ ឪពុក ទូច បានឈប់រៀន រួចហើយរៀបការជាមួយនឹងម្តាយគាត់ឈ្មោះ កៅយ៉ាត ដែលត្រូវជាប្អូនបង្កើតមិត្តភក្តិរួមថ្នាក់ជាមួយឪពុកគាត់ ។


សី ទូច

ក្រោយពីរៀបការរួច ឪពុករបស់ ទូច បានប្រកបរបរធ្វើស្រែ ដោយឡែកបងប្អូនខាងឪពុក ម្តាយគាត់បានចូលធ្វើទាហានលន់ នល់ ដើម្បីវាយជាមួយចលនាកុម្មុយនិស្តខ្មែរក្រហម ។

ទូច នៅចាំថា គាត់មានបងប្អូនជាច្រើន ព្រោះជីតាខាងឪពុកគាត់ឈ្មោះ សី មានប្រពន្ធច្រើន និងមានកូនរហូតដល់ទៅជិត ២០នាក់ ដែលក្រោយពីរបបខ្មែរក្រហមដួលរលំទៅ កូនគាត់នៅរស់តែប្រាំនាក់ប៉ុណ្ណោះ ។ តាសី បានចូលធ្វើទាហានជើងក្រហមបារាំងក្នុងសម័យប្រទេសកម្ពុជាស្ថិតនៅក្រោមអាណានិគមបារាំង ហើយជីតាគាត់ធ្លាប់ជិះកប៉ាល់ទៅប្រយុទ្ធរហូតដល់ប្រទេសបារាំង នៅក្នុងសម័យសង្គ្រាមលោកលើកទី២ ។

ក្រោយពេលត្រឡប់មកប្រទេសកម្ពុជាវិញ ជីតារបស់ ទូច ត្រូវបានអ្នកភូមិជាច្រើនគោរព រាប់អាន និងស្រឡាញ់គាត់ ។ ព្រមជាមួយនោះ តាសី ក៏ចេះវិជ្ជាមន្តអាគមដែលធ្វើឲ្យគាត់កាន់តែមានឈ្មោះល្បីនៅក្នុងចំណោមអ្នកស្រុកទៀត ។ មានថ្ងៃមួយចោរបានមកលួចគោគាត់ដែលចងនៅខាងក្រោមផ្ទះ ប៉ុន្តែចោរនោះមិនបានដឹកគោចេញផុតពីភូមិទេ ដោយសារតែគាត់បានដាក់មន្តអាគមធ្វើឲ្យចោរវង្វេងផ្លូវ ។

មុនពេល តាសី ស្លាប់ គាត់បានផ្ទេរចំណេះដឹងទាំងអស់ឲ្យអ៊ំប្រុសរបស់ ទូច ឈ្មោះ សី សារិ (ម្តាយផ្សេងគ្នាពីឪពុករបស់ ទូច) ។ ព្រមជាមួយនោះ អ៊ំប្រុសរបស់ ទូច ក៏ចេះក្បាច់គុណថែមទៀត ហើយនៅក្នុងសម័យខ្មែរក្រហម ដោយសារការគាបសង្កត់ខ្លាំង គាត់បានវាយឈ្លបខ្មែរក្រហមម្នាក់នៅក្នុងភូមិឲ្យមានរបួស រួចហើយក៏រត់គេចខ្លួន ។ ប៉ុន្តែក្រោយមក អ៊ំប្រុសរបស់គាត់ត្រូវបានយោធាខ្មែរក្រហមចាប់ខ្លួនបាន រួចហើយយកគាត់ទៅធ្វើទារុណកម្មយ៉ាងសាហាវឃោរឃៅ ។ ដោយសារទ្រាំទ្រនឹងការឈឺចាប់នោះមិនបាន អ៊ំប្រុសរបស់គាត់ក៏បានស្នើឲ្យយោធាខ្មែរក្រហមបាញ់សម្លាប់គាត់ចោលតែម្តង ។

ចំណែកជីតាខាងម្តាយរបស់ ទូច ឈ្មោះ តាញឹម ក៏មានប្រពន្ធពីរដែរ ។ តាញឹម មានទ្រព្យសម្បត្តិ និងដីស្រែរាប់រយហិកតាដែលដីមួយផ្នែកគាត់បានធ្វើអំណោយទៅវត្តតាកែវ ហើយដីនោះ បានបន្សល់កេរដំណែលរហូតមកដល់សព្វថ្ងៃ ដែលអ្នកភូមិតែងហៅថាកេរ្តិ៍ “តាញឹម” ។ តាញឹម មានកូនប្រុសម្នាក់ឈ្មោះ

ឡុច ត្រូវជាអ៊ំប្រុសខាងម្តាយរបស់ (ទូច) បានបួសរៀននៅវត្តអំពិល ក្នុងស្រុកកំពង់ត្របែក ហើយដោយសារគាត់រៀនពូកែ គាត់ក៏បានបន្តទៅរៀននៅភ្នំពេញ ។ ប៉ុន្តែក្រោយពេល របបខ្មែរក្រហមឡើងកាន់អំណាចគាត់បានបាត់ខ្លួនរហូត ។ ដោយសារមានជីតា និងបងប្អូនច្រើនដូច្នេះ ទើបមានអ្នកភូមិស្គាល់ឪពុកម្តាយរបស់ ទូច យ៉ាងច្បាស់ ។

ឪពុករបស់ ទូច បានមករស់នៅខាងម្តាយគាត់គឺនៅផ្ទះតាញឹម ។ នៅទីនោះជារឿយមានព្រឹត្តិការណ៍វាយប្រយុទ្ធគ្នារវាងទាហាន លន់ នល់ និងចលនាតស៊ូខ្មែរក្រហម ដូច្នេះឪពុកម្តាយគាត់តែងតែរត់គេចទៅក្រៅភូមិរហូតដល់ព្រឹត្តិការណ៍ស្ងប់ស្ងាត់ទើបត្រឡប់មកផ្ទះវិញ ។ ស្របពេលនោះ ឪពុកម្តាយគាត់ក៏ភ័យខ្លាចចំពោះទាហានវៀតកុង ដែលម្តងម្កាលបានចូលក្នុងភូមិដែរ ។

ជាញឹកញាប់ ឪពុកម្តាយ ទូច បានព្រួសំឡេងផ្ទុះគ្រាប់កាន់តែច្រើនឡើងនៅក្តួមសំណារ ដែលស្ថិតនៅជាប់នឹងព្រំប្រទល់ប្រទេសវៀតណាម, នៅអ្នកលឿង, ទន្លេតូច, រកាកោង និងនៅតាមបណ្តោយដងទន្លេមេគង្គ ដោយពេលនោះបងប្អូនខាងឪពុកម្តាយគាត់ក៏ត្រូវឡើងទៅប្រយុទ្ធដែរ ។ ទូច មានអ៊ំប្រុស (ខាងម្តាយ) ម្នាក់ឈ្មោះ កៅ ឡាយ ធ្វើទាហានពាក់សក្តិពីរខាង លន់ នល់ នៅជាមួយឧត្តមសេនីយ៍ ស្រី មាស ដែលតែងតែជិះឧទ្ធម្ភាគចក្រចុះមកធ្វើការងារនៅអ្នកលឿង ធ្វើឲ្យអ្នកភូមិកាន់តែស្គាល់ឪពុកម្តាយ និងក្រុមគ្រួសារគាត់ច្បាស់ថែមទៀត ។

រហូតកងទ័ពដល់ពេលយោធាខ្មែរក្រហមទទួលជ័យជម្នះ ឪពុកម្តាយរបស់ ទូច បានរស់នៅក្នុងភូមិឃុំដដែល ព្រោះខ្មែរក្រហមបានចាត់ទុកគ្រួសារគាត់ជាអ្នកមូលដ្ឋាន ទោះបីគាត់មានបងប្អូនធ្វើជា ទាហាន លន់ នល់ ក៏ដោយ ។ មូលហេតុដែលសម្រេចដូច្នេះ ព្រោះតែខ្មែរក្រហមដែលគ្រប់គ្រងនៅតំបន់នោះសុទ្ធតែធ្លាប់ស្គាល់ រាប់អានក្រុមគ្រួសារ និងបងប្អូនរបស់ ទូច ។

ខ្មែរក្រហមបានចាត់តាំងឪពុករបស់ ទូច ឲ្យភ្ជួរស្រែ ដឹកកណ្តាប់ និងបរទេះដឹកស្រូវ ហើយម្តាយគាត់ស្ទូងស្រូវ និងលាយដីលាមកសត្វដាក់ស្រែ ។ រីឯបងប្រុសរបស់គាត់ ខ្មែរក្រហមបញ្ជូនទៅកងឃ្វាលគោ និងចិញ្ចឹមទា និងបានអនុញ្ញាតឲ្យត្រឡប់មករស់នៅជុំឪពុកម្តាយវិញ ក្រោយពេលធ្វើការងាររួច ។ ចំណែករបបអាហារនៅពេលនោះ ឪពុកម្តាយរបស់ ទូច បានហូបគ្រប់គ្រាន់ គឺក្នុងមួយថ្ងៃហូបបីពេល លើកលែងតែពេលប្តូរប្រធានរោងបាយ




(រូបឈរទីពីរាប់ពីឆ្វេង) សី ទូច ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការចងក្រងឯកសារ និងការចុះបញ្ជីសារពើភ័ណ្ឌ ដែលប្រារព្ធធ្វើនៅខេត្តសៀមរាប កាលពីថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៣

សហករណ៍ (ព្រោះពេលនោះ ខ្មែរក្រហមបានផ្លាស់ប្តូរវេនប្រធានវេនបាយជាញឹកញាប់) ឈ្មោះ តាឡាច មកគ្រប់គ្រងមួយរយៈខ្លីប៉ុណ្ណោះ ។ តាឡាច ជាមនុស្សម៉ឺងម៉ាត់ ហើយកាចដូច្នេះហើយទើបអ្នកភូមិមួយចំនួនខ្លាចគាត់ ។ គាត់តែងតែបញ្ជាចុងភៅឲ្យស្ងោរត្រកួនដង្ហែលៗឲ្យហូប ប៉ុន្តែគាត់មិនដែលរករឿងក្រុមគ្រួសាររបស់ ទូច ទេ ។

នៅពេលនោះ ក៏មានការបាត់ខ្លួនមនុស្សជាញឹកញាប់ដោយមិនដឹងពីមូលហេតុដែរ ។ ក្រោយមកទើបឪពុករបស់ ទូច ដឹងថាខ្មែរក្រហមមានកន្លែងឃុំឃាំងមួយ នៅទីប្រជុំជនកំពង់ត្របែក និងកន្លែងសម្លាប់មនុស្សមួយដែលអ្នកភូមិតែងហៅថា "វាលម្រេញ" ដែលនៅជាប់ឈ្មោះរហូតដល់សព្វថ្ងៃ ។ ប៉ុន្តែឪពុក ទូច មិនដឹងថាអ្នកបាត់ខ្លួននោះមានកំហុសអ្វីនោះទេ ។

នៅថ្ងៃមួយ ឪពុករបស់ ទូច បានឃើញប្រធានសហករណ៍ភូមិឈ្មោះ ហ៊ួយ ដែលមានសម្បុរស និងមាឌធំខ្ពស់ បានរំលោភនារីម្នាក់នៅក្នុងភូមិ ហើយជាញឹកញាប់ឪពុកគាត់ឃើញ ហ៊ួយ ប្រព្រឹត្តទៅលើនារីផ្សេងៗ ។ ចំពោះនារីមួយចំនួនដែល ហ៊ួយ រំលោភហើយបានបាត់ខ្លួនតែម្តង ។ ហេតុការណ៍នោះ ឪពុករបស់ ទូច មិនបាននិយាយប្រាប់ទៅអ្នកភូមិផ្សេងទៀតទេ ទោះបីរបបខ្មែរក្រហមដួលរលំទៅហើយក៏ដោយ ព្រោះ ហ៊ួយ នៅមានតួនាទីជាឈ្លបឃុំ ។ ចំណែក ទូច ក្រោយពេលបានដឹងរឿងនេះតាមរយៈឪពុកគាត់រៀបរាប់ប្រាប់ គាត់តែងតែមានអារម្មណ៍ភ័យខ្លាច ហ៊ួយ ពេលដែលជួបគាត់នៅក្នុងភូមិម្តង ។

រហូតដល់កណ្តាលឆ្នាំ១៩៧៨ ឪពុករបស់ ទូច ត្រូវបានយោធាខ្មែរក្រហមចាប់យកទៅឃុំនៅមន្ទីរសន្តិសុខកំពង់ត្របែក ដោយមិនដឹងមូលហេតុ ចំពេលដែលម្តាយគាត់កំពុងមានទម្ងន់កូនទីបួន គឺ ទូច ។ ទូច បានកើតនៅខែកញ្ញា ឆ្នាំ១៩៧៨ ដោយមានឆ្មបបុរាណម្នាក់ឈ្មោះ ជិម ជាអ្នកជួយម្តាយគាត់ ។ ទូច កើតចំពេលដែលមានទឹកជំនន់ឡើងខ្លាំង និងស្របពេលដែលម្តាយគាត់កំពុងកើតទុក្ខដោយសារបាត់បង់ប្តី ។ ម្តាយ ទូច មិនដែលសង្ឃឹមថាបានជួបមុខប្តីវិញទេ ប៉ុន្តែក្រោយពេលខ្មែរក្រហមដួលរលំនៅដើមឆ្នាំ១៩៧៩ ស្រាប់តែឃើញប្តីត្រឡប់មកផ្ទះវិញ ព្រមជាមួយនោះក៏ឃើញបងប្អូនជាច្រើននាក់ដែលធ្វើទាហាន លន់ នល់ បានត្រឡប់មកភូមិវិញដែរ ។

ទូច បានជួបជុំឪពុកម្តាយ និងប្អូនរបស់គាត់ទាំងអស់ឡើងវិញ ។ ក្រោយមក ឪពុកគាត់ត្រូវ បានអ្នកភូមិជ្រើសរើសឲ្យធ្វើជាគ្រូបង្រៀននៅសាលាបឋមសិក្សាតាកែវ ហើយ ទូច ក៏បានចូលរៀន នៅទីនោះដែរ ។ ទូច បានរៀនបន្តនៅវិទ្យាល័យកំពង់ត្របែក ក្រោយមកគាត់បានមករៀនបន្តយកបរិញ្ញាបត្រនៅភ្នំពេញ ។

បច្ចុប្បន្ន ទូច ជាអនុប្រធានមន្ទីរវប្បធម៌ ខេត្តមណ្ឌលគិរី ទទួលបន្ទុកសារមន្ទីរដែលនឹងគ្រោងបង្កើតឲ្យមានឡើងនៅពេលឆាប់ៗខាងមុខ ។ ទូច ចង់ឲ្យប្រជាជននិយាយរឿងរ៉ាវពីរបបខ្មែរក្រហមឲ្យកាន់តែច្រើនដើម្បីឲ្យក្មេងជំនាន់ក្រោយបានដឹង និងចងចាំដូចជាវត្ថុបេតិកភណ្ឌរបស់ជាតិដែរ ។ **សោម ប៊ុនថន**

# ដំណឹងស្វែងរកប្អូន

នាងខ្ញុំឈ្មោះ ហង្ស ហួន និងប្តីឈ្មោះ សរ មឿន រស់នៅភូមិត្រពាំងសំរិត សង្កាត់គងនយ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។ នាងខ្ញុំសូមប្រកាសរកប្អូនពីរនាក់ គឺ : ◆ ប្អូនស្រី ហង្ស ហ៊ឹម និងប្តីឈ្មោះ មុំ ភីន ។ អ្នកទាំងពីរមានកូនបួននាក់ ទី១) ស្រីញឹប, ទី២) សុភី, ទី៣) សុផាត និង ទី៤) អាចក់ ◆ ប្អូនប្រុស ហង្ស សំណាង ហៅ គ្រឹម និងប្រពន្ធឈ្មោះ សយ ឃឿន ។ អ្នកទាំងពីរមានកូនពីរនាក់ ទី១) ណាក់ និង ទី២) ណូត ។

សូមបញ្ជាក់ថា គ្រួសារប្អូនៗទាំងពីរបែកគ្នាជាមួយនាងខ្ញុំនៅម្តុំអូរបែកក្អមក្នុងឆ្នាំ១៩៧៥ ក្រោយពេលដែលខ្មែរក្រហមរំដោះបានទីក្រុងភ្នំពេញ ។ មួយរយៈក្រោយមកនាងខ្ញុំឮដំណឹងថា គ្រួសារប្អូនទាំងពីរត្រូវខ្មែរក្រហមជម្លៀសទៅខេត្តបាត់ដំបង ប៉ុន្តែមិនដឹងថាទៅនៅភូមិស្រុកអ្វីនោះទេ ហើយក៏បាត់ដំណឹងរហូតមកដល់ពេលនេះ ។

អាស្រ័យហេតុនេះ បើបងប្អូនណាបានដឹង ឬស្គាល់ឈ្មោះដែលបានរៀបរាប់ខាងលើសូមទំនាក់ទំនងតាមរយៈអាសយដ្ឋានផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ, រាជធានីភ្នំពេញ ឬតាមរយៈទូរស័ព្ទលេខៈ ០១៦ ៨៩៦ ៦៩២ ។ ***សូមអរគុណ!***

# ថ្នាក់រៀននៅទួលស្លែង

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតថ្នាក់រៀនសាធារណៈមួយនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០១១ ដោយមានកិច្ចសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងវប្បធម៌ វិចិត្រសិល្បៈ ។ សារមន្ទីរទួលស្លែងគឺជាអតីតសាលារៀនដ៏ទំនើបមួយដែលបានសង់ឡើងជាលើកដំបូងនៅក្នុងឆ្នាំ១៩៦២ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានប្រែក្លាយសាលារៀននេះទៅជាគុកដ៏សម្ងាត់បំផុតមួយក្នុងចំណោមគុកចំនួន១៩៦ទូទាំងប្រទេស ។ អ្នកទោសភាគច្រើនដែលត្រូវបញ្ជូនទៅទួលស្លែងគឺជាកម្មាភិបាលខ្មែរក្រហមដែលត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើក្បត់ជាតិ ដូចជា ការសហការជាមួយរដ្ឋាភិបាលបរទេស ឬធ្វើជាអ្នកស៊ើបការណ៍ឲ្យសេ.អ៊ី.អា ឬ កា.ហ្គេ.បេ ជាដើម ។



ចាប់តាំងពីការប្រែក្លាយពីកន្លែងរៀនសូត្រមួយទៅជាកន្លែងដ៏គួរឲ្យរន្ធត់និងមហន្តរាយមួយ ទួលស្លែងមិនដែលទទួលបានមុខងាររបស់ខ្លួនដូចកាលពីដើមវិញឡើយ ។ ទោះជាយ៉ាងនេះក្តី នៅពេលអនាគតដើម្បីទាមទារមកវិញនូវកេរដំណែលអប់រំដែលមានលក្ខណៈវិជ្ជមានរបស់ទួលស្លែង និងដើម្បីបន្ថែមសមាសភាពអប់រំមួយទៅក្នុងសារមន្ទីរនេះ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងដើម្បីផ្តល់ការបង្រៀន និងការពិភាក្សាដោយឥតគិតថ្លៃអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហម និងប្រធានបទដែលជាប់ទាក់ទងដូចជា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ថ្នាក់រៀននេះក៏ជាវេទិកាសាធារណៈមួយសម្រាប់ឲ្យអ្នកមកទស្សនា និងអ្នកដែលនៅរស់រានមានជីវិតចែករំលែកព័ត៌មានគ្នាក្នុងការថែរក្សារយៈកាលនៃប្រវត្តិសាស្ត្រកម្ពុជាដ៏មានសារសំខាន់មួយទុកឲ្យអ្នកជំនាន់ក្រោយបានរៀនសូត្រ ។

បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដែលមានសញ្ញាបត្រមកពីបរទេស និងបានទទួលវិញ្ញាបនបត្រពីក្រសួងអប់រំ យុវជន និងកីឡា ផ្នែកការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-៧៩) ព្រមទាំងមានការចូលរួមពីអ្នកជំនាញជាតិនិងអន្តរជាតិដែលមានជំនាញលើប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងអ្នកដែលនៅរស់រានមានជីវិតពីមន្ទីរស-២១ នឹងបង្រៀននៅថ្នាក់រៀននេះ ។ ព័ត៌មានទាក់ទងនិងថ្នាក់រៀននេះ សូមទាក់ទង ស៊ុំ សារីណា តាមរយៈទូរស័ព្ទលេខៈ ០២៣ ២១១ ៨៧៥ ។

**◆ ទីកន្លែង : អាគារ "ក" ជាន់លើ**

**◆ ពេលវេលា : ច័ន្ទ ២-៣រសៀល, ពុធ ៩-១០ព្រឹក, សុក្រ ២-៣រសៀល**

# ការអត់ឃ្លាន និងការស្លាប់ហួសប្រមាណ

## សំឡេងយុត្តិធម៌ ៖ អំពើប្រល័យពូជសាសន៍ និងការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហម

***កម្មវិធីវិទ្យុសហគមន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា (វគ្គទី២)***

*ការផ្សាយវគ្គទីពីរនេះ ផ្តោតទៅលើប្រវត្តិដើមដំបូងនៃការធ្វើឲ្យមានការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហម ទស្សនៈផ្សេងៗអំពីមូលហេតុដែលបណ្តាលឲ្យមានការស្លាប់ហួសប្រមាណ ក៏ដូចជាហេតុផលមួយចំនួនដែលអ្នកស្រាវជ្រាវជាច្រើនមានការពិបាកក្នុងការកំណត់ថា តើមានប្រជាជនចំនួនប៉ុន្មាននាក់ដែលបានស្លាប់ដោយសារការអត់ឃ្លាននៅក្នុងប្រទេសកម្ពុជាចន្លោះពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ។*

*មុននឹងយើងចាប់ផ្តើមបទអត្ថាធិប្បាយវគ្គទីពីនេះ យើងខ្ញុំសូមជម្រាបជូនប្រិយមិត្តអ្នកស្តាប់អំពីការវិវឌ្ឍរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ រយៈពេលថ្មីៗកន្លងមកនេះ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមបានចេញសេចក្តីសម្រេចបដិសេធការបំបែកសំណុំរឿង០០២ទៅជាសំណុំរឿងតូចៗ ។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងមិនបានផ្តល់មូលហេតុសមរម្យ ក្នុងការសម្រេចបំបែកសំណុំរឿង០០២ទៅជាសំណុំរឿង តូចៗនោះទេ នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងកំពុងផ្តោតទៅលើតែរចនាសម្ព័ន្ធដឹកនាំនៅក្នុងរបបខ្មែរក្រហម និងឧក្រិដ្ឋកម្មទាំងឡាយដែលកើតឡើងដោយសារការជម្លៀសប្រជាជនចេញពីទីក្រុង និងទីប្រជុំជននានា ។ បច្ចុប្បន្ន អង្គជំនុំជម្រះសាលាដំបូងកំពុងដំណើរការកាត់សេចក្តីលើសំណុំរឿងមួយចេញពីសំណុំរឿង០០២ ។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការសម្រេចចិត្តបំបែកសំណុំរឿងរបស់ខ្លួនមានសារសំខាន់ចំពោះភាគីទាំងអស់នៅក្នុងសំណុំរឿង ។ ទន្ទឹមនឹងគ្នានេះដែរ សហព្រះរាជអាជ្ញាបានស្នើសុំអង្គជំនុំជម្រះសាលាដំបូងបញ្ចូលបទចោទប្រកាន់ទាក់ទងនឹងគុកទួលស្លែងទៅក្នុង*



*ប្រជាជនកំពុងរងការអត់ឃ្លានក្រោយរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ ។ ប្រជាជនទាំងនេះបានធ្វើដំណើរត្រឡប់ទៅកាន់លំនៅដ្ឋានវិញក្រោយពីចាកឆ្ងាយពីស្រុកកំណើតអស់រយៈពេលជិតបួនឆ្នាំ ។ នៅក្នុងរូបថតនេះ ប្រជាជនកម្ពុជាមួយក្រុមកំពុងឈប់សម្រាកតាមផ្លូវនិងជួបជាមួយទាហានវៀតណាម ។ រូបនេះថតដោយក្រុមអ្នកសារព័ត៌មានវៀតណាមក្នុងខែមករា ឆ្នាំ១៩៧៩ នៅខេត្តកំពង់ចាម ។ (បណ្ណសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា)*

សំណុំរឿងតូចនេះ ។ ប៉ុន្តែ មេធាវីការពារជនជាប់ចោទបានបដិសេធរាល់ការបញ្ចូលបទចោទប្រកាន់បន្ថែមទៅក្នុងសំណុំរឿងតូចនៃសំណុំរឿង០០២ ។ ជាងនេះទៅទៀត ការសម្រេចចិត្តបំបែកសំណុំរឿង០០២ទៅជាសំណុំរឿងតូចៗ បានប៉ះពាល់ដល់ផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀតដែលសំណុំរឿងរបស់ខ្លួនមិនមានការពាក់ព័ន្ធទៅនឹងសំណុំរឿងតូចនៃសំណុំរឿង០០២ ដែលកំពុងដំណើរការសព្វថ្ងៃ ។ ដើមបណ្តឹងរដ្ឋប្បវេណីដែលសំណុំរឿងរបស់ខ្លួនមិនមានការពាក់ព័ន្ធនឹងសំណុំរឿងតូចនេះត្រូវរង់ចាំទំរាំដល់ការជំនុំជម្រះក្តីលើសំណុំរឿងថ្មីដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលខ្លួនស្នើសុំចូលរួមចាប់ផ្តើមដំណើរការ ។ ស្របពេលនឹងគ្នានេះដែរ សុខភាពរបស់ជនជាប់ចោទនៅក្នុងសំណុំរឿង ០០២ កំពុងតែស្ថិតក្នុងស្ថានភាពដែលគួរឲ្យព្រួយបារម្ភ ។ កាលពីថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣ អៀង សារី ឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងការបរទេសនៃរបបខ្មែរក្រហមបានស្លាប់នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ដោយសារជំងឺ ។

## សេចក្តីផ្តើម ៖ ខ្មែរក្រហម និងការសន្យាថាប្រជាជនគ្រប់រូបមានអាហារបរិភោគគ្រប់គ្រាន់

ស្រូវ ឬអង្ករ គឺជាប្រភេទចំណីអាហារដ៏សំខាន់មួយសម្រាប់ប្រជាជនកម្ពុជា ។ ដូច្នេះ នៅក្នុងកម្មវិធីវិទ្យុនេះ នៅពេលដែលនិយាយអំពីផលិតកម្មម្ហូបអាហារ គឺសំដៅលើផលិតកម្មស្រូវ ។

នៅដើមទសវត្សរ៍១៩៦០ ផលិតកម្មស្រូវនៅក្នុងប្រទេសកម្ពុជាមានការកើនឡើងជាលំដាប់ ។ នៅចន្លោះឆ្នាំ១៩៦៣ និងឆ្នាំ១៩៦៤ ប្រទេសកម្ពុជាអាចបង្កបង្កើនផលស្រូវបានពីរដងក្នុងមួយឆ្នាំ ហើយកម្ពុជាបាននាំផលស្រូវយ៉ាងច្រើនសន្ធឹកសន្ធាប់ទៅក្រៅប្រទេស ។ ប៉ុន្តែ នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៦០ដដែលនេះ ទោះបីជាផលិតផលស្រូវនៅក្នុងប្រទេសមានកម្រិតខ្ពស់យ៉ាងណាក៏ដោយ ក៏ការនាំចេញផលិតផលស្រូវបានធ្លាក់ចុះមកវិញ នៅពេលដែលផលិតផលស្រូវមួយចំនួនធំត្រូវបានឈ្មួញនាំចេញទៅប្រទេសវៀតណាម និងលក់ឲ្យភាគីទាំងសងខាងដែលចូលរួមនៅក្នុងសង្គ្រាមស៊ីវិល ។ ជាងនេះទៅទៀត នៅពេលដែលប្រទេសកម្ពុជាបានធ្លាក់ចូលក្នុងសង្គ្រាមស៊ីវិលនៅឆ្នាំ១៩៧០ ដំណាំស្រូវទទួលការប៉ះពាល់ដោយទឹកស្ទានមិនដល់ ។ ការដាំដុះ ការសាបព្រោះ និងសកម្មភាពបង្កបង្កើនផលស្រូវមួយចំនួនមានការធ្លាក់ចុះនៅពេលដែលមានសង្គ្រាមរវាងរដ្ឋាភិបាល លន់ នល់ ជាមួយនឹងកម្លាំងខទ្មាំងខ្មែរក្រហម ។ ការទម្លាក់គ្រាប់បែកមកលើប្រទេសកម្ពុជានៅក្នុងរបប លន់ នល់ បានធ្វើឲ្យផលិតកម្មកសិកម្មកម្ពុជាកាន់តែថយចុះ ។ សកម្មភាពទម្លាក់គ្រាប់បែកនេះបានបំផ្លិចបំផ្លាញទីជនបទ ដីកសិកម្ម និងបានសម្លាប់ប្រជាកសិករ ព្រមទាំងសត្វពាហនៈដែលបម្រើដល់ការងារកសិកម្មអស់ជាច្រើន ។

ក្នុងអំឡុងពេលនៃសង្គ្រាមស៊ីវិល ខ្មែរក្រហមបានដឹងថា ប្រជាជនកម្ពុជាដែលរស់នៅទីជនបទពឹងផ្អែកទាំងស្រុងលើផលិតកម្មកសិកម្ម ។ ខ្មែរក្រហមបានប្រកាសថា បដិវត្តន៍របស់ខ្លួននឹងនាំមកនូវរបបថ្មីមួយ ដែលផលិតកម្មកសិកម្មមានការរីកចម្រើន ហើយដែលនៅពេលនោះប្រជាជនកម្ពុជានឹងមានម្ហូបអាហារគ្រប់គ្រាន់ ។ ជាឧទាហរណ៍ នៅក្នុងខ្សែភាពយន្តឃោសនាមួយរបស់ខ្មែរក្រហមដែលថតនៅឆ្នាំ១៩៧៣ នៅខេត្តកំពង់ចាម ដែលជាតំបន់រំដោះរបស់ខ្មែរក្រហម ខៀវ សំផន ដែលជាតំណាងខ្មែរក្រហមបានដឹកនាំគណៈប្រតិភូមួយក្រុមមកពីប្រទេសវៀតណាមខាងជើងធ្វើទស្សនកិច្ចទៅកាន់តំបន់កសិកម្មគំរូ ដែលបានបង្ហាញគណៈប្រតិភូទាំងនោះឲ្យឃើញថា ប្រទេសកម្ពុជាមានផលិតកម្មស្បៀងស្ទើរគ្រប់ទីកន្លែង ។ ខណៈពេលនោះដែរ ប្រជាជននៅក្នុងសហករណ៍បានញញឹមដាក់ម៉ាស៊ីនថតខ្សែភាពយន្តនៅពេលដែលកំពុងបោកបែនស្រូវ និងបំពេញការងារផ្សេងៗ ។ ប្រជាកសិករទាំងនោះ មើលទៅដូចជាមានសុខភាពល្អ និងទទួលបានអាហារបរិភោគគ្រប់គ្រាន់ ។

ការឃោសនានេះ និងការសន្យាក្នុងការធ្វើកំណែទម្រង់ដីធ្លីដើម្បីផ្តល់ដីបន្ថែមដល់កសិករក្រីក្រ គឺជាហេតុផលមួយក្នុងចំណោមហេតុផលជាច្រើនទៀត ដែលធ្វើឲ្យចលនារបស់ខ្មែរក្រហមមានប្រជាប្រិយភាពពីសំណាក់កសិករក្រីក្រនៅតាមទីជនបទ ។ ប្រជាប្រិយភាពនេះ និងការគ្រប់គ្រងតំបន់ផលិតស្បៀងអាហាររបស់ប្រទេសកម្ពុជាបានជួយខ្មែរក្រហមក្នុងការសម្រេចបាននូវជោគជ័យ ដោយសារខ្មែរក្រហមបានកាត់ផ្តាច់ការផ្គត់ផ្គង់ស្បៀងអាហារទៅកាន់តំបន់មួយចំនួនគ្រប់គ្រងដោយរបប លន់ នល់ ។

ខ្មែរក្រហមវាយឈ្នះរដ្ឋាភិបាល លន់ នល់ និងកាន់កាប់ទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ត្រឹមតែមួយ

សប្តាហ៍ប៉ុណ្ណោះ ប្រជាជននៅទីក្រុងភ្នំពេញស្ទើរតែទាំងអស់ត្រូវបានជម្លៀសចេញពីទីក្រុង ។ ប៉ុន្តែ មូលហេតុពិតប្រាកដនៃការជម្លៀសប្រជាជននេះ នៅតែមានភាពស្រពេចស្រពិលមិនច្បាស់លាស់រហូតដល់សព្វថ្ងៃនេះ ។ អៀង សារី ដែលជាឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងការបរទេសនៃរបបខ្មែរក្រហម បានអះអាងជាសាធារណៈថា ការជម្លៀសដោយបង្ខំ ដោយមូលហេតុកង្វះស្បៀងអាហារដើម្បីចិញ្ចឹមប្រជាជនដ៏ច្រើនសន្ធឹកសន្ធាប់ដែលរស់នៅទីក្រុងភ្នំពេញ ។ អៀង សារី បានបន្តថា "បញ្ហាគឺការស្វែងរកមធ្យោបាយដើម្បីដោះស្រាយបញ្ហាជីវភាពរបស់ប្រជាជនដោយប្រើប្រាស់មធ្យោបាយផ្សេងៗដែលយើងមាន" ។ អៀង សារី បានអះអាងទៀតថា "បញ្ហានេះបាននាំមកនូវបទពិសោធយ៉ាងច្រើនដែលធ្វើឲ្យយើងរកឃើញមធ្យោបាយក្នុងការបង្កើនផលិតផលស្បៀង ។ ថ្វីបើបរិមាណស្រូវនៅពេលនេះមិនទាន់មានច្រើនក្រាស់ក្រែល ប៉ុន្តែយើងមាន ស្រូវគ្រប់គ្រាន់ដើម្បីចិញ្ចឹមប្រជាជនគ្រប់គ្នា ។ ថ្ងៃនេះ ប្រជាកសិករយើងកំពុងធ្វើការនៅតាមទីជនបទ ហើយបានចូលរួមយ៉ាងសកម្មក្នុងសកម្មភាពផលិតស្បៀងអាហារ" ។

លើសពីនេះទៅទៀត ខៀវ សំផន ដែលជាប្រមុខរដ្ឋនៃរបបខ្មែរក្រហមដែលក្រោយមក ត្រូវបានប្តូរឈ្មោះទៅជាកម្ពុជាប្រជាធិបតេយ្យវិញនោះ បានអះអាងនៅក្នុងសារព័ត៌មានមួយចេញផ្សាយនៅខែសីហា ឆ្នាំ១៩៧៥ ថា "ទោះបីជាយើងមិនមានស្បៀងអាហារច្រើនលើសលុបក៏ដោយ ក៏យើងនៅតែអាចចិញ្ចឹមប្រជាជនយើងបានដែរ ។"

នៅពេលដែលខ្មែរក្រហមបានកាន់កាប់ប្រទេសកម្ពុជាទាំងស្រុងហើយនោះ ខ្មែរក្រហមបានចាប់ផ្តើមអនុវត្តនូវការសន្យារបស់ខ្លួនដែលថាប្រជាជនកម្ពុជានឹងមានអាហារបរិភោគគ្រប់គ្រាន់ ។ ប៉ុន្តែរបបថ្មីនោះមិនបានធ្វើការកសាងប្រទេសឡើងវិញឲ្យបានត្រឹមត្រូវនោះទេ ខ្មែរក្រហមបានប្រែក្លាយប្រទេសកម្ពុជាទៅជាប្រទេសស្វ័យត ពឹងផ្អែកលើខ្លួនឯង និងជារដ្ឋសង្គមនិយម ។ ភាពជាម្ចាស់ការលើខ្លួនឯង និងការពន្លឿនល្បឿនហួសកម្រិតបានបង្កឲ្យមានគ្រោះអត់ឃ្លានកើតឡើងនៅក្នុងប្រទេសដែលបានធ្វើឲ្យប្រជាជនកម្ពុជាយ៉ាងហោចណាស់ប្រាំបីសែននាក់ស្លាប់បាត់បង់ជីវិត ។ តួលេខនេះគិតត្រឹមខែមករា ឆ្នាំ១៩៧៩ ។

## គោលនយោបាយរបស់ខ្មែរក្រហមដែលនាំឲ្យមានការអត់ឃ្លាន

បន្ទាប់ពីខ្មែរក្រហមឡើងកាន់អំណាច មេដឹកនាំខ្មែរក្រហមបានរៀបចំឲ្យមានការជួបប្រជុំមួយនៅទីក្រុងភ្នំពេញនៅខែឧសភា ឆ្នាំ១៩៧៥ ។ នៅក្នុងកិច្ចប្រជុំនោះ គោលនយោបាយសំខាន់ៗមួយចំនួនរបស់បក្សត្រូវបានរៀបចំឡើង ដែលក្នុងនោះរួមមានគម្រោងបង្កើតសហករណ៍ថ្នាក់ខ្ពស់ ការលុបបំបាត់ចោលរូបិយវត្ថុ រួមទាំងការបង្កើតឲ្យមានការបរិភោគ និងការរស់នៅជាសមូហភាព ។

នៅក្នុងកិច្ចប្រជុំបន្ទាប់មកទៀត ប៉ុល ពត បានធ្វើសេចក្តីថ្លែងការណ៍មួយថា ៖

> "ប្រទេសជាតិឲ្យយើងត្រូវតែកសាងឡើងវិញ ហើយលទ្ធិសង្គមនិយមត្រូវតែយកមកអនុវត្តឲ្យបានលឿនបំផុតតាមដែលអាចធ្វើទៅបាន ។ ពោលគឺ ធ្វើយ៉ាងណាឲ្យប្រទេសកម្ពុជាដែលដើរថយក្រោយខាងផ្នែកកសិកម្មក្លាយទៅជាប្រទេសដែលរីកចម្រើនខាងផ្នែកកសិកម្មវិញក្នុងរយៈពេលពី៥ ទៅ១០ឆ្នាំ ព្រមទាំងធ្វើការកសាងប្រទេសកម្ពុជាពីប្រទេសដែលពឹងផ្អែកលើកសិកម្មឲ្យទៅជាប្រទេសឧស្សាហកម្មនៅក្នុងរយៈពេលពី១៥ ទៅ២០ឆ្នាំខាងមុខនេះ ។"

ជាមួយគ្នានេះដែរ ខ្មែរក្រហមក៏បានប្រកាសថា ប្រទេសកម្ពុជានឹងសម្រេចឲ្យបាននូវផែនការ "មហាលោតផ្លោះ មហាអស្ចារ្យ" ដែលនឹងធ្វើការកែប្រែប្រទេសឲ្យក្លាយទៅជារដ្ឋសង្គមនិយមគំរូមួយឲ្យបានលឿនបំផុត ។ មេដឹកនាំខ្មែរក្រហមបានពឹងផ្អែកទៅលើកសិកម្មដែលជាប្រភពនៃចំណូលជាតិ ដើម្បីសម្រេចទៅដល់ផែនការ "មហាលោតផ្លោះមហាអស្ចារ្យ" របស់ខ្លួន ។ នៅក្នុងកិច្ចប្រជុំមួយ ខ្មែរក្រហមបានលើកឡើងថា ៖

> "យើងពឹងផ្អែកលើវិស័យកសិកម្ម ដើម្បីឈានទៅរកការសម្រេចជោគជ័យលើវិស័យផ្សេងៗទៀត ដូចជា វិស័យឧស្សាហកម្ម រោងចក្រលោហធាតុ និង ប្រេង ជាដើម ។ គន្លឹះចម្បងបំផុតរបស់យើងគឺវិស័យកសិកម្ម ហើយការពឹងពាក់ខ្លួនឯងគឺជាកម្លាំងស្នូលសម្រាប់វិស័យកសិកម្ម ។"

ខ្មែរក្រហម បានដាក់គម្រោងក្នុងការបង្កើនទិន្នផលស្រូវច្រើនជាងមុនបីដងនៃផលិតផលស្រូវដែលធ្លាប់ផលិតបាន ពោលគឺសម្រេចឲ្យបានទិន្នផលជាមធ្យម៣តោនក្នុងមួយហិកតានៅលើដីកសិកម្មនៅទូទាំងប្រទេសកម្ពុជា ។ ប៉ុន្តែ គោលដៅនៃផលិតកម្មនេះពិបាកនឹងសម្រេចបានដោយមូលហេតុថា ប្រទេសកម្ពុជាមិនដែលធ្លាប់សម្រេចបានផលិតផលស្រូវក្នុងកម្រិតនេះពីមុនមកនោះទេ ។ ម្យ៉ាងវិញទៀត ប្រទេសកម្ពុជាទើបតែងើបចេញពីសង្គ្រាមស៊ីវិលដែលបានញាំញីប្រទេសអស់រយៈពេលជាងប្រាំឆ្នាំមកហើយ ។

ដើម្បីសម្រេចបាននូវការបង្កើនផលិតកម្មស្រូវដ៏ច្រើនសន្ធឹកសន្ធាប់នេះ ខ្មែរក្រហមបានខិតខំដោះស្រាយបញ្ហាខ្វះខាតទឹកនៅក្នុងប្រទេស ដោយបានធ្វើការបង្កើតឲ្យមានប្រព័ន្ធប្រឡាយទឹកទំនប់ទឹក ដើម្បីធ្វើការស្តុកទឹក និងបែងចែកទឹកឲ្យបានពេញមួយឆ្នាំ ។ ប៉ុន្តែ ខ្មែរក្រហមមិនមានថវិកា អ្នកជំនាញ និងគ្រឿងចក្រគ្រប់គ្រាន់ ដើម្បីបង្កើតប្រព័ន្ធធារាសាស្ត្រនៅទូទាំងប្រទេសទេ ។ ផ្ទុយទៅវិញ ខ្មែរក្រហមបានពឹងផ្អែកទាំងស្រុងទៅលើកម្លាំងពលកម្មរបស់ប្រជាពលរដ្ឋ ដើម្បីកសាងទំនប់ទឹកជាច្រើនដែលក្រោយមក ទំនប់ទឹកទាំងនោះភាគច្រើនដំណើរការមិនបានល្អ និងបាក់ខូចខាតទៅវិញ ។

ទន្ទឹមនឹងការដាក់ការងារធ្ងន់ធ្ងរ និងការបង្ខំឲ្យប្រជាជនសម្រេចឲ្យបានទិន្នផលស្រូវចំនួនបីតោនក្នុងមួយហិកតា ខ្មែរក្រហមក៏បានកាត់បន្ថយនូវរបបអាហារប្រចាំថ្ងៃរបស់ប្រជាជន ដើម្បីទុកស្រូវទៅផ្គត់ផ្គង់លើផ្នែកដទៃទៀត ។

បើតាមអ្វីដែលខ្មែរក្រហមធ្លាប់បានសន្យា ប្រជាជនកម្ពុជាត្រូវទទួលបានរបបស្រូវក្នុងម្នាក់ចំនួន១៣ថាំង សម្រាប់រយៈពេលមួយឆ្នាំ ដែលស្មើនឹង៣១២គីឡូក្រាម ឬ ជិតមួយគីឡូក្រាមក្នុងមួយថ្ងៃ ។ ជាក់ស្តែង មានតែប្រជាជនមួយចំនួនតូចប៉ុណ្ណោះដែលទទួលបានរបបនេះ ហើយប្រជាជនភាគច្រើនទទួលបានរបបអាហារតិចតួចបំផុត ត្រឹមតែបបររាវៗមួយវែក ចំនួនពីរដងក្នុងមួយថ្ងៃ ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏មេដឹកនាំខ្មែរក្រហមនៅតែមានសុទិដ្ឋិនិយម និងបានប្រកាសថា នៅពេលឆាប់ៗខាងមុខនេះ ប្រជាជនទាំងអស់នឹងទទួលបានអាហារបន្ថែមនៅពេលដែលបដិវត្តន៍របស់ខ្លួនទទួលបានជោគជ័យ ។ ប្រជាជនទាំងអស់ “នឹងមានការរីករាយពេញចិត្តចំពោះការរស់នៅក្នុងរបបនេះ” ។ ប៉ុន្តែ អ្វីដែលគួរឲ្យសោកស្តាយនោះ គឺការសន្យារបស់ខ្មែរក្រហមមិនដែលសម្រេចបាននោះទេ ។ ជាងនេះទៅទៀត ខ្មែរក្រហមបែរជាធ្វើការកាត់បន្ថយរបបអាហាររបស់ប្រជាជនបន្តិចម្តងៗ រហូតធ្វើឲ្យមានការកើនឡើងនៃតួលេខប្រជាជនដែលស្លាប់ដោយសារការអត់ឃ្លាន និងជំងឺរាតត្បាតផ្សេងៗ ដែលបណ្តាលមកពីកង្វះអាហារូបត្ថម្ភ ។

## តើការអត់ឃ្លានធ្វើឲ្យមនុស្សស្លាប់យ៉ាងដូចម្តេចខ្លះ?

នៅពេលដែលការអត់អាហារចាប់ផ្តើមកើតមានឡើង ប្រជាជនកម្រនឹងស្លាប់ដោយសារការដាច់ពោះភ្លាមៗណាស់ ។ ផ្ទុយទៅវិញ ការស្លាប់ដោយសារការអត់ឃ្លានមានរូបភាពច្រើនយ៉ាង ។ ជាទូទៅ មនុស្សចាប់ផ្តើមបាក់កម្លាំងនៅពេលដែលអត់មានអាហារបរិភោគ ហើយជំងឺចាប់ផ្តើមរាតត្បាតនៅពេលដែលមនុស្សដើរស្វែងរកចំណីអាហារ ។ ជាមួយគ្នានេះដែរ មនុស្សមួយចំនួនបែរជាលែងស្គាល់នូវអាហារដែលអាចបរិភោគបាននៅពេលដែលគ្រោះអត់ឃ្លានកើតមានឡើង ។ កត្តានេះអាចបណ្តាលឲ្យមនុស្សជួបប្រទះនូវបញ្ហាឈឺក្រពះ និងធ្វើឲ្យការអត់ឃ្លានកាន់តែមានសភាពធ្ងន់ធ្ងរឡើងៗ ។ បញ្ហាទាំងអស់នេះបានកើតឡើងជាក់ស្តែងនៅក្នុងប្រទេសកម្ពុជានៅក្នុងរបបខ្មែរក្រហម ។

សុខុមាលភាពរបស់ប្រជាជនកម្ពុជា បានចុះខ្សោយរួចទៅហើយបន្ទាប់ពីរងគ្រោះដោយសារសង្គ្រាមស៊ីវិលដែលអូសបន្លាយអស់រយៈពេល៥ឆ្នាំ ។ បន្ទាប់មក នៅពេលដែលខ្មែរក្រហមឡើងកាន់អំណាច ខ្មែរក្រហមបានបង្ខំប្រជាជនកម្ពុជារាប់សែននាក់ឲ្យផ្លាស់ទីលំនៅទៅកាន់ទីជនបទដាច់ស្រយាល ។ ការផ្លាស់ប្តូរលំនៅនេះ គឺជាហេតុបង្កឲ្យមានការរីករាលដាលនៃជំងឺឆ្លងផ្សេងៗនៅពេលដែលប្រជាជនធ្វើការប្រាស្រ័យទាក់ទងជាមួយគ្នា ។ មិនតែប៉ុណ្ណោះទៀតសោត លក្ខខណ្ឌរស់នៅជាទូទៅរបស់ប្រជាជននៅក្នុងរបបខ្មែរក្រហមមានលក្ខណៈលំបាកយ៉ាងខ្លាំង ។ ខ្មែរក្រហមមិនបានផ្តល់ឲ្យប្រជាជនកម្ពុជានូវការរស់នៅដ៏សមរម្យមួយនោះទេ ។ ប្រជាជនកម្ពុជាស្ទើរគ្រប់តំបន់ត្រូវរស់នៅដោយកង្វះបង្គន់អនាម័យ ។ ប្រជាជនជាច្រើននាក់បានបាក់កម្លាំង ដោយសារការបង្ខំឲ្យធ្វើការធ្ងន់ធ្ងរ និងកង្វះខាតម្ហូបអាហារ ។ នៅពេលដែល

ប្រជាជនបាក់កម្លាំង និងពុំមានអាហារបរិភោគគ្រប់គ្រាន់ ប្រជាជនមិនអាចទៅងូតទឹកដុះសម្អាតខ្លួនដើម្បីថែរក្សាអនាម័យខ្លួនប្រាណបានឡើយ ។ នេះជាហេតុបង្កឲ្យមានការចម្លងជំងឺកាន់តែខ្លាំងឡើង ។ នៅពេលមានជំងឺរាតត្បាតកើតឡើងម្តងៗ រួមផ្សំនឹងកង្វះខាតផ្នែកប្រព័ន្ធសុខាភិបាលនៅក្នុងរបបខ្មែរក្រហមផងនោះ ខ្មែរក្រហមជួបប្រទះបញ្ហាលំបាកក្នុងការកាត់បន្ថយល្បឿននៃការឆ្លងរាលដាលនៃជំងឺ ។

ក្រុមអ្នកជំនាញរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមបានធ្វើការប៉ាន់ប្រមាណកាលពីឆ្នាំ២០០៩ថា នៅក្នុងរបបខ្មែរក្រហម ប្រជាជនកម្ពុជាចន្លោះពីប្រាំបីសែន ទៅមួយលានបីសែននាក់ បានស្លាប់ដោយមិនទទួលរងនូវអំពើហិង្សានោះឡើយ ។ ប្រជាជនទាំងទាំងនោះបានស្លាប់ដោយកត្តាផ្សេងៗដែលមិនមែនជាបុព្វហេតុធម្មជាតិ ដូចជា ភាពចាស់ជរាជាដើម ។ ប៉ុន្តែ ប្រជាជនភាគច្រើន បានស្លាប់ដោយសារការអត់ឃ្លានដោយផ្ទាល់ និងដោយប្រយោល ព្រមទាំងលក្ខខណ្ឌរស់នៅផ្សេងៗ ។ ទន្ទឹមនឹងនេះ វាមានភាពខុសគ្នាជាច្រើនអំពីគម្លាតនៃតួលេខនៃចំនួនអ្នកដែលបានស្លាប់ដោយសារការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហម ។ បុព្វហេតុនៃការស្លាប់របស់ជនរងគ្រោះទាំងនោះមិនត្រូវបានកត់ត្រាត្រឹមត្រូវនោះទេ ។ ជាលទ្ធផល យើងអាចត្រឹមតែធ្វើការប៉ាន់ស្មានទៅលើចំនួនប្រជាជន ដែលបានស្លាប់ដោយសារការអត់ឃ្លានតែប៉ុណ្ណោះ ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏អ្នកប្រវត្តិសាស្ត្រខាងការអត់ឃ្លានម្នាក់បានឲ្យដឹងថា អត្រាអ្នកស្លាប់ដោយសារការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហមមានកម្រិតខ្ពស់បំផុត បើប្រៀបធៀបនឹងចំនួនអ្នកដែលបានស្លាប់ដោយសារអត់ដំឡូងបារាំងបរិភោគរបស់ប្រជាជនអៀរឡង់ពីឆ្នាំ១៨៤៦ ដល់ឆ្នាំ១៩៥២ ។

ដូច្នេះ យើងអាចធ្វើការសរុបសេចក្តីមួយចំនួនបានទៅលើបញ្ហាអត់ឃ្លាននៅក្នុងរបបខ្មែរក្រហមតាមរយៈព័ត៌មានដែលមានស្រាប់ថា ៖ ទីមួយ ការអត់ឃ្លានអាចមកពីលទ្ធផលនៃសង្គ្រាមស៊ីវិលដែលបានកើតឡើងមុនរបបខ្មែរក្រហម និងគោលនយោបាយរបស់ខ្មែរក្រហមដែលធ្វើឲ្យការអត់ឃ្លានកាន់តែមានសភាពធ្ងន់ធ្ងរជាងពេលដែលខ្មែរក្រហមមិនទាន់ដាក់ជាគោលនយោបាយទៅទៀត ។ ទីពីរ ការស្លាប់ដោយសារជំងឺ និងការស្លាប់ដោយសារការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហមមានការពាក់ព័ន្ធយ៉ាងជិតស្និទ្ធ ពោលគឺជំងឺភាគច្រើនដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហមបណ្តាលមកពីកង្វះខាតម្ហូបអាហារ ។ ទីបី ខ្មែរក្រហមមិនបានចាត់វិធានការ ឬកែប្រែគោលនយោបាយរបស់ខ្លួននោះទេ នៅពេលដែលមានការអត់ឃ្លានកើតឡើង ។ ម្យ៉ាងវិញទៀត មូលដ្ឋាននៃការដឹកនាំរបស់ខ្មែរក្រហមបែរជាធ្វើឲ្យគោលនយោបាយរបស់ខ្លួនកាន់តែតឹងរ៉ឹងជាងមុន ដែលបង្កឲ្យគ្រោះអត់ឃ្លានធ្លាក់ក្នុងសភាពធ្ងន់ធ្ងរឡើងៗ ។ ទីបួន យើងអាចនិយាយបានថា ប្រជាជនកម្ពុជារាប់សែននាក់បានស្លាប់បាត់បង់ជីវិតដោយសារពុំមានអាហារបរិភោគគ្រប់គ្រាន់ ។ ជាលទ្ធផល ប្រជាជនកម្ពុជាប្រហែលជាមួយលាននាក់ បានស្លាប់ដោយសារតែមូលហេតុផ្សេងៗដែលពាក់ព័ន្ធនឹងគ្រោះអត់ឃ្លាន ។ ជាសរុប យើងអាចសន្និដ្ឋានបានថា ភាគរយនៃចំនួនប្រជាជនដែលបានស្លាប់ដោយសារការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហម ជាភាគរយដែលច្រើនជាងគេបំផុតនៃប្រជាជនដែលបានស្លាប់ដោយសារការអត់ឃ្លាននៅក្នុងសតវត្សរ៍ទី២០ ។

**អ៊ែនឌុល ជីហ្វាល់ក្**

# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ÷

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥
ទូរស័ព្ទលេខៈ (៨៥៥) (១៦) ៨៧៦ ៦៩២
ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨
*Email: truthsocheat@dccam.org*
*Home page: www.dccam.org*

# ការិយាល័យព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឬសាលាក្តីខ្មែរក្រហម ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺជាឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីរគឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហមនិងសម័យក្រោយមកទៀត ។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននឹងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ុំ សារីណា តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។




















# ដើមបណ្តឹងរដ្ឋប្បវេណីចង្អុលឱ្យឃើញពីគម្រោងជួសជុលសំណង ក្នុងសំណុំរឿង ០០២/០១

សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចង្អុលឲ្យឃើញពីគម្រោងជួសជុលសំណងជាច្រើន រួមទាំងស្ថានភាពដែលខ្លួនអាចមានឱកាសដែលខ្លួនមានបំណងចង់ស្នើសុំបញ្ចូលក្នុងសំណុំរឿង០០២/០១ "ដែលទំនងជាអាចសម្រេចបានច្រើន" ។ មានគម្រោងចំនួនប្រាំពីរកំពុងត្រូវបានធ្វើឡើង ដូចជាការទទួលស្គាល់របស់រាជរដ្ឋាភិបាលកម្ពុជាទៅលើទិវាថ្មីស្តីពីការចងចាំជនរងគ្រោះខ្មែរក្រហម ការកសាងស្តូបរំឭកវិញ្ញាណក្ខន្ធជាសាធារណៈពីបីទៅប្រាំមួយកន្លែង ជាការទទួលស្គាល់នូវការឈឺចាប់របស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២ ជាពិសេស គោលនយោបាយ ផ្លាស់ទីលំនៅដោយបង្ខំក្នុងសំណុំរឿង០០២/០១ ការផ្តល់ឱកាសសម្រាប់សេវាសុខភាពផ្លូវចិត្ត ដូចជាការផ្តល់ប្រឹក្សាផ្នែកសុខភាពផ្លូវចិត្តដល់អ្នកមកផ្តល់សក្ខីកម្ម និងក្រុមជួយខ្លួនឯងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២/០១ ការតាំងពិព័រណ៍ចល័តជាមួយខ្សែភាពយន្តខ្លី និងសក្ខីកម្មផ្ទាល់របស់ដើមបណ្តឹងរដ្ឋប្បវេណីដែលរៀបរាប់ពីការឈឺចាប់ ដោយរួមទាំងការរៀបរាប់អំពីការជម្លៀសដោយបង្ខំ កន្លែងតាំងពិព័រណ៍ឯកសារ រូបភាពសោតទស្សន៍អំពីសក្ខីកម្ម និងការដាក់តាំងបែបសិល្បៈអចិន្ត្រៃយ៍ ដើម្បីថែរក្សាសាច់រឿងផ្សេងៗដែលទាក់ទិននឹងការជម្លៀសដោយបង្ខំក្នុងចំណោមការឈឺចាប់នានា និងសៀវភៅដែលពន្យល់អំពីដំណើរការក្តីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងបទឧក្រិដ្ឋកម្មដែលគ្របដណ្តប់នៅក្នុងសំណុំរឿង០០២ ។ យោងតាមសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖

> គម្រោងអាទិភាពចំនួនទាំងប្រាំពីរនេះ គឺស្ថិតក្នុងដំហានចុងក្រោយនៃការគិតគូរដោយសហការជាមួយមេធាវីដើម



សូ រី ដែលប្តីរបស់គាត់ត្រូវបានសម្លាប់នៅមន្ទីរឃុំឃាំងគុកក្រាំងតាចាន់ ខេត្តតាកែវ បានដាក់ពាក្យតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងករណី០០២

> *បណ្តឹងរដ្ឋប្បវេណី អង្គភាពគាំពារជនរងគ្រោះ និងអង្គការ និងស្ថាប័នដាដៃគូផ្សេងៗជាច្រើនទៀត ។ អង្គការ និងស្ថាប័នជាដៃគូដែលបានបញ្ជាក់ច្បាស់ទាំងអស់បានសម្តែងចេតនារបស់ខ្លួនទទួលខុសត្រូវលើការអនុវត្តគម្រោងទាំងនោះ ហើយចង់ចុះកិច្ចព្រមព្រៀងផ្តល់ថវិកាផ្ទាល់ជាមួយម្ចាស់ជំនួយលើគម្រោង និងជាមួយអង្គភាពគាំពារជនរងគ្រោះ ។*

អនុលោមតាមវិធានផ្ទៃក្នុង អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ពុំមានអំណាចផ្តល់ជូនសំណងខូចខាតជាបុគ្គលទេ គឺមានតែសំណងដែលមាន «លក្ខណៈសមូហភាព និងផ្លូវចិត្ត» ប៉ុណ្ណោះ ។ អង្គជំនុំជម្រះសាលាដំបូងធ្លាប់សម្រេចថា ៖

> *អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ពុំមានសមត្ថកិច្ចផ្តល់ជូនសំណងលុយកាក់ជាបុគ្គលដល់ដើមបណ្តឹងរដ្ឋប្បវេណីឡើយ ។ ការផ្តើមចេញពីច្បាប់ជាតិបែបនេះត្រូវបានចាត់ទុកថាចាំបាច់ក្នុងការពិនិត្យលើចំនួនដើមបណ្តឹងរដ្ឋប្បវេណីច្រើនដែលរំពឹងថាទាមទារនៅមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងភាពលំបាកដែលមិនអាចជៀសផុតពីការវាយតម្លៃលើទំហំនៃការបាត់បង់ឲ្យបានពេញលេញដែលប៉ះពាល់ដោយជនរងគ្រោះនូវកម្រិតខុសៗគ្នា ។ ហេតុដូច្នេះ សំណងនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសំដៅដល់ភាពជានិមិត្តរូបសំខាន់ជាជាងសំណងលុយកាក់ ។*

នៅក្នុងសំណុំរឿង ០០១ ក្រុមដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំការជួសជុលសំណងខូចខាត «ក្នុងកម្រិតអប្បបរមា» ដូចជាការចងក្រង និងចែកចាយជូនសេចក្តីថ្លែងការណ៍សុំអភ័យទោសរបស់ប្រធានមន្ទីរសន្តិសុខស-២១ កាំង ហ្កេកអ៊ាវ (ហៅ ឌុច) ជាមួយនឹងយោបល់របស់ដើមបណ្តឹងរដ្ឋប្បវេណី ការទទួលបានការថែទាំវេជ្ជសាស្ត្រសម្រាប់អ្នកជំងឺ ការផ្តល់ថវិកាដល់កម្មវិធីអប់រំអំពីរបបខ្មែរក្រហម និង ស-២១ ការសាងស្តូបរំឭកវិញ្ញាណក្ខន្ធនិងវត្តអារាម និងការបញ្ចូលឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសាលក្រម ។

អនុលោមតាមវិធានផ្ទៃក្នុងជាធរមាននៅក្នុងអំឡុងពេលនោះ ការផ្តល់នូវសំណងគឺ «សំដៅប្រឆាំងដោយផ្ទាល់ និងលើជនជាប់ចោទតែម្នាក់ឯង» ហើយ ឌុច ត្រូវបានកំណត់ថា ជនទុរគត ។ អង្គជំនុំជម្រះសាលាដំបូងរកឃើញថា ខ្លួនពុំមានសមត្ថកិច្ចលើជនកម្ពុជា ឬអាជ្ញាធរណាមួយដែលមិនអាចចេញបញ្ជាដែលមិនអាចមានលទ្ធភាពក្នុងការអនុវត្ត ដោយសារតែកង្វះភាពជាក់លាក់ ហើយយ៉ាងច្រើនអាចត្រឹមតែ «លើកទឹកចិត្ត» តួអង្គខាងក្រៅក្នុងការផ្តល់ជូនជនរងគ្រោះនូវការគាំទ្រផ្នែកហិរញ្ញវត្ថុតែប៉ុណ្ណោះ ។ បើទោះជាមានការទទួលស្គាល់នូវគោលការអន្តរជាតិដែលបានដាក់កាតព្វកិច្ចលើរដ្ឋឲ្យដោះស្រាយជូនជនរងគ្រោះពីការរំលោភបំពានធ្ងន់ធ្ងរលើសិទ្ធិមនុស្សក៏ដោយ អង្គជំនុំជម្រះសាលាដំបូងបានថ្លែងថា «ខ្លួនត្រូវបានកម្រិតនៅក្នុងសមត្ថកិច្ចឆ្លើយតបនឹងសំណើនៅចំពោះមុខខ្លួន និងប្រភេទនៃការធ្វើសំណងដែលបានអនុញ្ញាតតាមវិធានផ្ទៃក្នុង ។ ការកម្រិតបែបនេះពុំអាចនឹងជៀសវាងបានតាមរយៈយុត្តិសាស្ត្រទេ ក៏ប៉ុន្តែត្រូវឲ្យមានវិសោធនកម្មវិធានផ្ទៃក្នុងវិញ» ។ អាស្រ័យហេតុនេះ ខ្លួនផ្តល់តាមសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលសុំឲ្យបញ្ចូលឈ្មោះដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះផ្ទាល់នៅក្នុងសាលក្រមចុងក្រោយ ព្រមទាំងការរៀបចំ និងបោះពុម្ពរាល់សេចក្តីថ្លែងការណ៍សុំអភ័យទោសដែលធ្វើឡើងដោយ ឌុច នៅក្នុងអំឡុងពេលសវនាការតែប៉ុណ្ណោះ ។

នៅក្នុងការប្រមើលមើលលើសំណុំរឿង ០០២ ចៅក្រមបានធ្វើវិសោធនកម្មលើវិធានផ្ទៃក្នុងដើម្បីពង្រីកអំណាចរបស់ខ្លួនក្នុងការផ្តល់សំណង ។ វិធាន ២៣(៣) ថ្មី ផ្តល់ជូនចៅក្រមនូវអំណាចទាំងការចេញបញ្ជាថា តម្លៃនៃការផ្តល់សំណងគឺស្ថិតនៅលើជនត្រូវទទួលទោស ឬ «ទទួលស្គាល់ថាគម្រោងជាក់លាក់ផ្តល់សំណងយ៉ាងសមស្របតាមការស្នើរកររបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ហើយគម្រោងនោះអាចយកទៅអនុវត្តបាន ។ គម្រោងបែបនេះ ត្រូវតែរៀបចំ ឬចង្អុលបង្ហាញដោយមានការសហការជាមួយអង្គភាពគាំពារជនរងគ្រោះ និងត្រូវធានាថវិកាផ្នែកខាងក្រៅឲ្យបានគ្រប់គ្រាន់» ។ វិសោធនកម្មវិធាននេះបង្កើតឱកាសសម្រាប់ការជួសជុលសំណងឲ្យមានលក្ខណៈទូលំទូលាយ ។ ទោះបីជាយ៉ាងណាក្តី មកដល់ពេលបច្ចុប្បន្ននេះ អង្គជំនុំជម្រះសាលាដំបូងមិនធ្លាប់បានផ្តល់នូវក្របខណ្ឌជាក់លាក់ក្នុងការចង្អុលបង្ហាញពីការអនុវត្តរបស់ខ្លួនឡើយ ហើយការអនុវត្តជាក់ស្តែងជាច្រើន

នៅមានលក្ខណៈមិនច្បាស់លាស់ ។

មេធាវីដើមបណ្តឹងរដ្ឋប្បវេណីចែករំលែកការទទួលខុសត្រូវដែលមានលក្ខណៈត្រួតគ្នា ជាមួយអង្គភាពគាំពារជនរងគ្រោះក្នុងការបង្កើតគម្រោងសំណង ដោយធ្វើឲ្យដែនសមត្ថកិច្ច និងការទទួលខុសត្រូវចុងក្រោយ ស្ថិតក្នុងភាពមិនច្បាស់លាស់នៅត្រង់ថា «អង្គភាពគាំពារជនរងគ្រោះដោយមានកិច្ចសហការជាមួយសហមេធាវីនាំមុខត្រូវខិតខំប្រឹងប្រែង ចង្អុលបង្ហាញ រៀបចំ និងក្រោយមកអនុវត្តគម្រោង» មេធាវីដើមបណ្តឹងរដ្ឋប្បវេណី សុះស្មែង និងពាំនាំទស្សនៈរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងគម្រោងណាមួយដែលមានអត្ថន័យ រួចហើយរៀបចំជាសំណើចុងក្រោយដាក់ជូនអង្គជំនុំជម្រះសាលាដំបូង ក៏ប៉ុន្តែតួនាទីចម្បងរបស់ខ្លួនគឺការធ្វើជាតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងតុលាការពុំមែនគ្រប់គ្រងលើគម្រោងនោះទេ ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីសង្កត់ធ្ងន់ថា ខ្លួនអាចគាំទ្រ និងជួយសម្រួលដំណើរការស្វែងរកថវិកាជាមួយអង្គភាពគាំពារជនរងគ្រោះ បើទោះជាខ្លួន «ពុំមានជំនាញនិងអាណត្តិក្នុងការទទួលខុសត្រូវដោយផ្ទាល់ក៏ដោយ» អង្គភាពគាំពារជនរងគ្រោះ គឺទទួលខុសត្រូវលើការអភិវឌ្ឍគម្រោង ហើយត្រូវបានរំពឹងថា «រៀបចំផ្តល់សំណងដែលចង្អុលបង្ហាញដោយសហមេធាវីនាំមុខព្រមទាំងធានានូវថវិការបស់ខ្លួន និងភាពរួចរាល់សម្រាប់ការអនុវត្តនៅដំណាក់កាលសាលក្រមចុងក្រោយ» ។

យោងតាមមេធាវីដើមបណ្តឹងរដ្ឋប្បវេណី បច្ចុប្បន្ននេះ «អត្តសញ្ញាណ និងគំរូនៃគម្រោងនេះ ស្ថិតក្នុងដំណាក់កាលលូតលាស់ទៅមុខ ប៉ុន្តែការធានាផ្នែកហិរញ្ញវត្ថុមិនទាន់អាចរកបាននៅឡើយទេ ឬ ប្រសិនបើអាចរកបាន វានៅមិនទាន់ច្បាស់នៅឡើយទេ» ។ បើទោះជាអង្គជំនុំជម្រះបាននិយាយថា វិធានសងសំណងថ្មី «សន្មតជាមុនពីការបង្កើតសំណងតាមន័យបច្ចេកទេស តាមរយៈការចាត់ចែងកម្មវិធី ស្របគ្នាជាមួយនឹងការកាត់សេចក្តីនេះ» ។ វានៅមិនទាន់ច្បាស់នៅឡើយ ថាតើកម្មវិធីនេះ ត្រូវបង្កើតឡើង និងមានមូលនិធិពេញលេញមុនពេលទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានធ្វើឲ្យការអនុម័តរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានលក្ខណៈនិមិត្តរូបសុទ្ធសាធ ឬបើសិនជាមានលក្ខណៈគ្រប់គ្រាន់ដែលថាដែនការដាក់ស្តែង ឬការសន្យាផ្តល់មូលនិធិ (ប្រហែលអាស្រ័យលើការទទួលស្គាល់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា) មានអាទិភាព ។

អង្គជំនុំជម្រះបានផ្តល់ការសង្កេតពីមុនៗ អំពីភាពសមស្របចំពោះប្រភេទគម្រោងដែលមេធាវីដើមបណ្តឹងរដ្ឋប្បវេណីកំពុងផ្តល់អាទិភាពដោយមានក្របខណ្ឌសំណងថ្មីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ជាការគួរឲ្យកត់សម្គាល់ អង្គជំនុំជម្រះបង្ហាញថា វិធានការដែលតម្រូវឲ្យមានការអនុម័តពីរដ្ឋាភិបាលកម្ពុជាអាចហួសពីវិសាលភាពនៃអំណាចរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ លើសពីនេះទៀត អង្គជំនុំជម្រះបាននិយាយថា ការស្នើសុំឲ្យកសាងចេតិយ ទីតាំងបូជនីយដ្ឋាន កម្មវិធីអប់រំ និងកិច្ចគាំពារខាងចិត្តសាស្ត្រ តម្រូវឲ្យមានភាពជាក់លាក់គ្រប់គ្រាន់ ។ ឧទាហរណ៍ យោងតាមសាលក្រមទៅលើ ឌុច អង្គជំនុំជម្រះបានបង្ហាញថា ព័ត៌មានជាក់ស្តែងអំពីទីតាំង ការចំណាយ និងការព្រមព្រៀងពីម្ចាស់ទីតាំងបូជនីយដ្ឋានតាមការស្នើសុំ និងសេចក្តីត្រូវការចំពោះការអនុញ្ញាតផ្នែករដ្ឋបាល មានដូចជាការអនុញ្ញាតចំពោះការកសាង ត្រូវតែបានផ្តល់ «ដើម្បីធានាថាផ្នែកឆ្លងគ្នាប្រកបដោយភាពកម្រិតចំពោះវិធានការទាំងនេះអាចសម្រេចបានយ៉ាងមានអត្ថន័យដែលស្ថិតក្នុងក្របខណ្ឌពេលវេលាដែលអាចអនុវត្តបាន» ។ ផ្ទុយទៅវិញ អង្គជំនុំជម្រះមិនពន្យល់អំពីកម្រិតនៃភាពជាក់លាក់ឲ្យបានគ្រប់គ្រាន់ ប៉ុន្តែផ្ទុយទៅវិញបានកំណត់នូវវិធានការដែលស្រដៀងគ្នាទៅនឹងសំណងនៅក្នុងសំណុំរឿង០០១ ដូចជាការផ្សព្វផ្សាយសាលក្រមនិងបញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណី ថាជា «វិធានការដ៏សមស្រប និងអាចសម្រេចបាននៅក្នុងបរិបទរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា» ។ ប៉ុន្តែការសងសំណងនេះមានរួចស្រេចទៅហើយមុនពេលការអនុម័តច្បាប់ថ្មី ហើយសំណងនោះត្រូវបានចាត់ទុកថា «គ្មានប្រសិទ្ធភាព» ពីសំណាក់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ។

នៅទីបញ្ចប់ភាពជាប់ពាក់ព័ន្ធនៃការបំបែកសំណុំរឿង០០២ទៅជាការកាត់សេចក្តីតូចៗមួយ ឬពីរស្តីពីសិទ្ធិរបស់បុគ្គលម្នាក់ៗនៃដើមបណ្តឹងរដ្ឋប្បវេណី០០២ ចំពោះការសងសំណងនៅតែមិនអាចដោះស្រាយ ។ ប្រធានបទនេះ នឹងត្រូវបានដោះស្រាយនៅក្នុងបទអត្ថាធិប្បាយលើកក្រោយទៀត ។

**អាន ហាញឌុល**

# ចៅក្រមអង្គបុរេជំនុំជម្រះជាតិ និងអន្តរជាតិខ្វែងគំនិតគ្នានៅក្នុង សំណុំរឿង០០៣ ជាថ្មីម្តងទៀត

អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានខ្វែងគំនិតគ្នារវាងចៅក្រមអន្តរជាតិ និងចៅក្រមជាតិជាថ្មីទៀតលើសំណុំរឿង០០៣ ដែលមានភាពចម្រូងចម្រាសគ្នា ដោយបដិសេធនូវបណ្តឹងឧទ្ធរណ៍របស់អ្នកប្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលទទួលបានការទាត់ចោលម្តងរួចហើយកាលពី១៨ខែមុន ក្រោយពីបណ្តឹងនេះជាប់គាំងនោះ ។ សេចក្តីសម្រេចនេះស្តែងឲ្យឃើញបន្ថែមទៀតនូវភាពមិនប្រក្រតីលើនីតិវិធីក្នុងការគ្រប់គ្រងសំណុំរឿងនិងធ្វើឲ្យមានកង្វល់ឡើងវិញអំពីសមត្ថភាពរបស់តុលាការក្នុងការចាត់ការកិច្ចស៊ើបសួរដែលនៅសេសសល់ដោយឯករាជ្យនិងមិនលម្អៀង ។

ក្នុងខែមេសា ឆ្នាំ២០១១ សហចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេង និងអតីតសហភាគីរបស់គាត់ គឺចៅក្រម ស៊ីកហ្វ្រេដ ប៊្លុង បានសម្រេចបិទការស៊ើបអង្កេតលើសំណុំរឿង០០៣ភ្លាមៗដោយចេញតែសេចក្តីថ្លែងការណ៍ព័ត៌មានមួយល្បះប៉ុណ្ណោះ ហើយពុំបានជូនដំណឹងជនរងគ្រោះអំពីសិទ្ធិដែលនឹងផុតកំណត់ចូលរួមក្នុងដំណើរការនីតិវិធីក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី និងក្នុងការដាក់សំណើសុំចំណាត់ការស៊ើបអង្កេតចុងក្រោយ ។ ជនរងគ្រោះពីរបីនាក់មានលទ្ធភាពដាក់ពាក្យបណ្តឹងនៅក្នុងអំឡុងពេលនៃការកំណត់រយៈ១៥ថ្ងៃដែលច្បាប់ផ្តល់ជូន ហើយអ្នកដាក់បណ្តឹងដែលដឹងជាសាធារណៈទាំងនោះត្រូវបានទាត់ចោលដោយសហចៅក្រមស៊ើបអង្កេត ។ ដោយទទួលបានបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹង រ៉ប់ ហាមីល ដែលបងរបស់គាត់ត្រូវបានយោធាដើងទឹកដែលស្ថិតក្រោមបញ្ជាការរបស់ជនសង្ស័យក្នុងសំណុំរឿងនេះចាប់ជាអ្នកទោស និងក្រោយមកត្រូវបានសម្លាប់ចោលនោះ អង្គបុរេជំនុំជម្រះពុំអាចឈានដល់ការសម្រេចទេដោយសារតែមានការខ្វែងគំនិតគ្នារវាងចៅក្រមជាតិ និងចៅក្រមអន្តរជាតិ ។ យោបល់ដោយឡែករបស់ចៅក្រមអន្តរជាតិបានបន្ទោសសហចៅក្រមស៊ើបអង្កេតពីភាពមិនស៊ីសង្វាក់នៅក្នុងការដោះស្រាយកិច្ចស៊ើបសួរដោយប្រៀបធៀបនឹងរបៀបស៊ើបអង្កេតលើសំណុំរឿង០០១ និង០០២ ដែលបានធ្វើឡើងកន្លងមករួមទាំងការខកខានក្នុងការបង្ហាញជនសង្ស័យដែលត្រូវចោទប្រកាន់ការខកខានក្នុងការជូនដំណឹងជនរងគ្រោះឲ្យបានទាន់ពេលវេលាដើម្បីឲ្យជនរងគ្រោះអាចអនុវត្តនូវសិទ្ធិរបស់ខ្លួនចូលរួមនៅក្នុងដំណើរការស៊ើបអង្កេតការខកខានក្នុងការទទួលស្គាល់មេធាវីរបស់ដើមបណ្តឹងនិងក្នុងការជូនដំណឹងដល់មេធាវីអំពីឯកសារនៅក្នុងសំណុំរឿងឬផ្តល់សិទ្ធិទទួលបានការមើលសំណុំរឿង ព្រមទាំង «ការពន្យារពេលដែលពុំមានការពន្យល់ឲ្យបានជាក់លាក់នៅក្នុងដំណើរការទទួលយកឯកសារ និងដាក់ឯកសារចូលក្នុងសំណុំរឿង» ។

អ្នកដាក់បណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ទៀតគឺមិនត្រូវបានបញ្ចេញឈ្មោះទេ ។ ដើមបណ្តឹងម្នាក់នេះត្រូវបានបង្ខំឲ្យរៀបការក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យហើយប្តីរបស់ខ្លួនត្រូវបានបង្ខំឲ្យធ្វើការជាទម្ងន់នៅការដ្ឋានសង់ព្រលានយន្តហោះនៅខេត្តកំពង់ឆ្នាំង (ទីតាំងឧក្រិដ្ឋកម្មនៅក្នុងសំណុំរឿង០០៣) មុននឹងត្រូវបានធ្វើទារុណកម្ម និងសម្លាប់ចោលនៅមន្ទីរសន្តិសុខស-២១ ។ បើទោះបីជាដើមបណ្តឹងម្នាក់នេះត្រូវបានទទួលស្គាល់នៅក្នុងសំណុំរឿង០០១ និង០០២រួចមកហើយក៏ដោយ ក៏សហចៅក្រមស៊ើបអង្កេតនៅតែផ្តល់ហេតុផលថាដើមបណ្តឹងម្នាក់នេះពុំទទួលរងផលប៉ះពាល់ដោយផ្ទាល់ដោយឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងប្រឆាំងនឹងប្តីរបស់ខ្លួនទេ ផ្ទុយទៅវិញគឺដោយបច្ច័យផ្សេង ពោលគឺការងារធ្ងន់ដែលត្រូវបានបង្ខំឲ្យធ្វើរបស់ប្តីដើមបណ្តឹងនោះ ។ សហចៅក្រមស៊ើបអង្កេតបានរកឃើញទៀតថា វា «មិនជាទំនងប៉ុន្មានទេ» ដែលថាដើមបណ្តឹងម្នាក់នេះតាមពិតទៅបានទទួលរងការឈឺចាប់ខាងផ្លូវចិត្តដោយសារតែការបង្ខំឲ្យធ្វើការជាទម្ងន់របស់ប្តីខ្លួន កាលពី៣៨ឆ្នាំកន្លងទៅនោះ ហើយសន្និដ្ឋានថាដើមបណ្តឹងម្នាក់នេះប្តឹង

ទាមទារ "ដោយផ្អែកលើការឲ្យយោបល់ដែលមិនសមហេតុពីភាគីទី៣" ។ នៅទីបញ្ចប់សហចៅក្រមស៊ើបអង្កេតបាននិយាយថាដើមបណ្តឹងនេះមិនគួរនឹងទទួលយកទេពីព្រោះខ្លួនគឺជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០១ និង០០២ រួចទៅហើយ ។

សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងនេះកាលពីឆ្នាំ២០១១ បានចង្អុលបង្ហាញថា វាពុំមានការបន្ទន់នូវទស្សនៈយល់ឃើញតាំងពីពេលចេញសេចក្តីសម្រេចលើ រ៉ប់ ហាម៉ីល មកម៉្លេះ ។ ដោយសារតែអង្គបុរេជំនុំជម្រះ ពុំអាចឈានដល់សេចក្តីសម្រេចជាឯកច្ឆ័ន្ទ អនុលោមតាមវិធានរបស់តុលាការសេចក្តីសម្រេចទាត់ចោលការដាក់បណ្តឹងរបស់ដើមបណ្តឹងដោយសហចៅក្រមស៊ើបអង្កេតនៅតែមានប្រសិទ្ធភាព ។ ដោយផ្តោះបញ្ចាំងលើហេតុផលដែលមាននៅក្នុងបណ្តឹងឧទ្ធរណ៍របស់ រ៉ប់ ហាម៉ីល យោបល់ដោយឡែករបស់ចៅក្រមជាតិនៅអង្គបុរេជំនុំជម្រះអះអាងថា ដោយសារតែសហចៅក្រមស៊ើបអង្កេតពុំទាន់ចោទប្រកាន់នរណាម្នាក់នៅឡើយក្នុងសំណុំរឿង០០៣ "ទើបពុំមានជនត្រូវចោទដែលត្រូវទទួលខុសត្រូវលើដំណោះស្រាយដែលស្វែងរកសម្រាប់ជួសជុលការខូចខាតដែលបង្កដល់ជនរងគ្រោះ ហើយអាស្រ័យហេតុនេះ ការទាត់ចោលការសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅដំណាក់កាលនេះគឺពុំរំលោភលើសិទ្ធិរបស់ជនរងគ្រោះទេ" ។

ផ្ទុយទៅវិញចៅក្រមអន្តរជាតិ *Downing* និង *Chung* បានយកតាមការកត់សម្គាល់ទាំងអស់នៅក្នុងសេចក្តីលើបណ្តឹងឧទ្ធរណ៍របស់ រ៉ប់ ហាម៉ីល ស្តីអំពីការកើតមានឡើងនូវភាពមិនប្រក្រតីផ្នែកនីតិវិធី និងភាពមិនស៊ីសង្វាក់នៅក្នុងកិច្ចការរបស់សហចៅក្រមស៊ើបអង្កេត ។ លើសពីនេះទៀតចៅក្រមទាំងពីរ បានរកឃើញភាពមានចន្លោះផ្នែកនីតិវិធីបន្ថែមទៀត ដែលតាមទស្សនៈរបស់ខ្លួនគឺត្រូវឈានដល់ការសម្រេចមោឃភាព ដោយសារតែ "ផលប៉ះពាល់របស់វាមានលក្ខណៈផ្ទុយគ្នា" លើសិទ្ធិរបស់ភាគី ៖ ទាំងការដាក់បណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងឯកសារដែលគាំទ្រដល់បណ្តឹងគឺជាផ្នែកខ្លះនៅក្នុងសំណុំរឿងដែលនាពេលនោះត្រូវទាត់ចោល ។ "ហេតុដូច្នេះវាទំនងត្រូវបានសហចៅក្រមស៊ើបអង្កេតចេញសេចក្តីសម្រេចដែលរងការជំទាស់ដោយពុំទទួលយកបណ្តឹងនឹងពុំជូនដំណឹងដល់សហព្រះរាជអាជ្ញា និងជនត្រូវចោទ" ដោយជៀសវាងនូវ "របបនីតិវិធីដែលមានរួចមកហើយតាមរយៈវិធានផ្ទៃក្នុង ព្រមទាំងការធានាជាមូលដ្ឋានលើដំណើរការក្តីប្រកបដោយយុត្តិធម៌ដែលចែងឡើងជាស្តង់ដារទទួលស្គាល់ជាអន្តរជាតិ ។" ភាពមិនប្រក្រតីថ្មីនេះ "ឆ្លុះបញ្ចាំងឲ្យឃើញនូវគំរូនៃការប្រព្រឹត្តដែលទទួលយកដោយសហចៅក្រមស៊ើបអង្កេតនៅក្នុងសំណុំរឿង ០០៣" ដែល "ធ្វើឲ្យមានមន្ទិលសង្ស័យលើចេតនារបស់ចៅក្រមក្នុងការបើកកិច្ចដំណើរនីតិវិធីតាមរបៀបមួយដែលប្រកបដោយតម្លាភាព និងអាចគតាំងបានដែលនឹងធានាដល់ការគោរពសិទ្ធិរបស់ភាគី និងអ្នកចូលរួមនៅកិច្ចដំណើរការនោះ" ។

ដោយចៅក្រមជាតិ និងអន្តរជាតិពុំយល់ព្រមបញ្ជូនសំណុំរឿងត្រឡប់ទៅឲ្យសហចៅក្រមស៊ើបអង្កេតវិញដើម្បីធ្វើការពិចារណាជាថ្មីដោយសារតែផលវិបាកដែលកើតចេញពីភាពមានចន្លោះផ្នែកនីតិវិធីទាំងនោះគឺជាលើកទី១ហើយ ដែលចៅក្រមអន្តរជាតិ នៅអង្គបុរេជំនុំជម្រះដោះស្រាយលើខ្លឹមសារនៃហេតុផលដែលលើកឡើងដោយសហចៅក្រមស៊ើបអង្កេត ។ ចៅក្រមអន្តរជាតិបានកត់សម្គាល់ថាទាំងដើមបណ្តឹងឧទ្ធរណ៍ ទាំងដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀតដែលធ្លាប់បានទទួលយកដោយសហចៅក្រមស៊ើបអង្កេត អង្គបុរេជំនុំជម្រះនិងអង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០១ និង ០០២ បានពឹងផ្អែកលើ "ការឈឺចាប់ដែលជាលទ្ធផលនៃឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងប្រឆាំងនឹងសមាជិកគ្រួសារផ្ទាល់របស់ខ្លួន ដោយរួមបញ្ចូលទាំងប្តីឬប្រពន្ធរបស់ខ្លួនទៀតផង" ។ ក្នុងការសម្រេចផ្ទុយដែលថារបួសស្នាមរបស់ដើមបណ្តឹងពុំឆ្លើយតបនឹងលក្ខខណ្ឌតម្រូវចាំបាច់សម្រាប់ការទទួលយកនៅក្នុងសំណុំរឿង ០០៣នោះ គឺសហចៅក្រមស៊ើបអង្កេតមិនបានយកចិត្តទុកដាក់លើការសម្រេចពីមុនៗរបស់តុលាការ និងបានរំលោភលើសិទ្ធិរបស់ភាគី "ក្នុងការទទួលបាននូវភាពជាក់លាក់របស់ច្បាប់ និងភាពស្មើគ្នាចំពោះមុខច្បាប់" ។ លើសពីនេះទៀតចៅក្រមអន្តរជាតិបានរកឃើញនូវចំណងទាក់ទងដែលសហចៅក្រមស៊ើបអង្កេតសម្រេចថាមានតែជនរងគ្រោះក្នុងចំណងលោហិតជិតស្និទ្ធប៉ុណ្ណោះមានសិទ្ធិក្លាយជាដើមបណ្តឹងរដ្ឋប្បវេណីនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហើយមិនមែនញាតិលោហិតឆ្ងាយនោះទេដែលមានសិទ្ធិនេះដែលវាមិនត្រឹមតែខុសទៅនឹងគោលបំណងរបស់វិធានផ្ទៃ

ក្នុងប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងខុសនឹងការអនុវត្តលក្ខណៈជាតិ និងអន្តរជាតិទៀតផង ។ ចុងបញ្ចប់ ចៅក្រមអន្តរជាតិ បាននិយាយថាស្តង់ដារនៃភ័ស្តុតាងដូចដែលយកមកអនុវត្តនេះខ្វះការឲ្យហេតុផលច្បាស់លាស់ និងការសន្មតដែលថា ដើមបណ្តឹងរដ្ឋប្បវេណីពុំមានសិទ្ធិទទួលឲ្យធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងច្រើនផ្សេងពីគ្នានោះ "គឺពុំមានក្នុងមូលដ្ឋានច្បាប់ ឬនៅក្នុងការឲ្យហេតុផលពីមុនៗទេ ហើយបានរំលោភបំពានលើសិទ្ធិជាមូលដ្ឋានរបស់ជនរងគ្រោះទៀតផង" ។ ដោយសារតែអង្គបុរេជំនុំជម្រះដែលមានការខ្វែងគំនិតនេះមិនអាចផ្តល់ជូនដើមបណ្តឹងឧទ្ធរណ៍នូវការដោះស្រាយចំពោះការពិចារណាដោយខ្វះចន្លោះរបស់សហចៅក្រមស៊ើបអង្កេតលើសំណើសុំរបស់ដើមបណ្តឹងទើបចៅក្រមអន្តរជាតិជំរុញឲ្យសហចៅក្រមស៊ើបអង្កេតបច្ចុប្បន្នអនុវត្តសិទ្ធិដែលខ្លួនមានដើម្បីពិចារណាលើសំណើសុំនោះឡើងវិញ ។ ទោះបីជាយ៉ាងនេះក្តីដូចដែលបានកត់សម្គាល់ដោយចៅក្រមអ៊ីចិងគឺរឿងនេះធ្លាប់បានកើតមានរួចមកហើយ ។ នៅពេលដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងឡូរ៉ង់ កាស្ពឺ-អានសើមេត ចូលកាន់តំណែងជំនួសឲ្យចៅក្រម (ប៊ុង) លោកបានពិចារណាសំណើសុំនោះឡើងវិញដោយរកឃើញថាសំណើសុំនោះបានឆ្លើយតបតាមលក្ខខណ្ឌតម្រូវចាំបាច់ដែលអាចទទួលយកបាន និងបានផ្តល់ជូននូវសិទ្ធិទទួលបានឯកសារក្នុងសំណុំរឿងទៀតដោយបានធ្វើឲ្យបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងអាចយកមកពិភាក្សាបានយ៉ាងត្រឹមត្រូវ ។ ទោះបីជាយ៉ាងនេះក្តីសេចក្តីសម្រេចរបស់ចៅក្រមកាស្ពឺ-អានសើមេត ពុំមានឥទ្ធិពលជាក់ស្តែងទេ គឺដោយសារតែរដ្ឋាភិបាលកម្ពុជាមិនព្រមទទួលស្គាល់ការតែងតាំងនិងសិទ្ធិអំណាចក្នុងការចាត់វិធានការរបស់លោកចៅក្រម ។ បុគ្គលិកជាតិបានបដិសេធដោយបែបក្នុងការអនុវត្តសេចក្តីសម្រេចនេះដោយរាប់បញ្ចូលទាំងការសម្រេចទទួលយកការពិចារណាឡើងវិញលើសំណើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី រ៉ប់ហាម៉ីល និងផ្តល់ជូនមេធាវីរបស់ដើមបណ្តឹងរូបនេះនូវសិទ្ធិទទួលបានឯកសារនៅក្នុងសំណុំរឿង០០៣ទៀតផង ។

អាស្រ័យហេតុនេះវាមិនសូវជាទំនងទេដែលថាសេចក្តីសម្រេចណាមួយរបស់ចៅក្រម កាស្ពឺ-អានសើមេត រួមទាំងការបន្តការស៊ើបអង្កេតលើសំណុំរឿង០០៣នោះនឹងត្រូវបានគោរពតាម លុះត្រាតែចៅក្រម *Mark Harmon* (ម៉ាក់ ហាម៉ុន) ដែលទទួលតំណែងបន្តនោះទទួលយកសេចក្តីសម្រេចមកអនុវត្ត ។ សេចក្តីសម្រេចថ្មីរបស់អង្គបុរេជំនុំជម្រះបានប្រកាន់យកលំនាំពីមុនដោយសារតែទស្សនៈរបស់ចៅក្រមជាតិនៅតែព្យាយាមលើកហេតុផលដដែលៗ នោះគឺភាពខ្វះខាតក្នុងការទទួលបានអំណាចរបស់ចៅក្រមកាស្ពឺ-អានសើមេត ដែលបានធ្វើឲ្យចៅក្រមពុំមានសិទ្ធិចាត់កិច្ចស៊ើបសួរ ។

ភាពគ្មានសុឆន្ទៈបន្តរបស់ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះក្នុងការទទួលស្គាល់ និងដោះស្រាយភាពមានចន្លោះផ្នែកនីតិវិធីដែលជាក់ស្តែង និងរីករាលដាលទាក់ទងនឹងការស៊ើបអង្កេតក្នុងសំណុំរឿង០០៣ អាចធ្វើឲ្យកើនឡើងនូវភាពមន្ទិលសង្ស័យដែលថាសំណុំរឿងនេះនឹងត្រូវអនុញ្ញាតឲ្យចាត់ការបន្តដោយអនុលោមតាមវិធានផ្ទៃក្នុង និងស្តង់ដារអន្តរជាតិរបស់តុលាការទោះបីជាមានសហចៅក្រមស៊ើបអង្កេតអន្តរជាតិថ្មីចូលមកកាន់តំណែងក៏ដោយ ។

**អាន ហាញឌុល**



# ខ្ញុំបាត់បង់ប្តី និង កូនពីរនាក់



លឹម គីមឡេង

ខ្ញុំកើតនៅខែមេសា ឆ្នាំ១៩៣៦ នៅភូមិរកាកោង ស្រុកមុខកំពូល ខេត្តកណ្តាល ដែលមានចម្ងាយប្រមាណ៤០គីឡូម៉ែត្រភាគខាងជើងក្រុងភ្នំពេញ ។ ឆ្នាំ១៩៥៣ ខ្ញុំបានរៀបការជាមួយប្តីរបស់ខ្ញុំឈ្មោះ គឹម ហេង ។ គាត់ គឺជាមន្ត្រីគយវ័យក្មេង និងសង្ហាម្នាក់ដែលមានអាយុ២៣ឆ្នាំ ។ ក្នុងជីវិតជាប្តីប្រពន្ធ យើងមានកូនប្រាំមួយនាក់ ស្រីបីនាក់ និងប្រុសបីនាក់ ។ កូនស្រីច្បងរបស់ខ្ញុំឈ្មោះ ធីតា កើតក្នុងឆ្នាំ១៩៥៥ ។ ពីរឆ្នាំក្រោយមក ខ្ញុំកើតបានកូនស្រីទីពីរ ហើយយើងដាក់ឈ្មោះថា ចិន្តា ។ ក្រោយមក ខ្ញុំមានកូនប្រុសបីនាក់ទៀតដែលកើតឆ្លាស់គ្នារាល់ពីរឆ្នាំម្តង ។ កូនប្រុសទាំងនោះមានឈ្មោះថា គន្ធា រិទ្ធា និង គន្ធី ។ កូនពៅរបស់ខ្ញុំ គឺកូនស្រីឈ្មោះ គុន្ធារី កើតក្នុងឆ្នាំ១៩៦៨ ។

ដោយសារប្តីរបស់ខ្ញុំគឺជាមន្ត្រីគយ គាត់ត្រូវធ្វើដំណើរទៅជាច្រើនកន្លែង ។ ដូច្នេះហើយ កន្លែងរស់នៅរបស់យើងក៏ត្រូវផ្លាស់ប្តូរតាមកន្លែងដែលប្តីខ្ញុំធ្វើការដែរ ។ ខ្ញុំចាំថា កន្លែងដំបូងដែលយើងរស់នៅគឺនៅទីប្រជុំជនក្រែកក្នុងខេត្តកំពង់ចាមជិតព្រំដែនវៀតណាម ។ ទីនោះក៏ជាកន្លែងដែលកូនពីរនាក់ដំបូងរបស់ខ្ញុំចាប់កំណើត ។ បន្ទាប់ពីនោះមក យើងផ្លាស់ប្តូរទីលំនៅទៅបាភ្នំ (ជិតអ្នកលឿង) បន្ទាប់មក ទៅភ្នំដិន ខេត្តតាកែវ ជាប់ព្រំដែនម្ខាងទៀតនៃប្រទេសវៀតណាម ។ បន្ទាប់ពីស្នាក់នៅភ្នំដិន យើងបានផ្លាស់ទីលំនៅទៅនៅកំពង់សោម និងកន្លែងជាច្រើនដែលខ្ញុំមិនអាចចងចាំអស់ ។ ប៉ុន្តែកន្លែងចុងក្រោយដែលប្តីខ្ញុំ និងខ្ញុំរស់នៅមុនពេលទៅរស់នៅអចិន្ត្រៃយ៍នៅភ្នំពេញក្នុងឆ្នាំ១៩៧០ គឺប៉ោយប៉ែតជិតព្រំដែនថៃ ។

នៅភ្នំពេញ ផ្ទះរបស់យើងមានទីតាំងជិតអតីតសណ្ឋាគារអំបាសាឌើរ (បច្ចុប្បន្នអគ្គនាយកដ្ឋានពន្ធដារ) ត្រង់មុំផ្លូវប្រសព្វមហាវិថីសហព័ន្ធរុស្ស៊ី និងមហាវិថីម៉ៅសេទុង ។ អំឡុងពេលដែលខ្មែរក្រហមឡោមព័ទ្ធក្រុងភ្នំពេញក្នុងឆ្នាំ១៩៧៥ ផ្ទះរបស់ខ្ញុំស្ថិតក្នុងតំបន់ដែលគ្រាប់ផ្លោងធ្លាក់ ដូច្នេះហើយ យើងបានផ្លាស់ទីលំនៅដើម្បីស្វែងរកទីជម្រកនៅវត្តខណ្ឌលោម ។ នៅព្រឹកថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ពេលដែលខ្មែរក្រហមចូលដល់ក្រុងភ្នំពេញ យើងបានត្រឡប់មកផ្ទះរបស់យើងវិញ ។ នៅទីនោះ យើងបានជួបសាច់ញាតិមួយចំនួនដែលត្រូវបានជម្លៀសពីការប្រយុទ្ធគ្នា ។ ដោយមិនដឹងថានឹងត្រូវធ្វើអ្វី យើងសម្រេចចិត្តស្នាក់នៅក្នុងផ្ទះហើយរង់ចាំស្ថានការណ៍ធូរស្រាល ។ នៅពេលរសៀល យើងបានឮសំឡេងគោះទ្វារ និងសំឡេងចម្លែកនៅខាងក្រៅ ភ្លាមនោះ ប្តីរបស់ខ្ញុំបានទៅកាន់ទ្វារដើម្បីបើកទ្វារ ហើយបានឃើញយោធាខ្មែរក្រហមពីរបីនាក់ដែលបានបង្ខំឲ្យប្រជាជនចាកចេញពីទីក្រុង ។ យោធាខ្មែរក្រហមទាំងនោះបានប្រាប់យើងឲ្យចេញពីផ្ទះតែពីរបីថ្ងៃប៉ុណ្ណោះ ។ ដូច្នេះហើយ យើងមិនចាំបាច់យកអីវ៉ាន់ទៅជាមួយច្រើនទេ ។ ដោយសារតែភ័យស្ទន់ស្ទោរ ប្តីខ្ញុំនិងខ្ញុំក៏ស្តាប់តាមពាក្យយោធាខ្មែរក្រហមទាំងនោះ ។ យើងបានចាកចេញភ្លាមៗ ដោយមិនបានយកម្ហូបបម្រុងទុកសម្រាប់ការស្នាក់នៅរយៈពេលវែងទេ ។

រួមដំណើរជាមួយគ្នាគឺ ម្តាយរបស់ខ្ញុំ កូនប្រសារ (ប្តីរបស់ធីតា) និងកូនទើបនឹងកើតរបស់ ធីតា សរុបទៅមានសមាជិក១១នាក់ រួមបញ្ចូលបងប្អូនសាច់ឆ្ងាយប្រាំនាក់ផ្សេងទៀត ។ យើងបានផ្ទុកអីវ៉ាន់ក្នុងឡានពីរគ្រឿង និងចាប់ផ្តើមធ្វើដំណើរឆ្ពោះទៅទិសខាង

លិច ។ ដំបូង យើងបើកឡាន យឺតៗ ខណៈដែលមានមនុស្សម្នាដើរពាសពេញផ្លូវ ។ មួយស្របក់ក្រោយមក យើងមិនអាចបើកឡានតាមផ្លូវដែលកកស្ទះនោះឡើយ ។ ដូច្នេះហើយ យើងបើកយឺតៗ ។ ពេលដែលយើងបើកដល់ផ្លូវបំបែកឆ្ពោះទៅខេត្តតាកែវ យើងបានសម្រេចចិត្តស្នាក់នៅទីនោះមួយយប់ពីព្រោះមេឃងងឹតពេករហូតដល់មិនអាចបន្តការធ្វើដំណើររបស់យើងបាន ។ យើងស្នាក់នៅទីនោះពីរបីថ្ងៃ ដើម្បីគិតរកកន្លែងធ្វើដំណើរជាបន្ត ។ នៅពេលនោះ ខ្មែរក្រហមបានបញ្ជាឲ្យយើងចាកចេញពីឡាន ។ ដូច្នេះចាប់តាំងពីពេលនោះមក យើងទាំងអស់គ្នាត្រូវស្ពាយអីវ៉ាន់ទាំងអស់នៅលើខ្នង ។ យើងគិតថា នឹងទៅខេត្តតាកែវ ប៉ុន្តែប្តីរបស់ខ្ញុំព្រួយបារម្ភពីប្រវត្តិរូបរបស់ខ្លួនជាមន្ត្រីគយ ដែលប្រហែលជាអាចគ្រោះថ្នាក់ ដោយសារតែខ្មែរក្រហមបានចាប់ផ្តើមចាប់ខ្លួនអតីតមន្ត្រីរាជការរបបមុន ។

ជាការប្រុងប្រយ័ត្ន កូនប្រសាររបស់ខ្ញុំបានស្ម័គ្រចិត្តទៅខេត្តតាកែវត្រួតពិនិត្យមើលស្ថានភាពជាមុនសិនថាតើយើងអាចទៅរស់នៅទីនោះបានឬអត់ ។ ពេលដែលកូនប្រសាររបស់ខ្ញុំទៅខេត្តតាកែវ ខ្មែរក្រហមបញ្ជាយើងធ្វើដំណើរតាមផ្លូវជាតិលេខ៤ ។ ដូច្នេះ យើងធ្វើដំណើរតាមផ្លូវជាតិលេខ៤ ។ កូនប្រសារប្រុសរបស់ខ្ញុំបានបែកពីខ្ញុំនៅទីនោះ ។ បន្ទាប់ពីយើងធ្វើដំណើរជាច្រើនគីឡូម៉ែត្រ យោធាខ្មែរក្រហមបានបង្គាប់ឲ្យធ្វើដំណើរតាមផ្លូវលំឆ្ពោះទៅលិច ។ នៅតាមផ្លូវ យើងឃើញសាកសពជាច្រើន ប្រហែលជាសាកសពរបស់កងទ័ពដែលត្រូវបានសម្លាប់អំឡុងពេលប្រយុទ្ធគ្នា ។ នៅពេលល្ងាច យើងបានទៅដល់ភូមិមួយ ហើយបានត្រៀមរៀបចំកន្លែងសម្រាកនៅក្នុងបរិវេណវត្តមួយ ។ នៅពេលដែលយើងហៀបនឹងសម្រាក ខ្មែរក្រហមបានមកដល់ ហើយបញ្ជាយើងទាំងអស់គ្នាឲ្យត្រឡប់ទៅកន្លែងដើមដែលយើងទើបតែបានចាកចេញ ។ ដូច្នេះហើយ យើងបានដើរត្រឡប់ទៅផ្លូវជាតិលេខ៤វិញ ។ យើងមិនមែនជាគ្រួសារតែមួយដែលខ្មែរក្រហមបញ្ជាឲ្យវិលទៅលំនៅនោះទេ ។ មានមនុស្សរាប់សិបនាក់ មានវាសនាដូចយើងដែរ ។ យើងដើរនៅពេលយប់ ដែលពេលនោះ មេឃកំពុងតែភ្លៀងដែលបង្ខំឲ្យមនុស្សគ្រប់គ្នាស្វែងរកជម្រកក្រោមដើមឈើ ឬក៏ក្រោមផ្ទះដែលបោះបង់ចោល ឬទីជម្រកបែបណាក៏ដោយឲ្យតែយើងអាចស្វែងរកបាន ។ នៅពេលព្រលឹមស្រាងៗ មុនពេលព្រះអាទិត្យរះ ខ្មែរក្រហមបានមកហើយបញ្ជាមនុស្សគ្រប់គ្នាឲ្យធ្វើដំណើរជាបន្ត ។ យើងដើរជាច្រើនម៉ោង ហើយនៅពេលរសៀល មានឡានខ្មែរក្រហមមួយចំនួនបានមកដល់ ។ អ្នកបើកឡានដែលជាយោធាខ្មែរក្រហមបានសួរយើងថាតើយើងកំពុងទៅណា ។ ប្តីរបស់ខ្ញុំបានប្រាប់ថា យើងអត់មានគោលដៅច្បាស់លាស់នោះទេ ។ ដូច្នេះយោធាខ្មែរក្រហមនោះ បានដឹកយើងទៅទីជនបទ ។ នៅពេលនោះ យើងអស់សង្ឃឹមថានឹងអាចវិលត្រឡប់មកភ្នំពេញវិញ និងចាកចេញពីហ្វូងមនុស្សដែលត្រូវបានជម្លៀសដូចសត្វ ។ យើងជិះឡានជាមួយពីរបីគ្រួសារផ្សេងទៀត ។ ឡានរបស់យោធាខ្មែរក្រហមបានដឹកយើងតាមផ្លូវជាតិលេខ៤លើចម្ងាយផ្លូវប្រហែល១០គីឡូម៉ែត្រ ហើយបន្ទាប់មកបត់ស្តាំទៅរកផ្លូវលំ ។ ខ្ញុំមិនដឹងថាតើយើងកំពុងតែឆ្ពោះទៅទីណាទេ ។ ប៉ុន្តែ បើតាមខ្ញុំមើលព្រះអាទិត្យ យើងកំពុងធ្វើដំណើរឆ្ពោះទៅរកទិសនិរតីនៃក្រុងភ្នំពេញ ។ ឡាននោះបានដឹកយើងទៅភូមិជនបទតូចមួយដែលមានប្រជាជនជម្លៀសជាច្រើន ។ យើងត្រូវយោធាខ្មែរក្រហមទម្លាក់ចោលនៅទីនោះ ។ យប់នោះ កម្មាភិបាលខ្មែរក្រហមបានមកកត់ឈ្មោះយើង ហើយប្រាប់ថា យើងនឹងត្រូវបញ្ជូនទៅរស់នៅក្នុងភូមិត្រពាំងចាបលុង ។ ថ្ងៃបន្ទាប់ យើងបានដើរទៅភូមិត្រពាំងចាបលុង ។ យើងបានរស់នៅក្នុងភូមិត្រពាំងចាបលុងរយៈពេលពីរបីខែ ពេលនោះហើយដែលកូនរបស់ ធីតា ដែលនៅក្មេងផងនោះ បានស្លាប់ដោយសារការខ្វះអាហារ ។ បន្ទាប់មកខ្មែរក្រហមបានបញ្ជាឲ្យយើងត្រៀមខ្លួនបន្តដំណើរទៅកន្លែងថ្មី ។ ល្ងាចនោះ យើងឃើញរទេះគោជាច្រើនសំដៅមកដឹកយើងទៅកន្លែងថ្មី ។ យើងធ្វើដំណើរពេញមួយយប់ ។ នៅម៉ោងប្រហែលជា៨ព្រឹក យើងបានទៅដល់ក្រុងខត្តុងដ៏ចំណាស់ ។ នៅទីនោះ ម្តាយរបស់ខ្ញុំបានបែកពីខ្ញុំ ពេលដែលគាត់ទៅរកាកោង ដែលពេលនោះ ខ្មែរក្រហមកំពុងបញ្ជូនយើងទៅកន្លែងថ្មី ។

នៅពេលទៅដល់ខត្តុង យើងឃើញមនុស្សរាប់ពាន់នាក់បានប្រមូលផ្តុំគ្នានៅទីនោះ ។ ឡានជាច្រើនកំពុងរង់ចាំដឹកយើងបន្តដំណើរទៅមុខទៀត ។ យើងបានឡើងជិះឡានមួយគ្រឿង ។ នៅពេលដែលឡានមានមនុស្សឡើងជិះគ្រប់គ្នាអស់ហើយ អ្នកបើកបានចេញដំណើរតាមបណ្តោយផ្លូវជាតិលេខ៥ ឆ្ពោះទៅខេត្តបាត់ដំបង ។

ឡានរបស់យើងបានឈប់ឲ្យយើងសម្រាកម្តងម្កាល ។ យើងបានចំណាយពេលមួយយប់នៅពេលធ្វើដំណើរមុនពេលដែលឡានបានដឹកយើងទៅដល់ភូមិព្រៃស្វាយ ស្រុកមោងឫស្សីនៅក្នុងខេត្តបាត់ដំបង ។ នៅទីនោះ អ្នកបើកឡានបានប្រាប់ឲ្យយើងចុះ ហើយត្រូវធ្វើដំណើរបន្តដោយថ្មើរជើងតាមផ្លូវលំឆ្ពោះទៅទីកន្លែងថ្មីដែលមានទីតាំងនៅភូមិចាមរអា ។

កន្លែងរស់នៅថ្មី គឺជាវាលសោះកក្រោះ ។ មនុស្សគ្រប់គ្នាត្រូវតែរៀនរស់ចិញ្ចឹមជីវិតដោយខ្លួនឯង ។ មានមនុស្សយ៉ាងច្រើនរស់នៅទីនោះ ។ ភ្លាមនោះ យើងចាប់ផ្តើមកាប់ព្រៃហើយសង់ខ្ទមជាទីជម្រក ។ ពីរបីថ្ងៃក្រោយមក ខ្មែរក្រហមបានបញ្ជាយើងឲ្យកាប់ព្រៃដើម្បីដាំដំឡូង ឬក៏ធ្វើស្រែ ។ យើងត្រូវបានចាត់តាំងឲ្យចូលជាកងចល័ត ។ ប្តីរបស់ខ្ញុំត្រូវខ្មែរក្រហមបញ្ជូនឲ្យទៅកាប់ព្រៃ ចំណែកកូនស្រីច្បង និងកូនប្រុសរបស់ខ្ញុំត្រូវបានបញ្ជូនឲ្យទៅធ្វើស្រែឆ្ងាយពីភូមិ ។ សូម្បីតែកូនប្រុសពៅ និងកូនស្រីពៅរបស់ខ្ញុំ គន្ធី និង គន្ធារី ក៏ត្រូវធ្វើការងារនៅវាលស្រែដែរ ។ ខ្ញុំត្រូវបានអនុញ្ញាតឲ្យធ្វើការនៅក្បែរភូមិ ។ ដូច្នេះហើយ ខ្ញុំមានឱកាសដើម្បីត្រឡប់ទៅផ្ទះរៀងរាល់ល្ងាច ។ ខ្ញុំកម្រឃើញសមាជិកគ្រួសារដទៃរបស់ខ្ញុំណាស់ លើកលែងតែកូនតូចៗពីរនាក់របស់ខ្ញុំដែលត្រឡប់មកផ្ទះម្តងម្កាល ។

ចាមរអា គឺជាកន្លែងដ៏លំបាកដើម្បីចិញ្ចឹមជីវិត ។ មិនមានធនធានធម្មជាតិច្រើនដើម្បីជួយយើងឲ្យរស់នៅបានស្រួលនោះទេ ។ មនុស្សចាប់ផ្តើមស្លាប់ដោយសារភាពអត់ឃ្លានចាប់តាំងពីថ្ងៃដែលយើងទៅដល់ ។ រៀងរាល់ថ្ងៃមនុស្សជាច្រើនបានស្លាប់ ។

ពីរបីខែបន្ទាប់ពីយើងមកដល់ចាមរអា កូនប្រុសច្បងរបស់ខ្ញុំ គន្ធា និង រិទ្ធា ជាមួយនឹងក្មួយប្រុសម្នាក់របស់ខ្ញុំបានសម្រេចចិត្តរត់គេចចេញពីកងចល័ត ហើយត្រឡប់ទៅស្រុកកំណើតនៅស្រុកមុខកំពូល ខេត្តកណ្តាលវិញ ។ នោះគឺជាការប៉ុនប៉ងរត់គេចដោយប្រថុយប្រថានបំផុតដោយសារចម្ងាយពីចាមរអាទៅមុខកំពូលយ៉ាងហោចណាស់ក៏១៦០គីឡូម៉ែត្រដែរ ។ កូនខ្ញុំទាំងនោះបានរត់ទៅដល់ស្រុកក្រគរ ខេត្តពោធិ៍សាត់ ក៏ត្រូវខ្មែរក្រហមចាប់ខ្លួនហើយឃាត់ឲ្យនៅទីនោះធ្វើការជាមួយប្រជាជនមូលដ្ឋាន ។ ខ្ញុំបានដឹងពីការរត់គេចបន្ទាប់ពីវៀតណាមចូលមកដល់កម្ពុជាក្នុងឆ្នាំ១៩៧៩ ហើយពេលដែលខ្ញុំបានជួប រិទ្ធា ដែលជាអ្នករស់រានមានជីវិតតែមួយគត់ដែលបានប្រាប់ខ្ញុំពីការធ្វើដំណើរនោះ ។ រិទ្ធា អាចរស់រានមានជីវិតដោយសារយោធាខ្មែរក្រហមយកទៅរស់នៅបឹងទន្លេសាបដើម្បីធ្វើការងារជួយខាងកងនេសាទ ។

ស្ថានភាពរស់នៅក្នុងចាមរអា កាន់តែដុនដាបទៅៗជារៀងរាល់ថ្ងៃ ។ ក្លិនស្អុយសាកសពនៅជុំវិញខ្លួនរបស់យើង និងនៅពាសពេញទីកន្លែង ។ មនុស្សស្លាប់គ្រប់ទីកន្លែង ។ អ្នកខ្លះស្លាប់នៅវាលស្រែ អ្នកខ្លះស្លាប់នៅផ្ទះ អ្នកខ្លះស្លាប់នៅមន្ទីរពេទ្យ ។ ភ្លាមៗនោះស្ថានភាពនៅក្នុងភូមិបានប្រែទៅជាសភាពស្ងប់ស្ងាត់ ដូចទីក្រុងខ្មោច ។ មនុស្សដែលរស់នៅក្នុងខ្ទមក្បែរខ្ញុំ បានស្លាប់ទាំងអស់ ។

ថ្ងៃមួយ ខ្ញុំឃើញកូនស្រីរបស់ខ្ញុំ គន្ធី បានមកផ្ទះក្នុងស្ថានភាពដ៏យ៉ាប់យ៉ឺន ។ គន្ធី ធ្លាក់ខ្លួនស្គមកំព្រឹង និងមានជំងឺផង ។ ដោយសារតែខ្ញុំត្រូវទៅធ្វើស្រែ ខ្ញុំមិនអាចថែទាំកូនខ្ញុំបានល្អឡើយ ។ ខ្ញុំបានប្រាប់កូនស្រីតូចរបស់ខ្ញុំឲ្យទៅស្នាក់នៅជាមួយបងស្រីដែលកំពុងឈឺ ហើយកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យ ។

ថ្ងៃបន្ទាប់ ពេលដែលខ្ញុំទៅសួរសុខទុក្ខកូនស្រីទាំងពីរនៅមន្ទីរពេទ្យនៅតាមផ្លូវទៅធ្វើការ ខ្ញុំឃើញកូនស្រីតូចរបស់ខ្ញុំឈ្មោះ គន្ធារី ស្លាប់រួចមកហើយ ។ ធីតា បានប្រាប់ខ្ញុំថា គន្ធារី បានស្លាប់កាលពីយប់ម្សិលមិញ ។ ការឃើញកូនស្រីតូចរបស់ខ្ញុំក្នុងស្ថានភាពយ៉ាប់យ៉ឺន គឺជារឿងលំបាកបំផុតសម្រាប់ខ្ញុំ ។ ខ្ញុំជូតទឹកភ្នែក ហើយត្រឡប់ទៅធ្វើការដោយសារតែខ្ញុំមិនត្រូវបានអនុញ្ញាតឲ្យយកសាកសពកូនចេញពីមន្ទីរពេទ្យឡើយ ។ កម្មាភិបាលនៅមន្ទីរពេទ្យគឺជាអ្នកទទួលខុសត្រូវខាងដុតសាកសព ។

ពីរថ្ងៃក្រោយមក ខ្ញុំទៅលេង ធីតា ម្តងទៀតនៅមន្ទីរពេទ្យ ។ ខ្ញុំឃើញកូនស្រីខ្ញុំលើកកែវទទេដាក់មាត់ដែលហាក់បីដូចជាកំពុងព្យាយាមផឹកទឹក ។ ដូច្នេះហើយខ្ញុំសួរថា “កូនចង់ហូបទឹកឬ” ? កូនខ្ញុំក៏ងក់ក្បាល ។ ខ្ញុំបានទៅដួសទឹកឲ្យកូនផឹក ។

នៅពេលដែលខ្ញុំត្រឡប់ពីធ្វើការ ខ្ញុំបានទៅមន្ទីរពេទ្យម្តងទៀតដើម្បីមើលថាតើ ធីតា មានអាការយ៉ាងម៉េចហើយ ។ នៅពេលដែលខ្ញុំបានទៅដល់មន្ទីរពេទ្យ ធីតា បានស្លាប់រួចទៅហើយ ។ នៅពេលនោះខ្ញុំមានទុក្ខព្រួយយ៉ាងខ្លាំង ។ ខ្ញុំអង្គុយក្បែរសាកសពកូនស្រីខ្ញុំ ជាមួយក្តីសង្វេគយ៉ាងខ្លាំង ។ ប៉ុន្តែ ខ្ញុំមិនបានស្រក់ទឹកភ្នែក ។ ទឹកភ្នែកហាក់បីដូចជាហួតអស់រលីង ។ ល្ងាចនោះ ប្តីរបស់ខ្ញុំបានត្រឡប់មក

ផ្ទះ ពេលដែលទទួលដំណឹងថាយើងបានបាត់បង់កូនពីរនាក់ ក្នុងរយៈពេលបីថ្ងៃ គាត់បានឱបខ្ញុំហើយបានខ្សឹបដាក់ត្រចៀកដោយប្រាប់ខ្ញុំឲ្យរឹងមាំឡើង ហើយថាការឈឺចាប់ និងទុក្ខលំបាកនឹងមិននៅយូរទេ ។

ថ្វីបើយើងមានទុក្ខព្រួយ បន្ទាប់ពីកូនស្រីទាំងពីររបស់យើងបានស្លាប់ យើងមិនត្រូវបានអនុញ្ញាតឲ្យកាន់ទុក្ខ និងបង្ហាញភាពទុក្ខព្រួយនោះឡើយ ។ ប្តី និងខ្ញុំត្រូវត្រឡប់ទៅធ្វើការវិញ ហាក់បីដូចជាគ្មានរឿងអ្វីកើតឡើងនោះឡើយ ។

ពីរបីសប្តាហ៍ក្រោយមក បន្ទាប់ពីប្តីរបស់ខ្ញុំត្រឡប់ទៅរានព្រៃដើម្បីដាំដំឡូងនៅដំណាក់ដាង ខ្ញុំបានទទួលដំណឹងថា ប្តីរបស់ខ្ញុំបានស្លាប់ដោយសារតែដាច់សរសៃឈាមក្នុងខួរក្បាល ។ ទោះបីជាខ្ញុំមានមន្ទិលសង្ស័យអំពីស្ថានភាពដែលគាត់ស្លាប់ ខ្ញុំមិនមានមធ្យោបាយណាមួយស្វែងរកសេចក្តីលម្អិតក្រៅពីទទួលយកអ្វីដែលខ្ញុំបានដឹង ។

ដោយក្តីតក់ស្លុត ខ្ញុំបានលត់ជង្គង់ និងដួលនឹងកន្លែង ។ អ្នកនៅក្នុងកងជាមួយបានជួយគ្រាខ្ញុំត្រឡប់ទៅខ្ទមវិញ ។ ខ្ញុំបានបាត់បង់កូនពីរនាក់ និងប្តីក្នុងរយៈពេលតែមួយខែប៉ុណ្ណោះ ។ ការឈឺចាប់ គឺហួសពីការបរិយាយ ។

បន្ទាប់ពីប្តីរបស់ខ្ញុំស្លាប់ ខ្ញុំត្រូវបានចាត់តាំងឲ្យទៅរានព្រៃដើម្បីដាំដំឡូងនៅក្នុងព្រៃជ្រៅមួយ ។ កាលនោះ ខ្ញុំនៅសល់តែកូនពីរនាក់ប៉ុណ្ណោះ គឺ ចិន្តា និង គន្ធី ប៉ុន្តែ ខ្ញុំមិនដឹងថាកូនទាំងពីរនៅរស់ប្រយ៉ាងណាទេ ដោយសារយើងធ្វើការនៅកន្លែងផ្សេងគ្នា ។ អំឡុងពេលដែលខ្ញុំរស់នៅក្នុងព្រៃ អាហារហូបចុក គឺជាបបរលាយជាមួយមើមដំឡូងដែលជាអាហារសម្រាប់ចិញ្ចឹមជ្រូក ។ ប៉ុន្តែ ដោយសារតែខ្វះម្ហូបអាហារ យើងត្រូវតែហូបរបស់នោះដើម្បីរស់រានមានជីវិត ។

ពីរបីខែបន្ទាប់ពីទៅធ្វើការនៅក្នុងជំរំក្នុងព្រៃ ខ្ញុំបានកើតរោគរាកដែលធ្វើឲ្យខ្ញុំមិនអាចធ្វើការធ្ងន់កាប់ព្រៃបានឡើយ ។ ខ្ញុំទន់ខ្សោយរហូតដល់មិនអាចធ្វើការងារណាមួយបាន ។ ដូច្នេះ មេកងបានបញ្ជូនខ្ញុំត្រឡប់ទៅភូមិដើម្បីធ្វើការជាអ្នកតម្បាញជាមួយកងយាយៗ ។

មិនមានមនុស្សច្រើននៅក្នុងភូមិនោះឡើយ ។ នៅក្នុងភូមិមានសភាពស្ងប់ស្ងាត់ចម្លែក ។ ខ្ញុំបានដើរទៅខ្ទមរបស់ខ្ញុំ ហើយក៏ឃើញក្មេងស្រីតូចម្នាក់ដើរនៅក្បែរនោះ ។ អ្នកភូមិផ្សេងទៀតបានបាត់ខ្លួនជាបន្តបន្ទាប់ ។ ដោយសារមនុស្សបានស្លាប់ជារឿយៗ មេភូមិបានបញ្ជាអ្នកភូមិឲ្យបោះទីតាំងថ្មីនៅសហករណ៍ ដូច្នេះហើយកម្មាភិបាលខ្មែរក្រហមកាន់តែមានភាពងាយក្នុងការគ្រប់គ្រងពិនិត្យមនុស្សគ្រប់គ្នា ។

ជាច្រើនខែក្រោយមក កម្មាភិបាលខ្មែរក្រហមបានបង្ខំខ្ញុំឲ្យរៀបការម្តងទៀត ។ ខ្មែរក្រហមមិនអនុញ្ញាតឲ្យយើងជ្រើសរើសដៃគូនោះឡើយ ។ នៅពេលណាក៏ដោយដែលកម្មាភិបាលខ្មែរក្រហមយល់ថាចង់រៀបការនរណាម្នាក់ កម្មាភិបាលទាំងនោះនឹងផ្គូផ្គងហើយប្រាប់ថាអ្នកទាំងនោះនឹងត្រូវរៀបការ ។ សម្រាប់ករណីរបស់ខ្ញុំ អ្នកធ្វើការជាមួយឈ្មោះយាយ ង៉ែត បានប្រាប់ខ្ញុំថាត្រូវបានរាយការណ៍ទៅសហករណ៍ ។ នៅពេលដែលខ្ញុំទៅដល់ទីនោះ ខ្ញុំបានជួបជាមួយប្រធានសហករណ៍ និងយោធាពីរបីនាក់ ។ យោធាខ្មែរក្រហមទាំងនោះប្រាប់ខ្ញុំថា គេនឹងរៀបការខ្ញុំជាមួយបុរសឈ្មោះ ដាង ជាមនុស្សកាចសាហាវម្នាក់ ។ បន្ទាប់ពីដឹងថា កម្មាភិបាលខ្មែរក្រហមមានផែនការរៀបការខ្ញុំជាមួយនឹងបុរសឈ្មោះ ដាង ខ្ញុំធ្លាក់ថ្លើមក្តុក ។ ខ្ញុំព្យាយាមរកលេសដើម្បីគេចពីការរៀបការដោយបង្ខំនេះ ។ ខ្ញុំសុំអង្វរកម្មាភិបាលទាំងនោះឲ្យផ្តល់ពេលវេលាខ្លះដើម្បីគិតអំពីរឿងនោះ ដោយសារប្តីរបស់ខ្ញុំទើបតែស្លាប់មិនដល់១ឆ្នាំផង ។ នៅពេលនោះ កម្មាភិបាលខ្មែរក្រហមម្នាក់បានប្រាប់ខ្ញុំថា នឹងអនុញ្ញាតឲ្យខ្ញុំគិតសិនមួយរយៈ ។

បន្ទាប់ពីប្រាប់ខ្ញុំរួចមក កម្មាភិបាលខ្មែរក្រហមបានចាត់តាំងខ្ញុំឲ្យត្រឡប់ទៅធ្វើការវិញ ។ ខ្ញុំដើរត្រឡប់ទៅកន្លែងធ្វើការដោយទឹកភ្នែក ។ យាយ ង៉ែត ដែលកំពុងរង់ចាំចង់ដឹងអំពីការប្រជុំរបស់ខ្ញុំជាមួយប្រធានសហករណ៍បានមកសួរអំពីស្ថានការណ៍ទាំងនោះ ។ ខ្ញុំបានប្រាប់យាយ ង៉ែត អំពីផែនការដើម្បីរៀបការខ្ញុំជាមួយនឹងបុរសឈ្មោះ ដាង ហើយថា ខ្ញុំគ្មានជម្រើស ប៉ុន្តែត្រូវទទួលយកការចាត់តាំងនេះ ។

យាយ ង៉ែត មានការតក់ស្លុតពេលដែលឮអំពីស្ថានការណ៍ដ៏លំបាកនេះ ដោយសារគាត់ដឹងថាបុរសឈ្មោះ ដាង មិនត្រឹមតែជាមនុស្សកាចសាហាវទេ ថែមទាំងជាជនអសីលធម៌ទៀតផង ។ ដាង ចូលចិត្តប្រព្រឹត្តអំពើហិង្សាណាស់ ។ នៅពេលដែលខ្ញុំក្លាយទៅជាប្រពន្ធរបស់គាត់ ដាង នឹងប្រព្រឹត្តអំពើមិនសមរម្យដាក់ខ្ញុំជាមិនខាន ។

ដោយសារ យាយង៉ែត ចង់ស្វែងរកដំណោះស្រាយរត់គេច គាត់បានទៅជួបកូនរបស់គាត់ ឈ្មោះ ញ៉ារ ដែលជាមេក្រុមដាងដែក

នៅសហករណ៍ ។ អ្នកដែលធ្វើការក្រោមញ៉ារ គឺឈ្មោះ ស៊ីនួន ដែលមានប្រពន្ធ និងកូនបានស្លាប់ដោយការបង្អត់អាហារ ។ ស៊ីនួន គឺជាគ្រូពេទ្យដែលបានជម្លៀសចេញពីភ្នំពេញ ។ មនុស្សគ្រប់គ្នានៅក្នុងភូមិហៅគាត់ថាជាជនពិការ ហើយគាត់រស់នៅតែម្នាក់ឯងជិតរោងជាងដែកដែលមានទីតាំងនៅចុងភូមិ ។ ដើម្បីបំបែកខ្ញុំពីការរៀបការជាមួយ ជាង នោះ ញ៉ារ បានស្នើថា ខ្ញុំគួរតែរៀបការជាមួយ ស៊ីនួន មុនពេលដែលកម្មាភិបាលខ្មែរក្រហមដែលចង់ឲ្យខ្ញុំរៀបការជាមួយ ជាង នោះត្រឡប់មកពីការដ្ឋានឆ្ងាយពីភូមិវិញ ដូច្នេះផែនការរបស់កម្មាភិបាលនោះនឹងមិនអាចកើតឡើងនោះទេ ។

បន្ទាប់ពីខ្ញុំយល់ព្រមចំពោះផែនការនេះ ស៊ីនួន បានមកជួប និងប្រាប់ខ្ញុំថា គាត់ដឹងអំពីការរត់គេច ហើយយល់ព្រមចំពោះការស្នើរបស់ញ៉ារ ។ ស៊ីនួន បាននិយាយថា «នៅពេលដែលរបបផ្ដាច់ការខ្មែរក្រហមនេះដួលរលំ យើងនឹងមានសេរីភាពក្នុងការចែកផ្លូវគ្នា ប្រសិនបើយើងសម្រេចចិត្តដូច្នេះ» ។ ស៊ីនួន បាននិយាយលើកឡើងហាក់បីដូចជាគាត់ដឹងថា ការលំបាករបស់យើងក្រោមរបបខ្មែរក្រហមនឹងមិននៅយូរអង្វែងឡើយ ។ នៅពេលនោះ យើងទាំងអស់គ្នាយល់ស្របនឹងធ្វើតាមផែនការនេះ ។

ញ៉ា មានបងប្រុសម្នាក់ដែលជាគណៈស្រុក ដូច្នេះហើយ ដោយប្រើប្រាស់ទំនាក់ទំនងខាងនយោបាយរបស់គាត់ គាត់ទទួលបានការអនុញ្ញាតជាពិសេស ហើយបានរៀបចំឲ្យ ស៊ីនួន និងខ្ញុំបានរៀបការក្នុងរយៈពេលពីរថ្ងៃបន្ទាប់ពីយើងយល់ព្រមចំពោះផែនការនេះ ។

ពិធីរៀបការរបស់យើងមានលក្ខណៈដោយឡែកដែលផ្ទុយទៅនឹងការរៀបការច្រើនគូដែលរៀបចំឡើងដោយខ្មែរក្រហម ។ កាលនោះ មានតែការរៀបការពីរបីគូប៉ុណ្ណោះ ។ ញ៉ារ និងប្រធានគណៈសហករណ៍ពីរបីនាក់ផ្សេងទៀតបានរៀបចំតុមួយក្រោមផ្ទះធំមួយ ។ នៅខាងក្រោយតុមានទង់បក្សកុម្មុយនីស្តដ៏ធំមួយដែលមានរូបកណ្ដៀវ និងញញួរ ។ ស៊ីនួន និងខ្ញុំឈរនៅពីមុខតុ ពេលដែល ញ៉ា និងកម្មាភិបាលខ្មែរក្រហមដទៃអង្គុយនៅពីក្រោយ ដោយអានគោលការណ៍ទាក់ទងទៅនឹងកាតព្វកិច្ច និងការលះបង់ក្នុងនាមជាប្ដី និងប្រពន្ធចំពោះបុព្វហេតុរបស់ខ្មែរក្រហម ។ ការរៀបការនោះគឺជាការរៀបការដ៏ក្រៀមក្រំ និងស្ងប់ស្ងាត់ដែលញាំញីមនុស្សគ្រប់គ្នាអស់មួយជីវិត ។

ពីរបីថ្ងៃក្រោយបន្ទាប់ពីខ្ញុំរៀបការ ខ្ញុំត្រូវបានបញ្ជូនត្រឡប់ទៅធ្វើការនៅក្នុងជំរំឆ្ងាយពីភូមិម្ដងទៀត ។ នៅជំរំថ្មីនោះ ខ្ញុំត្រូវបានចាត់តាំងឲ្យធ្វើការនៅវាលស្រែ ដោយស្ទូងស្រូវ ឬមើលថែសំណាប ។ ខ្ញុំក៏ធ្លាក់ខ្លួនឈឺបន្ទាប់ពីពីរបីខែក្រោយមក ។ ខ្ញុំកើតរោគរាកមួលសាជាថ្មី ។ បន្ទាប់ពីខ្ញុំមិនអាចទប់ការរាកបាន ប្រធានសហករណ៍បានបញ្ជូនខ្ញុំត្រឡប់ទៅភូមិវិញ ។ បន្ទាប់ពីទៅដល់ផ្ទះ ស៊ីនួន ដែលជាប្ដីថ្មីរបស់ខ្ញុំ បានថែទាំខ្ញុំយ៉ាងយកចិត្តទុកដាក់ ហើយដោយមិននិយាយពាក្យអ្វីមួយម៉ាត់សោះ ស៊ីនួន បានទាញយកឈើច្រត់របស់គាត់ ហើយបានដើរទៅជួបកម្មាភិបាលខ្មែរក្រហមដែលត្រួតត្រាឃុំរបស់យើង ។ ម្ដងម្កាល គាត់បានត្រឡប់ទៅផ្ទះដោយនាំយកថ្នាំ និងដូងមកជាមួយ ។ បន្ទាប់ពីផឹកថ្នាំ និងទឹកដូងរួចស្ថានភាពរបស់ខ្ញុំចាប់ប្រសើរឡើង ហើយពីរបីថ្ងៃបន្ទាប់ជំងឺរាករបស់ខ្ញុំបានធូរស្បើយ ។

បន្ទាប់ពីជាសះស្បើយពីជំងឺ ខ្ញុំបានសួរ ស៊ីនួន ថាតើគាត់បានថ្នាំសង្កូវ និងដូងដោយរបៀបណា និងមកពីណា ទោះបីជារបស់ទាំងនោះខ្សត់ខ្សោយយ៉ាងណានោះ ។ ខ្ញុំពិតជាភ្ញាក់ផ្អើល និងភ័យខ្លាចនៅពេលដែលគាត់ប្រាប់ខ្ញុំថាគាត់បានប្រើជំនាញពេទ្យរបស់គាត់ដើម្បីជួយព្យាបាលកូនប្រុសរបស់កម្មាភិបាលខ្មែរក្រហមដែលឈឺធ្ងន់ ។ ជាការដឹងគុណកម្មាភិបាលខ្មែរក្រហមនោះ បានរក្សាការសម្ងាត់អំពីប្រវត្តិរូបរបស់គាត់ជាគ្រូពេទ្យដែលនោះគឺជាការដាក់ទោសប្រហារជីវិតនៅក្នុងរបបខ្មែរក្រហម ហើយថ្នាំសង្កូវ និងដូងត្រូវបានផ្ដល់ឲ្យគាត់នោះជាការដឹងគុណ ។

ខ្ញុំបានចំណាយពេលជាច្រើនថ្ងៃនៅក្នុងភូមិដើម្បីព្យាបាលជំងឺ ។ បន្ទាប់មក ខ្ញុំបានត្រឡប់ទៅធ្វើការជាធម្មតាវិញ ។ ដោយសារពោះរបស់ខ្ញុំងាយរាកខ្ញុំព្យាយាមប្រយ័ត្នប្រយែងចំពោះការហូបចុក ។ ប៉ុន្តែ ខ្ញុំពិតជាប្រយ័ត្នប្រយែងក្នុងការហូបចុក ។ ចាប់តាំងពីថ្ងៃទីមួយនៃការមកដល់ចាមរអា ភាពអត់ឃ្លាន បានគំរាមកំហែងដល់ការរស់នៅរបស់យើង ។

អំឡុងពេលនោះ ប្ដីរបស់ខ្ញុំឈ្មោះ ស៊ីនួន ដែលជាជនពិការគឺជាអ្នកដែលជួយសង្គ្រោះខ្ញុំ ។ ដោយសារគាត់ជាជនពិការគ្មាននរណាម្នាក់ផ្ដោតការយកចិត្តទុកដាក់លើរូបគាត់ឡើយ ។ ដូច្នេះ គាត់

មានសេរីភាពធ្វើការងារផ្សេងក្រៅពីការងារនៅមូលដ្ឋាន ។ គាត់បានបង្កើតអន្ទាក់ដាក់សត្វដើម្បីចាប់សារិកាកែវ និងលបចាប់ត្រី ហើយបានយកសត្វឲ្យខ្ញុំជាទៀងទាត់ ។ ខ្ញុំគិតថា ខ្ញុំ អាចរស់រានមានជីវិតបានពីរបបខ្មែរក្រហមដោយសារគុណបំណាច់របស់បុរសពិការម្នាក់នេះ បើគ្មានគាត់ទេ ខ្ញុំនឹងស្លាប់យូរណាស់មកហើយ ។

ដើម្បីប្រាប់អ្នកថាតើភាពអត់ឃ្លានធ្ងន់ធ្ងរយ៉ាងណានោះ អំឡុងពេលការស្នាក់នៅជាបណ្ដោះអាសន្ននៅចាមរអា មនុស្សចង់ស៊ីសាច់មនុស្សគ្នាឯងខ្លាំងណាស់ ។ ខ្ញុំខ្លួនឯងផ្ទាល់ប្រហែលជាបានហូបសាច់មនុស្សម្ដងនៅពេលដែលអ្នកជិតខាងរបស់ខ្ញុំឆាបឆ្នាំងជាមួយសាច់ដ៏ចម្លែក ។ បន្ទាប់ពីហូបរួច ខ្ញុំសួរអ្នកជិតខាងថា តើសាច់នោះគឺជាសាច់អ្វីនៅក្នុងបន្ទែឆា ។ គាត់ប្រាប់ខ្ញុំថា គាត់មិនដឹងទេ ។ គាត់បានសាច់នោះពីបុរសម្នាក់ដែលរស់នៅចុងភូមិ ។ ជាច្រើនខែក្រោយមករឿងនោះក៏ត្រូវបានលាតត្រដាងដោយបុរសម្នាក់នោះ គឺជាអ្នកស៊ីសាច់មនុស្ស បន្ទាប់ពីគាត់បានសម្លាប់កូនក្មេងម្នាក់ ។ នៅពេលស្រាវជ្រាវផ្ទះរបស់គាត់ មនុស្សម្នាបានរកឃើញឆ្អឹងកូនក្មេងកប់នៅក្រោមផ្ទះរបស់គាត់ ។

ខ្ញុំបានឃើញភស្ដុតាងជាច្រើន និងបានឃើញជនខ្រិដ្ឋដែលត្រូវបាននាំយកទៅសម្លាប់ចោល ។ ខ្ញុំបានដឹងរឿងហេតុនៅពេលក្រោយដែលបានកើតឡើងចំពោះកូនប្រុសពៅរបស់ខ្ញុំឈ្មោះ គន្ធី ដែលប្រហែលជាជនរងគ្រោះនៃអំពើខ្រិដ្ឋស៊ីសាច់មនុស្សនោះ ដោយសារកូនប្រុសពៅរបស់ខ្ញុំបានបាត់ខ្លួនដោយគ្មានបន្សល់ទុកដានអ្វីសោះ ។ ប្រសិនបើកូនប្រុសពៅរបស់ខ្ញុំបានស្លាប់ដោយសារការអត់ឃ្លាន ឬអ្វីមួយនោះ មនុស្សនឹងបានឃើញសាកសព ។

នៅចុងឆ្នាំ១៩៧៨ មានមនុស្សជាច្រើនបានមកដល់ ។ ពេលនោះ មិនមានមនុស្សថ្មីត្រូវបានជម្លៀសចេញពីទីក្រុងនោះឡើយ ប៉ុន្តែមានមនុស្សផ្សេងៗដែលរស់នៅតំបន់ភាគខាងកើតប្រទេសកម្ពុជាជិតព្រំដែនវៀតណាមបានមកដល់ ។ តាមរយៈមនុស្សថ្មីទាំងនោះ យើងបានដឹងថា ជម្លោះរវាងកម្ពុជា និងវៀតណាមនឹងកើតឡើង ។ មិនយូរប៉ុន្មាន យើងឃើញមានចលនាផ្លាស់ទីរបស់ទ័ពខ្មែរក្រហម ។ នៅចុងខែធ្នូ យើងបានឃើញយន្តហោះហោះពីលើក្បាលរបស់យើង ។ នៅពេលនោះ យើងដឹងថាការបញ្ចប់ទុកលំបាករបស់យើងខិតជិតមកដល់ហើយ ។

ខ្ញុំចងចាំថ្ងៃរំដោះយ៉ាងច្បាស់ ។ នៅពេលព្រឹក ខ្ញុំ និងស្ត្រីប្រហែលដប់នាក់ បានទៅបែនស្រូវនៅកន្លែងមួយដែលមិនឆ្ងាយពីសហករណ៍ ។ នៅពាក់កណ្ដាលព្រឹក កម្មាភិបាលខ្មែរក្រហមថ្មីដែលជាស្ត្រីក្មេងដែលត្រូវបានបញ្ជូនពីភូមិភាគនិរតីដើម្បីត្រួតពិនិត្យយើង បានហៅខ្ញុំឲ្យទៅសហករណ៍ហើយប្រាប់ខ្ញុំឲ្យចាកចេញពីកន្លែងនោះ ។ ដោយមិនស្គាល់ខ្ញុំ កម្មាភិបាលខ្មែរក្រហមថ្មីបានអង្កេតមើលខ្ញុំមួយរយៈហើយ ក៏យល់ថាដូចជាជាប់សាច់ញាតិនឹងខ្ញុំ ។ កម្មាភិបាលខ្មែរក្រហមថ្មីនោះ បានឲ្យគោមួយនឹម រទេះគោ និងអង្ករមួយចំនួន និងប្រាប់ខ្ញុំឲ្យត្រឡប់ទៅព្រៃស្វាយដែលមានទីតាំងនៅតាមបណ្ដោយផ្លូវជាតិលេខ៥ ។ នៅពេលនោះ ខ្ញុំដឹងថាខ្មែរក្រហមត្រូវបានផ្ដួលរំលំពីអំណាច ហើយទំព័រថ្មីនៃប្រវត្តិសាស្ត្រកម្ពុជានឹងចាប់ផ្ដើម ។

ខ្ញុំ បានប្រាប់ស្ត្រីដទៃ ដែលរវល់បែនស្រូវអំពីដំណឹងនោះ ។ យើងបានប្រញាប់ប្រញាល់ប្រមូលសមាជិកគ្រួសាររបស់យើងទៅព្រៃស្វាយ ។ ដោយសារខ្ញុំជាអ្នកទីក្រុង ខ្ញុំមិនដឹងពីរបៀបបររទេះគោឡើយ ។ ដោយអស់សង្ឃឹម ខ្ញុំបានស្នើសុំឲ្យបុរសម្នាក់ឈ្មោះ រ៉េត ជួយបររទេះគោ ។ រទេះគោនោះ គឺអ្នកជួយជីវិតយើងដោយសារប្ដីរបស់ខ្ញុំ ស៊ុនួន គឺជាជនពិការហើយមិនអាចដើរលើចម្ងាយផ្លូវឆ្ងាយដោយឈើច្រត់ឫស្សីបានឡើយ ។ ដូច្នេះហើយ យើងបានអនុញ្ញាតឲ្យគាត់ជិះរទេះគ្រប់ពេលវេលាទាំងអស់ពេលណាក៏ដោយដែលយើងធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយទៀត ។

នៅពាក់កណ្ដាលផ្លូវទៅព្រៃស្វាយ យើងបានជួបប្រទះទ័ពវៀតណាម ។ ទ័ពវៀតណាមបានឃាត់យើងដើម្បីត្រួតពិនិត្យមើលថា តើមានយោធាខ្មែរក្រហមកំពុងលាក់ខ្លួនដែរឬទេ ។ នៅពេលនោះប្ដីរបស់ខ្ញុំត្រូវសង្ស័យថាជាយោធាខ្មែរក្រហម ពីព្រោះគាត់បានពាក់អាវពណ៌គគីរបៃតង ដែលវៀតណាមយល់ខុសថាសម្លៀកបំពាក់របស់យោធាខ្មែរក្រហម ។ ដោយសារតែមានភាសាផ្សេងគ្នា យើងពិបាកបញ្ចុះបញ្ចូលទ័ពវៀតណាមណាស់ ។ ប៉ុន្តែ បន្ទាប់ពីឃើញថា ប្ដីរបស់ខ្ញុំ គឺជាជនពិការ ទើបទ័ពវៀតណាមអនុញ្ញាតឲ្យយើងធ្វើដំណើរទៅមុខ ។

បន្ទាប់ពីទៅដល់ព្រៃស្វាយ និងផ្លូវជាតិលេខ៥ យើងបានសម្រេចចិត្តទៅក្រុងបាត់ដំបង ដែលមានទីតាំងប្រហែល៤៥គីឡូ

ម៉ែត្រ ។ នៅពេលដែលយើងមកដល់បាត់ដំបង យើងបានទៅស្នាក់នៅក្នុងអគារដែលបោះបង់ចោលដែលធ្លាប់ជាមន្ទីរព័ត៌មានខេត្ត ។

អំឡុងពេលដែលយើងស្នាក់នៅក្នុងអគារដែលបោះបង់ចោល ខ្ញុំបានជួបមិត្តចាស់ និងកូនកំព្រាពីរនាក់ដែលជាក្មេងជំទង់ប្រុស និងក្មេងជំទង់ស្រីឈ្មោះ លន់ និង ព្រីង ដែលឪពុកម្ដាយរបស់អ្នកទាំងពីរធ្លាប់រស់នៅក្បែរខ្ញុំនៅចាមរអា ។ ដោយសារ ប្ដីរបស់ខ្ញុំ និងខ្ញុំបានបាត់បង់កូនទាំងអស់ យើងសម្រេចចិត្តទទួលយកក្មេងកំព្រាទាំងពីរនាក់យកមកចិញ្ចឹម និងមើលថែ ។ នៅពេលនោះ វ៉េត និងប្រពន្ធរបស់គាត់ ដែលបានជួយយើងបររទេះគោពីចាមរអាទៅបាត់ដំបង បានសម្រេចចិត្តត្រឡប់ទៅភ្នំពេញដើម្បីស្វែងរកសាច់ញាតិដែលបានបាត់ខ្លួន ។ ដោយសារ យើងពិបាករក្សា និងមើលថែសត្វគោ យើងសម្រេចចិត្តឲ្យគោ និងរទេះទៅ វ៉េត និងប្រពន្ធរបស់គាត់ដើម្បីប្រើសម្រាប់ជាមធ្យោបាយធ្វើដំណើរទៅភ្នំពេញ ។

បន្ទាប់ពីស្នាក់នៅពីរបីសប្ដាហ៍នៅក្នុងផ្ទះដែលបោះបង់ចោល ទ័ពវៀតណាមមួយចំនួនបានមកដល់ ហើយឲ្យយើងចាកចេញពីកន្លែងនោះ ។ ទ័ពវៀតណាមទាំងនោះ បានបើកឡានមក និងបានប្រាប់យើងឲ្យឡើងជិះ ។ បន្ទាប់ពីនោះមក កងទ័ពវៀតណាមទាំងនោះ បានយកយើងទៅភូមិមួយនៅជិតភ្នំសំពៅ ហើយទម្លាក់យើងចោលនៅទីនោះ ។ ដោយគ្មានរទេះគោ និងមានមនុស្សពិការមកជាមួយយើងពិបាករកមធ្យោបាយក្នុងការផ្លាស់ទីលំនៅណាស់ ។ យើងបានស្វែងរកកន្លែងស្នាក់នៅបណ្ដោះអាសន្នក្រោមផ្ទះរបស់អ្នកភូមិ ហើយថង់អង្ករបស់យើងត្រូវបានលួចនៅយប់នោះ ។

ដោយភាពអស់សង្ឃឹម ខ្ញុំបានជួបមិត្តផ្សេងដែលបាននាំដំណឹងល្អមកខ្ញុំ ដោយបានប្រាប់ខ្ញុំថា ប្អូនប្រុសរបស់ខ្ញុំ ថុល នៅមានជីវិត ហើយថា គាត់ត្រូវបានតែងតាំងជាចៅហ្វាយស្រុកពពាលខែ ដោយអាជ្ញាធរថ្មី ។

ពពាលខែ មានទីតាំងនៅឆ្ងាយពីក្រុងខេត្តបាត់ដំបងដែរ ។ យើងមិនអាចដើរដោយថ្មើរជើងបានឡើយ ។ ដើម្បីទៅដល់ទីនោះ យើងត្រូវមានយ៉ាងហោចណាស់កង់សម្រាប់ធ្វើដំណើរដែរ ។ ដូច្នេះយើងបានយកខ្សែកមកដោះដូរជាមួយកង់ចាស់មួយពីអ្នកភូមិម្នាក់ រួចហើយខ្ញុំជិះកង់នោះទៅរកបងប្រុសរបស់ខ្ញុំនៅពពាលខែ ។ បន្ទាប់ពីយើងបានជួបជុំគ្នាឡើងវិញ បងប្រុសរបស់ខ្ញុំបានចាត់ចែងនាំយកយើងពីភ្នំសំពៅមករស់នៅជាមួយគាត់ ។

បន្ទាប់ពីយើងបានមកដល់ស្រុកពពាលខែបានមួយរយៈ ខ្ញុំបានទទួលដំណឹងថា កូនម្នាក់ក្នុងចំណោមកូនប្រុសរបស់ខ្ញុំ គឺ រិទ្ធា ដែលបានរត់គេចពីបងប្រុសរបស់ខ្លួន គន្ធា និងបងប្អូនជីដូនមួយ អំឡុងពេលដែលយើងបានមកដល់ចាមរអា បានប៉ុន្មានថ្ងៃនោះ គឺនៅមានជីវិតរស់នៅឡើយ ។ បច្ចុប្បន្ន កូនរបស់ខ្ញុំរស់នៅរការកោង ។ ភ្លាមនោះ បងប្រុសរបស់ខ្ញុំបានបញ្ជូនប្រពន្ធរបស់គាត់ដែលចេះនិយាយភាសាវៀតណាមដើម្បីធ្វើដំណើរទៅរការកោងដោយសុំជិះឡានទ័ពវៀតណាម ។ នៅពេលនោះ យើងបានដឹងថា អង្គការជួយសង្គ្រោះ និងមនុស្សធម៌អន្តរជាតិ បានបង្កើតជំរំតាមបណ្ដោយព្រំដែនកម្ពុជាថៃដើម្បីផ្ដល់អាហារ និងការព្យាបាលដល់ជនភៀសសឹកកម្ពុជា ។ នៅពេលដែលទទួលដំណឹងពីជំនួយផ្នែកពេទ្យតាមបណ្ដោយព្រំដែនកម្ពុជាថៃដែលមានទីតាំងប្រហែលជាង១០០គីឡូម៉ែត្រ ប្ដីរបស់ខ្ញុំ ដែលប្រេះឆ្អឹងត្រគាក រួចបានបណ្ដាលឲ្យពិការចង់ទៅព្យាបាលនៅទីនោះ ។ បន្ទាប់ពីពិភាក្សាយ៉ាងយូរ យើងបានសម្រេចចិត្តទៅព្យាបាលការប្រេះឆ្អឹងត្រគាកនោះ ។

ដោយសារខ្វះចំណីអាហារ និងថ្នាំដើម្បីជួយប្រជាជនដែលមិនមានអាហារហូបចុកគ្រប់គ្រាន់ឲ្យរស់រានមានជីវិត ទ័ពវៀតណាមមិនបានដាក់កំហិតដល់យើងមិនឲ្យចាកចេញនោះទេ ។ ដូច្នេះហើយប្ដីរបស់ខ្ញុំអាចធ្វើដំណើរទៅព្រំដែនដោយសុំជិះរទេះរបស់អ្នកដែលត្រូវទៅដឹកស្បៀងអាហារពីអង្គការជួយសង្គ្រោះអន្តរជាតិដែលបានបង្កើតជំរំតាមបណ្ដោយព្រំដែន ។

ដោយចង់ព្យាបាលជំងឺ ប្ដីរបស់ខ្ញុំបានទៅដល់ជំរំខាវអ៊ីដាងដែលមានទីតាំងនៅក្នុងប្រទេសថៃ ។ គាត់បានផ្ញើសំបុត្រមួយច្បាប់ឲ្យខ្ញុំដើម្បីហៅខ្ញុំឲ្យមកជាមួយគាត់នៅជំរំខាវអ៊ីដាងជាទីដែលប្រជាជនដែលបានមកដល់ជំរំនោះនឹងត្រូវបានអនុញ្ញាតឲ្យរស់នៅប្រទេសទីបី ។

បន្ទាប់ពីទទួលសំបុត្រនោះពីប្ដីរបស់ខ្ញុំ ម្ដាយខ្ញុំ និងកូនរបស់ខ្ញុំបានមកដល់ស្រុកពពាលខែ ។ ខ្ញុំបានប្រាប់ម្ដាយរបស់ខ្ញុំថា ប្ដីថ្មីរបស់ខ្ញុំបានរៀបការជាមួយខ្ញុំដើម្បីជួយសង្គ្រោះខ្ញុំពីជនកំណាច ឈ្មោះ ជាង ហើយខ្ញុំមិនមានកាតព្វកិច្ចណាចាំបាច់ត្រូវតែទទួលយកគាត់ជាស្វាមីឡើយ នៅពេលដែលយើងមានសេរីភាពពីរបបផ្ដាច់ការ

ខ្មែរក្រហម ។ បន្ទាប់ពីស្តាប់សាច់រឿងរបស់ខ្ញុំ ម្តាយរបស់ខ្ញុំបានទទូចថា ខ្ញុំគួរតែទទួលយក ស៊ីនួន ជាប្តីស្របច្បាប់ពីព្រោះ គាត់និងខ្ញុំបានឆ្លងកាត់ការឈឺចាប់ជាមួយគ្នាជាច្រើនដែលយើងគួរតែចាត់ទុកការរៀបការរបស់យើងក្រោមរបបខ្មែរក្រហមថាជាចំណងអពាហ៍ពិពាហ៍ដែលទេព្តាប្រទាន ។

មុនពេលដែលខ្ញុំ ចាកចេញទៅជំរំនៅតាមព្រំដែនដើម្បីជួបជុំជាមួយប្តីរបស់ខ្ញុំជាថ្មី កូនប្រុសរបស់ខ្ញុំបានសុំខ្ញុំធ្វើដំណើរទៅព្រំប្រទល់ជាមុនដើម្បីត្រួតពិនិត្យមើលថាតើស្ថានភាពឆ្លងកាត់ព្រំដែនទៅប្រទេសថៃមានការលំបាកយ៉ាងណា ។ បន្ទាប់ពីបែកគ្នាជាងបីឆ្នាំ ខ្ញុំមានការស្ទាក់ស្ទើរក្នុងការអនុញ្ញាតឲ្យគាត់ទៅ ។

នៅពេលដែលកូនប្រុសរបស់ខ្ញុំ ចាកចេញទៅជំរំ ខ្ញុំបានប្រាប់គាត់ឲ្យស្វែងរកមធ្យោបាយទាក់ទងជាមួយឪពុកចុងឈ្មោះ ស៊ីនួន នៅជំរំខាវអ៊ីដាង ដោយសារយើងនឹងជួបជុំជាមួយគាត់ឆាប់ៗ ។ ពេលវេលាបានកន្លងហួសយ៉ាងឆាប់ពេលដែលអ្នកកំពុងអន្ទះសាររង់ចាំព័ត៌មាន ឬការវិលត្រឡប់របស់អ្នកណាម្នាក់ពីការបំពេញបេសកកម្មគ្រោះថ្នាក់ ។ ដូច្នេះបន្ទាប់ពីកូនប្រុសរបស់ខ្ញុំបានចាកចេញអស់រយៈពេលពីរសប្តាហ៍ដោយមិនបានឮដំណឹងអ្វីទាល់តែសោះនោះ ខ្ញុំពិតជានៅមិនស្ងប់ ហើយបានសម្រេចចិត្តស្វែងរកកូនប្រុសរបស់ខ្ញុំ និងស្វាមី ។ មុនខ្ញុំចាកចេញ ខ្ញុំបានប្រាប់បងប្រុសរបស់ខ្ញុំថា ប្រសិនបើកូនរបស់ខ្ញុំវិលត្រឡប់មកពពាលខែ សូមប្រាប់គាត់ឲ្យត្រឡប់ទៅជំរំនៅព្រំដែន ហើយឲ្យព្យាយាមស្វែងរកផ្លូវទៅជំរំខាវអ៊ីដាងដោយសារយើងនឹងអាចជួបជុំគ្នាឡើងវិញនៅទីនោះ ។

ខ្ញុំធ្វើដំណើរទៅជំរំនៅព្រំដែនជាមួយហ្វូងមនុស្សផ្សេងទៀត ។ អ្នកទាំងនោះ គឺជាអ្នកជួញដូរអីវ៉ាន់ ។ អ្នកទាំងនោះ គឺអ្នកភូមិដែលទៅទីនោះដើម្បីទទួលស្បៀងពីអង្គការជំនួយអន្តរជាតិ ។ យើងភាគច្រើនទៅប្រមូលផ្តុំគ្នានៅភូបែឌឹម ។ នៅទីនោះ ខ្ញុំជួបជាមួយស្ត្រីម្នាក់ដែលធ្វើដំណើរឆ្ពោះទៅជំរំតាមព្រំដែននោះដែរ ។ ក្មេងស្រីជំទង់ម្នាក់នោះបានធ្វើដំណើរទៅទីនោះជាញឹកញយ ដូច្នេះហើយ ខ្ញុំបានស្នើសុំឲ្យគាត់ធ្វើជាអ្នកនាំផ្លូវ ពីព្រោះខ្ញុំធ្វើដំណើរទៅទីនោះជាលើកដំបូង ។ ក្មេងស្រីជំទង់ម្នាក់នោះ ក៏យល់ព្រមជួយខ្ញុំ ។

ដើម្បីគេចពីទ័ពវៀតណាម និងចោរប្លន់ ជាធម្មតាយើងធ្វើដំណើរទៅជំរំនៅតាមជនបទនៅពេលយប់ ។ យើងរង់ចាំរហូតដល់ទាល់តែព្រះអាទិត្យលិចមុនពេលដែលយើងត្រៀមខ្លួនចាកចេញទៅជំរំ ។ ស្ត្រីវ័យក្មេង ដែលជាអ្នកនាំផ្លូវ បានទាញដៃខ្ញុំដោយប្រាប់ឲ្យនៅជិតនាងដោយសារការជដែកគ្នានៅពេលធ្វើដំណើរត្រូវហាមឃាត់ ។ យើងទាំងអស់គ្នាត្រូវដើរដោយភាពស្ងៀមស្ងាត់ ។

ក្រោមផ្ទៃមេឃងងឹតនៅពេលយប់ យើងបានដើរកាត់វាលស្រែ បន្ទាប់មកចូលក្នុងព្រៃ ។ ខ្ញុំមិនបានដឹងថាតើចម្ងាយផ្លូវឆ្ងាយយ៉ាងណានោះឡើយ ប៉ុន្តែយើងចំណាយពេលពេញមួយយប់ដើម្បីធ្វើដំណើរទៅជំរំ ។ យើងបានទៅដល់ជំរំណងច័ន្ទនៅពេលព្រឹកព្រលឹម ។ ខ្ញុំរីករាយពេលដែលបានឃើញមនុស្សជាច្រើនរស់នៅក្នុងជំរំ ។ នៅពេលដែលខ្ញុំដើរជុំវិញជំរំនោះ ខ្ញុំបានប្រទះឃើញបងប្អូនជីដូនមួយ ឈ្មោះ ណាម ដែលគាត់រំភើបចិត្តយ៉ាងខ្លាំងនៅពេលជួបខ្ញុំ ។ បងប្អូនជីដូនមួយរបស់ខ្ញុំបានគិតថា ខ្ញុំត្រូវខ្មែរក្រហមសម្លាប់អស់ហើយ ។ ណាម បាននាំខ្ញុំទៅខ្ទមរបស់នាង ហើយបានដងទឹកឲ្យខ្ញុំផ្ញូត ។

អំឡុងពេលដែលខ្ញុំស្នាក់នៅណងច័ន្ទ ខ្ញុំបានជួបមិត្តភក្តិមួយចំនួនរួមមានញាតិសាច់ឆ្ងាយដែលបានមកជំរំនោះដែរ ។ ខ្ញុំបានជួបកូនចិញ្ចឹមឈ្មោះ លន ។ លន បានឆ្លងកាត់ព្រំដែនជួញដូរទំនិញទៅវិញទៅមក ។ លន មានបណ្តាញក្រុមជួញដូរដែលអ្នកទាំងនោះធ្វើការជាអ្នកជួញដូរឥវ៉ាន់ និងមនុស្ស ។ តាមរយៈបណ្តាញក្រុមជួញដូរទាំងនោះ ខ្ញុំបានដឹងថា កូនចិញ្ចឹមរបស់ខ្ញុំរស់នៅក្នុងជំរំថ្មីនៅជំរំព្រំដែន ។

ដំបូង ខ្ញុំចង់ទៅជំរំថ្មីដើម្បីជួបជុំជាមួយនឹងកូនប្រុសរបស់ខ្ញុំ ប៉ុន្តែនៅពេលទទួលដំណឹងថា ប្តីរបស់ខ្ញុំនៅជំរំខាវអ៊ីដាង លន បានស្នើជាយោបល់ថា ខ្ញុំគួរតែទៅជំរំខាវអ៊ីដាង ហើយរង់ចាំគេ ។ ដូច្នេះហើយ លន បានចាត់ចែងឲ្យខ្ញុំទៅជំរំខាវអ៊ីដាងជាមួយអ្នកជួញដូរបួននាក់ផ្សេងទៀត ។

ជាថ្មីម្តងទៀត យើងបានដើរនៅពេលយប់ដោយដើរសសៀរតាមភូមិរបស់ប្រជាជនថៃមួយចំនួនដើម្បីទៅដល់ជំរំខាវអ៊ីដាង ។ នៅវេលាម៉ោងប្រហែល៨ទៀបភ្លឺ យើងបានទៅដល់ជំរំខាវអ៊ីដាងជាទីដែលខ្ញុំបានជួបជុំជាមួយប្តី ។ ជាច្រើនថ្ងៃក្រោយមក កូនចិញ្ចឹមរបស់ខ្ញុំបានទៅដល់ជំរំខាវអ៊ីដាង ។ យើងបានចំណាយពេលជិតមួយឆ្នាំនៅខាវអ៊ីដាងមុនពេលដែលត្រូវទទួលយកទៅរស់នៅសហរដ្ឋអាមេរិក ។ **លីម គីមឡេង**

# ជីវិតខ្ញុំពីដើមរៀងមក

ខ្ញុំកើតនៅថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៣៦ នៅភូមិស្រែគ្រួ ស្រុកត្រាំកក់ ខេត្តតាកែវ ។ ពេលដែលខ្ញុំមានអាយុ៥ឆ្នាំ ឪពុកម្តាយរបស់ខ្ញុំបានបញ្ជូនខ្ញុំទៅរស់នៅក្នុងវត្តមួយ ដែលគេហៅថា "វត្តពោធិ៍អង្គ្រង" ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។ ខ្ញុំត្រូវចៅអធិការព្រះនាម រស់ មាស ជាអ្នកមើលថែ ។ បន្ទាប់ពីព្រះចៅអធិការ រស់ មាស សុគតទៅ ខ្ញុំត្រូវបានមើលថែដោយសម្តេច ជួន ណាត ដែលកាលនោះព្រះអង្គជាភិក្ខុ ។ កាលខ្ញុំអាយុ១០ឆ្នាំ ខ្ញុំបានបួសជាលោកនេន ។ ខ្ញុំនៅសាងផ្នួសជាព្រះសង្ឃអស់បួនវស្សា ។ ក្នុងអំឡុងពេលសាងផ្នួស ខ្ញុំសិក្សាបាលី និងកម្មវិធីថ្នាក់បឋមសិក្សា ។ ក្នុងឆ្នាំ១៩៤៩ ខ្ញុំរៀនចប់បឋមសិក្សា ហើយបន្តទៅរៀនថ្នាក់មធ្យមសិក្សា ។ ដូច្នេះហើយ ខ្ញុំបានលាចាកសិក្ខាបទ ហើយបានក្លាយជាគ្រហស្ថដើម្បីបន្តការសិក្សានៅភ្នំពេញ ។

ក្រោយមក ខ្ញុំទៅភ្នំពេញដើម្បីចូលរៀនថ្នាក់វិទ្យាល័យ ។ ក្នុងឆ្នាំ១៩៥៥ ខ្ញុំបានប្រឡងជាប់បាក់ឌុប ហើយត្រូវបានអនុញ្ញាតឲ្យចូលរៀនសកលវិទ្យាល័យវេជ្ជសាស្ត្រសុខាភិបាល ចាប់ពីឆ្នាំ១៩៥៦ ដល់ឆ្នាំ១៩៥៨ ពេលដែលខ្ញុំបានទទួលអាហារូបករណ៍ទៅសិក្សានៅប្រទេសបារាំង ។ ខ្ញុំទៅសិក្សានៅទីក្រុងម៉ាកសីប្រទេសបារាំងអស់រយៈពេល៣ឆ្នាំ មុនពេលដែលត្រឡប់មកប្រទេសកម្ពុជាក្នុងឆ្នាំ១៩៦១ ។

បន្ទាប់ពីបានចូលរៀននៅសាលាពេទ្យ ខ្ញុំបានជួបនិងរៀបការជាមួយប្រពន្ធរបស់ខ្ញុំក្នុងឆ្នាំ១៩៥៧ ។ ជាមួយគ្នានេះ យើងមានកូនប្រាំពីរនាក់ ក្នុងនោះពីរនាក់ក្នុងចំណោមកូនរបស់ខ្ញុំ (កូនប្រុសម្នាក់ និងកូនស្រីម្នាក់) បានស្លាប់អំឡុងរបបខ្មែរក្រហម ។

ពេលដែលខ្ញុំកំពុងសិក្សាផ្នែកវេជ្ជសាស្ត្រ មុខវិជ្ជាជំនាញរបស់ខ្ញុំគឺ វិទ្យុព្យាបាល ។ ដូច្នេះហើយ វេជ្ជបណ្ឌិតត្រូវការយកខ្ញុំមកធ្វើការជាមួយតាមមន្ទីរពេទ្យជាច្រើននៅក្នុងភ្នំពេញ ដែលត្រូវការជំនួយការប្រើឧបករណ៍ឆ្លុះកាំរស្មីអ៊ិចអ្នកជំងឺ ។ ដំបូងខ្ញុំទៅធ្វើការនៅមន្ទីរពេទ្យកាល់ម៉ែត បន្ទាប់មកមន្ទីរពេទ្យរុស្ស៊ី និងមន្ទីរពេទ្យជាច្រើននៅភ្នំពេញ ។


សុខ យ៉ាវ

បន្ទាប់ពីសេនាប្រមុខ លន់ នល់ បានធ្វើរដ្ឋប្រហារនៅខែមីនា ឆ្នាំ១៩៧០ ដើម្បីទម្លាក់សម្តេច សីហនុ ចេញពីអំណាច ខ្ញុំបានសម្រេចចិត្តចូលរួមចលនាកុម្មុយនីស្តតាមការអំពាវនាវរបស់សម្តេច សីហនុ ដើម្បីតស៊ូប្រឆាំងនឹងរបប លន់ នល់ ។ ខ្ញុំបានចាកចេញពីភ្នំពេញ

ចុងឆ្នាំ១៩៧០ ហើយបានទៅចូលរួមចលនាបដិវត្តន៍ក្នុងខេត្តតាកែវ ដែលជាស្រុកកំណើតរបស់ខ្ញុំដែលក្រោយមក ចលនានោះត្រូវបានស្គាល់ថាជាខ្មែរក្រហម ។ បន្ទាប់ពីខ្ញុំបានទៅដល់ខេត្តតាកែវ ខ្ញុំបានបញ្ជូនប្រពន្ធ និងកូនទៅស្នាក់នៅជាមួយឪពុកម្ដាយរបស់ខ្ញុំនៅក្នុងភូមិតាភេម ស្រុកត្រាំកក់ ។

ក្នុងនាមជាអ្នកចំណូលថ្មីដំបូង អង្គការបានបញ្ជូនខ្ញុំទៅទទួលការបណ្ដុះបណ្ដាលនៅភ្នំដំរីរមៀល ជាទីដែលខ្ញុំបានជួបជាមួយកម្មាភិបាលខ្មែរក្រហមសំខាន់ៗមួយចំនួន ដូចជា វេជ្ជបណ្ឌិត ជួន ជឿន, ហ៊ូ នឹម និង ហ៊ូ យន់ ។ បន្ទាប់ពីខ្ញុំមកដល់ វេជ្ជបណ្ឌិត ជួន ជឿន បានផ្លាស់ទៅភូមិភាគឧត្ដរនៃប្រទេសកម្ពុជា ។ ខ្ញុំត្រូវបានឲ្យទៅធ្វើការនៅភូមិភាគនិរតី ។ បុរសដែលទទួលខុសត្រូវនៅតំបន់នោះ មានឈ្មោះថា តានឹម ដែលជាឈ្មោះប្រើក្នុងជួរកងទ័ព ។

មុនពេលខ្ញុំចាប់ផ្ដើមធ្វើការនៅភូមិក្បាលអូរ តានឹម បានឲ្យសំបុត្រមួយច្បាប់មកខ្ញុំដើម្បីឲ្យខ្ញុំយកទៅជួប តាម៉ុក ។ តាម៉ុក ដែលជាអ្នកមានដើមកំណើតនៅខេត្តតាកែវ ទទួលខុសត្រូវភូមិភាគនិរតីទាំងមូល ដែលហ៊ុមព័ទ្ធខេត្តជាច្រើន ។ គាត់បានស្វាគមន៍ខ្ញុំឲ្យចូលក្នុងចលនាកុម្មុយនីស្ត ។ ខ្ញុំបានចំណាយពេលជាច្រើនរៀនសូត្រពីតាម៉ុក ចំពោះអ្វីដែលខ្ញុំចាំបាច់ធ្វើដើម្បីបម្រើចលនាខ្មែរក្រហម ។ ទំនាក់ទំនងរវាងខ្ញុំជាមួយនឹង តាម៉ុក និងក្រុមគ្រួសាររបស់គាត់មានលក្ខណៈជិតស្និទ្ធ ដោយសារគាត់បានជួយជីវិតរបស់ខ្ញុំនៅពេលដែលខ្ញុំត្រូវបានចាប់ខ្លួន ហើយត្រូវបានខ្មែរក្រហមដាក់គុកនៅដើមឆ្នាំ១៩៧៥ ។

បន្ទាប់ពីទទួលបានការសន្ដោសប្រណីពី តាម៉ុក ខ្ញុំត្រូវបានចាត់តាំងឲ្យធ្វើការនៅមូលដ្ឋានខ្មែរក្រហមក្នុងស្រុកឈូក ។ អំឡុងពេលនោះ ខ្ញុំកម្រស្នាក់នៅមូលដ្ឋានណាស់ ។ ដោយសារតែមានការប្រយុទ្ធគ្នាធ្ងន់ធ្ងរ ខ្ញុំត្រូវទៅសមរភូមិមុខដើម្បីព្យាបាលអ្នកប្រយុទ្ធដែលរងរបួស ។

មានថ្ងៃមួយនោះ អំឡុងពេលដែលខ្ញុំធ្វើដំណើរទៅសមរភូមិមុខម្ដងនោះជាមួយនារីពេទ្យបួននាក់ ខ្ញុំស្ទើរតែបាត់បង់ជីវិតដោយសារតែគ្រាប់ផ្លោងរបស់ទាហាន លន់ នល់ ។ ខណៈពេលដែលយើងហៀបនឹងទៅដល់សមរភូមិមុខ ខ្ញុំឈឺបត់ជើងតូច ខ្ញុំបានប្រាប់នារីពេទ្យទាំងបួននាក់ឲ្យដើរទៅមុខ ពេលដែលខ្ញុំឈប់បត់ជើងតូចនៅឯគុម្ពោតព្រៃ ។ មួយសន្ទុះក្រោយមក ខ្ញុំឮសម្លេងផ្ទុះយ៉ាងខ្លាំង ។ បន្ទាប់ពីធូលីដីបក់ផាត់អស់ ខ្ញុំបានឃើញថា នារីពេទ្យទាំងបួននាក់បានស្លាប់អស់ ។ គ្រាប់ផ្លោងបានធ្លាក់ក្បែរនោះរួចនារីពេទ្យទាំងនោះក៏ត្រូវចំណាំងគ្រាប់ជះត្រូវសុះសាច់ទាំងអស់ ។

ខ្ញុំមានការរន្ធត់ពន់ពេក ។ ខ្ញុំសម្រេចចិត្តទៅដើររើសកម្ទេចសាច់ ហើយដាក់ក្នុងអង្រឹង ដោយសារខ្ញុំមិនដឹងធ្វើអ្វីផ្សេងទាល់តែសោះ ។ ខ្ញុំបានរើសកម្ទេចសាច់ជាច្រើនដែលខ្ញុំអាចស្ពាយបានដាក់លើខ្នង ដូច្នេះហើយ ខ្ញុំអាចបញ្ចុះសពឲ្យនារីពេទ្យដ៏អភ័ព្វទាំងបួននាក់នោះ នៅពេលដែលខ្ញុំបានត្រឡប់ទៅស្រែអណ្ដូងវិញ ។

បន្ទាប់ពីការជួបប្រទះការវាយប្រហារដោយគ្រាប់ផ្លោង ខ្ញុំត្រូវបានចាត់តាំងឲ្យទៅធ្វើការនៅមន្ទីរពេទ្យភូមិភាគនិរតី ។ នៅមន្ទីរពេទ្យ ខ្ញុំបានជួបជាមួយវេជ្ជបណ្ឌិតជាន់ខ្ពស់ខ្មែរក្រហមមួយចំនួន ដែលបានបណ្ដុះបណ្ដាលដោយវៀតណាមខាងជើង ។ ក្រោយមក វេជ្ជបណ្ឌិតទាំងនោះត្រូវបានសម្លាប់ អំឡុងពេលដែលការប្រយុទ្ធបានចុះថមថយបានប៉ុន្មានថ្ងៃ ។ ពេលនោះហើយដែលខ្ញុំត្រូវបានចាប់ខ្លួន ហើយត្រូវបានបញ្ជូនទៅគុកក្រាំងតាចាន់ ។

ខ្ញុំបានជាប់គុកក្រាំងតាចាន់ចាប់តាំងពីថ្ងៃទី២៣ ខែមីនា ដល់ថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៧៥ ។ ហេតុផលសម្រាប់ការចាប់ខ្លួននៅតែជាអាថ៌កំបាំងរហូត ។ ខ្ញុំមានអារម្មណ៍ថា គឺថាដោយសារការចូលរួមជាមួយនឹងចលនារបស់ខ្មែរក្រហមបន្ទាប់ពីមានការអំពាវនាវពីសម្ដេចសីហនុ ។ ដូច្នេះហើយ ខ្ញុំត្រូវបានមើលឃើញថាជាអ្នកដែលគាំទ្រសម្ដេច សីហនុ ដែលនឹងត្រូវសម្លាប់ជាមួយអ្នកដែលទទួលបានការបណ្ដុះបណ្ដាលពីវៀតណាមខាងជើង ។

អ្នកជាប់គុកជាច្រើននៅគុកក្រាំងតាចាន់ គឺជាអ្នកមានឋានន្តរស័ក្តិក្នុងជួរខ្មែរក្រហម ឬប្រវត្តិជាខ្មែរក្រហម ឬជាសមាជិករបស់គ្រួសារអ្នកទាំងនោះ ។ បើតាមខ្ញុំដឹង គ្មាននរណាម្នាក់ រស់រានមានជីវិតនោះឡើយ លើកលែងតែខ្ញុំ និងស្រីក្មេងមួយរូបមានឈ្មោះថា កែវ សំអាត ដែលស្នាក់នៅក្នុងគុកក្បែរខ្ញុំ ។ ការរស់រានមានជីវិតរបស់យើង គឺកើតឡើងដោយសារតែមានទំនាក់ទំនងជាមួយនឹង តាម៉ុក ។

ពីរបីសប្ដាហ៍បន្ទាប់ពីខ្ញុំត្រូវបានចាប់ខ្លួន ហើយបានដាក់គុក យោធាខ្មែរក្រហមបានគ្រប់គ្រងទីរួមខេត្តកំពង់ស្ពឺ ។ យោធា

ខ្មែរក្រហមទាំងនោះ បានរកឃើញម៉ាស៊ីនថតដោយវិទ្យុ ហើយក៏បាននាំយកទៅឲ្យ តាម៉ុក ។ តាម៉ុក បានដឹងថា ខ្ញុំគឺជាអ្នកបច្ចេកទេសខាងវិទ្យុ ។ ដូច្នេះហើយ គាត់ក៏ឲ្យខ្ញុំស្វែងរកម៉ាស៊ីននោះ ហើយមើលថាតើម៉ាស៊ីននោះនៅដំណើរការឬយ៉ាងណា ។ ពេលដែលគាត់មកដល់កន្លែងដែលខ្ញុំធ្លាប់ធ្វើការ ទើប តាម៉ុក បានដឹងថាខ្ញុំត្រូវបានបញ្ជូនទៅគុកក្រាំងតាចាន់ ។ ភ្លាមៗនោះ គាត់បានទៅគុកនោះដើម្បីមើលថាតើខ្ញុំនៅរស់ឬយ៉ាងណា ។ ខ្ញុំនៅតែចងចាំយ៉ាងច្បាស់ នូវការសន្ទនារវាង តាម៉ុក និងមេគុកឈ្មោះ អាចារ្យ ចិន ។

តាម៉ុក ៖ «អាចារ្យ ចិន! ហ្អែងចម្អិន (សម្លាប់) ពេទ្យ យ៉ាវ ហើយនៅ?»

ចិន ៖ «មិនទាន់ទេបង» ។

តាម៉ុក ៖ «ឲ្យបាយស៊ីឲ្យគ្រប់គ្រាន់ផង ។ បន្តិចទៀត អញត្រឡប់មកយកវា» ។

ចិន ៖ «បាទបង» ។

ខ្ញុំមិនបានស្គាល់សំឡេងរបស់ តាម៉ុក ទេ ។ ដូច្នេះហើយ បន្ទាប់ពីបានឮការសន្ទនានោះ ខ្ញុំភិតភ័យយ៉ាងខ្លាំង ។ ខ្ញុំគិតថាជីវិតរបស់ខ្ញុំនឹងចប់នៅពេលនេះ ។

ថ្ងៃបន្ទាប់ ខ្ញុំត្រូវបាននាំចេញពីគុក ហើយត្រូវបានផ្តល់អាហារឆ្ងាញ់សម្រាប់ហូប ប៉ុន្តែទោះបីជាខ្ញុំខំប្រឹងហូបយ៉ាងណា ខ្ញុំមិនអាចហូបអាហារទាំងនោះបានទេ ។ ខ្ញុំស្ទួតបំពង់ករដោយសារការភ័យខ្លាចបានធ្វើឲ្យបាត់បង់ចំណង់បរិភោគ ។ ថ្វីបើមានការស្រេកឃ្លានខ្លាំងនោះ ខ្ញុំមិនអាចហូបចំណីអាហារដែលនៅចំពោះមុខបានឡើយ ។ អ្នកធ្វើការនៅក្នុងគុកដែលយកចំណីអាហារមកឲ្យខ្ញុំនោះ បាននិយាយដោយធានាថា ខ្ញុំនឹងមិនមានរឿងអ្វីកើតឡើងនោះឡើយ ។

មិនយូរប៉ុន្មាន តាម៉ុក បានមកដល់ ហើយបានបញ្ជាខ្ញុំឲ្យមកជាមួយគាត់ ។ ខ្ញុំបានស្នើសុំឲ្យ តាម៉ុក ជួយដោះលែងស្ត្រីក្មេងឈ្មោះ កែវ សំអាត មុនពេលដែលយើងទៅផ្ទះរបស់គាត់ជាមួយគាត់ ។ បន្ទាប់ពីនោះមក ខ្ញុំត្រូវបានបញ្ជូនឲ្យទៅធ្វើការក្នុងឃុំដូចប្រជាជនកម្ពុជាធម្មតាដទៃទៀតដែរ ។ ភារកិច្ចរបស់ខ្ញុំគឺត្រូវបើកឡានដឹកទំនិញ ឬបើកនាវា ។

អំឡុងពេលនៃការជាប់គុក២៧ថ្ងៃ នៅគុកក្រាំងតាចាន់ ខ្ញុំបានឃើញការធ្វើទារុណកម្មអ្នកទោសយ៉ាងសាហាវចំនួនពីរដងរបស់កម្មាភិបាលខ្មែរក្រហមដែលបានគ្រប់គ្រងទីនោះ ។ ម្តងនោះ ខ្ញុំបានឃើញអ្នកទោសស្ត្រីបីនាក់ពីស្រែអំពិល ខេត្តកំពត យកមកសួរចម្លើយ ។ ឆ្មាំគុកបានបញ្ជាឲ្យអ្នកទោសមួយចំនួន រួមទាំងរូបខ្ញុំផងឲ្យអង្គុយ និងមើលការធ្វើទណ្ឌកម្ម ។ ដំបូង ឆ្មាំគុកទាំងនោះបានដោះខោអាវអ្នកទោសស្ត្រីទាំងបីនាក់នោះ ហើយបានប្រើដង្កាប់មួលសាច់ ។ រឿងដែលសាហាវបំផុតនៅពេលនោះ គឺនៅពេលដែលឆ្មាំគុក បានប្រើដង្កាប់មួលមុខរបស់ជនរងគ្រោះ ហើយបញ្ជាមិនឲ្យអ្នកទោសនោះយំឡើយ ។ យើងអាចមើលឃើញស្នាមរបួសច្បាស់នៅលើខ្លួនរបស់អ្នកទោសទាំងនោះ ដែលឆ្មាំគុកមួលនឹងដង្កាប់ ដែលបណ្តាលឲ្យដាច់សាច់ហូរឈាម ។ ការឈឺចាប់ពិតជាមានកម្រិតធ្ងន់ធ្ងរណាស់ ។ ជនរងគ្រោះទាំងបីនាក់បានដេករមូលលើដីដោយក្តីឈឺចាប់ ។

បន្ទាប់ពីជនរងគ្រោះត្រូវមួលសាច់រួចហើយ ឆ្មាំគុកបានអូសជនរងគ្រោះទៅបង្គោលក្បែរនោះ ដែលប្រើសម្រាប់ចងព្យួរ ។ បង្គោលនីមួយៗមានទំពក់ធ្វើពីដែក ។ ឆ្មាំគុកទាំងនោះបានលើកអ្នកទោស ទាំងបីនាក់ឡើង ហើយព្យួរជាប់ទៅនឹងថ្គាល់ ។ បន្ទាប់មកឆ្មាំគុកម្នាក់បានប្រើកាំបិតមុតវះពោះជនរងគ្រោះ ។ ឆ្មាំគុកនោះបានកាត់យកថ្លើមរបស់ជនរងគ្រោះ ហើយទាញចេញមកក្រៅ ។ យើងត្រូវអង្គុយនៅទីនោះ ហើយមើលអ្នកទោសទាំងបីនាក់ពេញមួយយប់រហូតដល់ព្រឹកបន្ទាប់ រហូតអស់ជីវិត ទើបឆ្មាំគុកម្នាក់បានមកបញ្ជាយើងឲ្យត្រឡប់ទៅគុកវិញ ។

មានម្តងនោះ ខ្ញុំបានឃើញអ្នកទោសជាស្ត្រីដែលទើបតែសម្រាលកូនរួច ទទួលទណ្ឌកម្មយ៉ាងខ្លាំង ។ ឆ្មាំគុកបានប្រាប់អ្នកទោសជាស្ត្រីរូបនោះឲ្យទៅអង្គុយក្រោមម្លប់ឈើដែលមានអណ្តូងទឹកតូចមួយក្បែរនោះ ។ ក្រៅពីកូនដែលទើបតែកើត ស្ត្រីរូបនោះមានកូនអាយុពីរឆ្នាំនៅជាមួយនឹងខ្លួន ។ ភ្លាមៗបន្ទាប់ពីស្ត្រីនោះនិងកូនរបស់ខ្លួនអង្គុយក្រោមដើមឈើ ឆ្មាំគុកម្នាក់ក៏បានមក ។ ឆ្មាំគុករូបនោះ បានយកកូនដែលទើបកើតថ្មីចេញពីដៃរបស់ស្ត្រីម្នាក់នោះ រួចហើយបោកទារកនោះនឹងគល់ឈើ ហើយគ្រវែងចូលក្នុងអណ្តូង ។ បន្ទាប់មក ឆ្មាំគុកនោះបានចាប់យកក្មេងធំម្តង រួចបោកក្បាលរបស់ក្មេងនោះទៅនឹងគល់ឈើ ហើយចោលសាកសព

ចូលក្នុងអណ្តូងម្តងទៀត ។ នៅពេលដែលឃើញកូនរបស់ខ្លួនត្រូវបានសម្លាប់ដោយឃោរឃៅ ស្ត្រីជាម្តាយ បានដួលសន្លប់នៅនឹងកន្លែង ។ ស្ត្រីជាម្តាយត្រូវបានរុញចូលក្នុងអណ្តូង ហើយត្រូវបានកប់ទាំងរស់ជាមួយ នឹងកូនរបស់ខ្លួន ។

នៅចន្លោះឆ្នាំ១៩៧៥-១៩៧៩ ខ្ញុំបានចំណាយពេលជាច្រើនធ្វើការដោយកម្លាំង ។ នៅពេលដែលខ្ញុំត្រូវបានបញ្ជាឲ្យបើកត្រាក់ទ័រកាយដី ខ្ញុំបានប្រាប់កម្មាភិបាលនោះថា ខ្ញុំមិនដែលត្រូវបានបណ្តុះបណ្តាលឲ្យធ្វើការជាមួយម៉ាស៊ីនប្រភេទនោះទេតាំងពីមុន ដូច្នេះហើយខ្ញុំមិនដឹងពីរបៀបប្រើទេ ។ ប៉ុន្តែកម្មាភិបាលបានទទូចថាខ្ញុំត្រូវតែធ្វើ ។ ដូច្នេះហើយ ខ្ញុំបានសាកល្បង ហើយនៅពេលកំពុងបើកបរនោះ ខ្ញុំបានបង្កឧប្បត្តិហេតុជាច្រើនដែលបណ្តាលឲ្យបាត់បង់ជីវិតមនុស្សជាច្រើន ។ ក្នុងនោះមានឧប្បត្តិហេតុមួយដែលបន្តញាំញីខ្ញុំរហូតដល់សព្វថ្ងៃ ។ ពេលនោះខ្ញុំព្យាយាមយកប្រដាប់ដោះសោររបស់ត្រាក់ទ័រចូកដីដើម្បីគាស់ធ្នឹមដែកនៅក្រោមម៉ាស៊ីនកិនស្រូវ ។ ខ្ញុំចុចបញ្ជាខុសហើយបានយោលទៅម្ខាងរួចក៏បុកជញ្ជាំងក្បែរនោះដោយបង្កឲ្យមានការរលំលើមនុស្សជាច្រើនដែលអង្គុយ និងឈរនៅក្បែរនោះ ។ ខ្ញុំដឹងថាមនុស្សមួយចំនួនបានស្លាប់នៅក្នុងឧប្បត្តិហេតុនោះខណៈដែលមនុស្សមួយចំនួនទៀតរងរបួសយ៉ាងធ្ងន់ធ្ងរ ។ បទពិសោធអាក្រក់របស់ខ្ញុំជាមួយនឹងត្រាក់ទ័រចូកដីនោះ មិនបានបញ្ចប់ដោយសារឧប្បត្តិហេតុធ្ងន់ធ្ងរនោះទេ ។ ខ្ញុំត្រូវបានបញ្ជាឲ្យបន្តរៀនសូត្រ បើកត្រាក់ទ័រនោះទៀត ថ្វីបើខ្ញុំខ្វះសមត្ថភាពក៏ដោយ ។ ខ្ញុំមិនចងចាំថា ខ្ញុំជួបគ្រោះថ្នាក់ប៉ុន្មានដងទេ ដែលខ្ញុំព្យាយាមបើកត្រាក់ទ័រនោះ ប៉ុន្តែខ្ញុំដឹងថាយ៉ាងហោចណាស់មនុស្ស៤នាក់បានស្លាប់ដោយសារកំហុសរបស់ខ្ញុំក្នុងការព្យាយាមប្រើម៉ាស៊ីននោះឲ្យដំណើរការ ។ ខ្ញុំចង់ឈប់ធ្វើការងារជាមួយនឹងត្រាក់ទ័រនោះ ប៉ុន្តែកម្មាភិបាលខ្មែរក្រហមដែលទទួលបន្ទុកនោះ បានទទូចថា ខ្ញុំត្រូវបន្តរៀនសូត្របើកបរត្រាក់ទ័រនោះរហូតដល់ខ្ញុំចេះពីរបៀបប្រើបើពុំដូច្នោះទេកម្មាភិបាលខ្មែរក្រហមនោះនឹងសម្លាប់ខ្ញុំចោល ។

ថ្ងៃរំដោះបានមកដល់នៅពេលដែលទ័ពវៀតណាមបានវាយចូលក្នុងប្រទេសកម្ពុជានៅដើមខែមករា ឆ្នាំ១៩៧៩ ។ នៅព្រឹកនោះ ខ្ញុំត្រូវបានចាត់តាំងឲ្យមកមន្ទីរភ័ស្តុភាររបស់ខ្មែរក្រហមនៅទីប្រជុំជនខេត្តតាកែវ ដើម្បីជួយកំណត់អត្តសញ្ញាណប្រភេទឧបករណ៍ពេទ្យ និងមុខងាររបស់ឧបករណ៍ទាំងនោះនៅក្នុងប្រអប់ដែលទុកក្នុងឃ្លាំង ។ ខ្ញុំមានអារម្មណ៍តក់ស្លុត និងភ័យខ្លាចយ៉ាងខ្លាំងដោយសារពេលនោះខ្ញុំត្រូវតែប្រាប់កម្មាភិបាលខ្មែរក្រហមអំពីឧបករណ៍ក្នុងប្រអប់នោះ ។ ខ្ញុំនឹកគិតថា ពេលនោះអត្តសញ្ញាណរបស់ខ្ញុំនឹងត្រូវបានលាតត្រដាងមិនខានឡើយ ។ ប្រអប់ទាំងអស់ត្រូវបានបោះពុម្ពជាភាសាបារាំង និងអង់គ្លេស ។ ពិតណាស់ បើខ្មែរក្រហមដឹងថាខ្ញុំអាចអានភាសាទាំងនោះបាន នឹងធ្វើឲ្យខ្ញុំក្លាយជាមនុស្សគោលដៅសម្រាប់ធ្វើបាបមិនខាន ។ ទោះបីជាយ៉ាងនេះក៏ដោយ ខ្ញុំយល់ថាមិនមានចំណុចណាមួយសម្រាប់ខ្ញុំក្នុងការលាក់កំបាំងអត្តសញ្ញាណរបស់ខ្លួនឡើយ ព្រោះអ្នកដែលហៅខ្ញុំមកសុទ្ធតែស្គាល់ខ្ញុំច្បាស់ ។

ចំពេលដែលខ្ញុំកំពុងជួយកម្មាភិបាលខ្មែរក្រហមមើលអំពីប្រភេទផលិតផលផ្នែកវេជ្ជសាស្ត្រនៅក្នុងប្រអប់នីមួយៗ យើងបានឮសំឡេងផ្ទុះជាច្រើន និងសំឡេងយន្តហោះហោះលើក្បាលរបស់យើង ។ ភ្លាមនោះ ការប្រកាសអាសន្នក៏បានធ្វើឡើង ហើយមនុស្សគ្រប់គ្នាបានរត់ប្រសាចគ្រប់ទិសដៅទាំងអស់ ។ ក្នុងសភាពជ្រួលច្របល់នោះ ខ្ញុំបានធ្វើដំណើរត្រឡប់ទៅឃុំដែលប្រពន្ធរបស់ខ្ញុំ និងកូនរស់នៅ ។

ពេលធ្វើដំណើរត្រឡប់ទៅភូមិតាភេមដើម្បីស្វែងរកគ្រួសាររបស់ខ្ញុំ ខ្ញុំបានជួបមិត្តភក្តិចាស់ ឈ្មោះប៉ាក ថូរីន ។ គាត់បានធ្វើការឲ្យកងកម្លាំងរំដោះដែលបានបណ្តេញខ្មែរក្រហមចេញពីអំណាច ។ ថូរីន បានឲ្យត្រាក់ឃោសនាមកខ្ញុំជាច្រើនហើយប្រាប់ខ្ញុំមិនឲ្យដើរតាមខ្មែរក្រហមដែលកំពុងរត់ចូលព្រៃឡើយ ។ បន្ទាប់ពីយើងបែកគ្នា ខ្ញុំបានទៅជួបជុំជាមួយគ្រួសាររបស់ខ្ញុំនៅភូមិតាភេម និងរស់នៅទីនោះតែម្តង ។

ពីរបីខែក្រោយមក ប៉ាក ថូរីន បានមកលេងនឹងខ្ញុំ ។ ពេលគាត់មកលេងនោះ ខ្ញុំត្រូវបានតែងតាំងជាក្រុមប្រឹក្សាឃុំជាមួយនឹងអ្នកភូមិបួននាក់ផ្សេងទៀត ។ បន្ទាប់ពីនោះមក ខ្ញុំត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សាស្រុកត្រាំកក់ទទួលបន្ទុកកិច្ចការសាសនា ។

អំឡុងពេលដែលខ្ញុំកាន់មុខតំណែងជាសមាជិកក្រុមប្រឹក្សាស្រុកត្រាំកក់ ទទួលបន្ទុកកិច្ចការសាសនា ខ្ញុំបានជួបប្រទះបញ្ហាជា

ច្រើនជាមួយអាជ្ញាធរថ្នាក់លើ ។ កំហុសរបស់ខ្ញុំគឺការបំបួសព្រះសង្ឃ ដោយមិនបានសុំការអនុញ្ញាតជាមុនពីក្រសួងធម្មការ និងសាសនា ។ បុរសដែលទទួលបន្ទុកនៅក្រសួងធម្មការ និងសាសនានោះគឺលោក ម៉ាត់ លី បានគំរាមកំហែងបញ្ជូនខ្ញុំទៅគុកដោយសារខ្ញុំមិនបានសុំការអនុញ្ញាតជាមុន ។ ចំពេលដែលខ្ញុំកំពុងជជែកការពារបញ្ហានោះ លោក ប៉ែន សុវណ្ណ ដែលកាលនោះគឺជានាយករដ្ឋមន្ត្រីបានមកដល់ និងសួរថាតើមានអ្វីកើតឡើង ។ បន្ទាប់ពីបានដឹងពីបទល្មើសរបស់ខ្ញុំ លោក ប៉ែន សុវណ្ណ បានធ្វើអន្តរាគមន៍លើបញ្ហានោះ ។

បន្ទាប់ពីបានធ្វើការជាសមាជិកក្រុមប្រឹក្សាអស់មួយរយៈ ខ្ញុំត្រូវបានឲ្យទៅធ្វើការនៅមន្ទីរពេទ្យ ក្នុងទីប្រជុំជនខេត្តតាកែវជាអ្នកបកប្រែឲ្យវេជ្ជបណ្ឌិតជនជាតិស៊ីស ឈ្មោះថា ស្រាក់ ភីព័រ ។ ដំបូង ខ្ញុំបានព្យាយាមលាក់កំបាំងប្រវត្តិរូបផ្នែកពេទ្យរបស់ខ្ញុំដោយធ្វើពុតថាខ្ញុំចេះតែភាសាបារាំងតែប៉ុណ្ណោះ ប៉ុន្តែ ខ្ញុំមិនអាចលាក់កំបាំងប្រវត្តិរូបផ្នែកពេទ្យរបស់ខ្ញុំបានឡើយ ។ មិនយូរប៉ុន្មាន ស្រាក់ បានស្វែងយល់ឃើញថាខ្ញុំគឺជាគ្រូពេទ្យ ដូច្នេះហើយខ្ញុំក៏ក្លាយជាអ្នកបកប្រែ និងជាអ្នកធ្វើការងារជាមួយគាត់រហូតមក ។

ពេលដែល ស្រាក់ និងសហសេវិករបស់គាត់បានមកដល់ខេត្តតាកែវដើម្បីធ្វើការងារស្ម័គ្រចិត្តនៅមន្ទីរពេទ្យខេត្ត អាជ្ញាធរបានរៀបចំការសម្តែងរបាំបុរាណខ្មែរដើម្បីស្វាគមន៍ភ្ញៀវបរទេសទាំងនោះ ។ បន្ទាប់ពីមើលការសម្តែងនោះ ស្រាក់ បានជាប់ចិត្តស្រលាញ់នារីរបាំម្នាក់ឈ្មោះ ចេក ។ នៅពេលដែលគាត់ស្គាល់ខ្ញុំកាន់តែច្បាស់ ស្រាក់ បានស្នើឲ្យខ្ញុំធ្វើជាមេអណ្តើក ហើយជួយផ្សំផ្គុំគាត់ឲ្យបានរៀបការជាមួយ ចេក ។ កាលនោះ សម្រាប់ជនបរទេសរៀបការផ្លូវការជាមួយនារីកម្ពុជាគឺជារឿងលំបាកមួយ ដោយសារយើងកំពុងរស់នៅក្រោមរបបកុម្មុយនីស្ត ហើយមិនមានបញ្ញត្តិណាមួយនៅក្នុងច្បាប់ដែលអនុញ្ញាតឲ្យមានការរៀបការរវាងប្រជាជនកម្ពុជា និងបរទេស ជាពិសេសអ្នកដែលមកពីប្រទេសសេរីដូចជាអឺរ៉ុបខាងលិច ឬអាមេរិកឡើយ ។

ដើម្បីជួយសម្របសម្រួលការរៀបការរវាងស្រាក់ និង ចេក ដំបូងខ្ញុំទៅជួប ចេក និង គ្រួសាររបស់គាត់ដើម្បីប្រាប់ពីចេតនារបស់ ស្រាក់ ។ បន្ទាប់មក ឪពុកម្តាយរបស់គាត់ក៏យល់ព្រម ហើយខ្ញុំក៏ទៅជួបអាជ្ញាធរខេត្តដើម្បីស្នើសុំការអនុញ្ញាតឲ្យ ស្រាក់ ដើម្បីរៀបការជាមួយនារីកម្ពុជាម្នាក់នេះ ។ អាជ្ញាធរខេត្តបានប្រាប់ខ្ញុំថាមិនមានច្បាប់នៅក្នុងសៀវភៅដែលអនុញ្ញាតឲ្យមានការរៀបការរវាងប្រជាជនកម្ពុជា និងជនបរទេសទេ ។ ទោះបីជាយ៉ាងនេះក៏ដោយ ប្រសិនបើអ្នកទាំងពីរនោះ ស្រលាញ់គ្នាទៅវិញទៅមក យើងអនុញ្ញាតឲ្យរៀបការស្ងាត់ៗ ។

បន្ទាប់ពីទទួលបានការយល់ព្រមពីអាជ្ញាធរខេត្ត ស្រាក់ និង ចេក បានរៀបការដោយមិនមានលក្ខណៈផ្លូវការឡើយ ។ ដោយសារ ស្រាក់ មិនអាចនិយាយភាសាខ្មែរ ហើយប្រពន្ធរបស់គាត់មិនអាចនិយាយភាសាបារាំង ខ្ញុំបានក្លាយជាអ្នកបកប្រែសម្រាប់អ្នកទាំងពីរ ។ ខ្ញុំរីករាយខ្លាំងណាស់ អំឡុងពេលដែលធ្វើការជាអ្នកបកប្រែរយៈពេលប៉ុន្មានខែសម្រាប់អ្នកទាំងពីរ ។ ខ្ញុំនិយាយលេងសើចជាច្រើនទាក់ទងនឹងអ្នកទាំងពីរដោយបានប្រែពាក្យពេចន៍ធម្មតាឲ្យទៅជាពាក្យពេចន៍ស្នេហា ។ ឧទាហរណ៍ នៅពេលដែល ចេក ត្រឡប់ពីរាំរបាំ ហើយបានមកមន្ទីរពេទ្យដើម្បីជួបជាមួយ ស្រាក់ ដើម្បីដើរទៅផ្ទះ ជាមួយគ្នានោះ ស្រាក់ បានប្រាប់ខ្ញុំថាឲ្យប្រាប់ប្រពន្ធរបស់គាត់ឲ្យរង់ចាំគាត់ពីរបីនាទី ព្រោះគាត់កំពុងបញ្ចប់ការងារ ។ សម្រាប់ការបកប្រែវិញ ខ្ញុំប្រាប់ ចេក ថា ស្រាក់ នឿយហត់ និងចង់ឱបថើបគាត់ ។ ចេកខ្មាសអៀនយ៉ាងខ្លាំងហើយយកដៃទាំងពីរគ្របមុខ ញញឹមដោយការខ្មាសអៀន ។ នៅពេលដែលបុគ្គលិកខ្មែរដទៃដែលអាចនិយាយ និងយល់ភាសាបារាំងផ្ទុះសំណើចនោះ ទើប ស្រាក់ និង ចេក ដឹងថាខ្ញុំនិយាយលេង ។ ក្រោយមក ខ្ញុំឈប់និយាយលេងសើចរបិលរប៉ូចពីអ្នកទាំងពីរនៅពេលដែលអ្នកទាំងពីរអាចសន្ទនាជាភាសាខ្មែរជាមួយគ្នាបានខ្លះ ។

ប្រហែលឆ្នាំ១៩៨៣ ខ្ញុំបានចាកចេញពីមន្ទីរពេទ្យខេត្តតាកែវ ហើយបានទៅធ្វើការនៅក្រសួងមហាផ្ទៃនៅភ្នំពេញ ។ ខ្ញុំធ្វើការនៅទីនោះរហូតដល់ឆ្នាំ២០០០ទើបខ្ញុំចូលនិវត្តន៍ ។ បន្ទាប់ពីចូលនិវត្តន៍ ខ្ញុំបានត្រឡប់ទៅរស់នៅលើដីគ្រួសាររបស់ខ្ញុំនៅភូមិតាភេមវិញ ។ បច្ចុប្បន្ន ខ្ញុំចំណាយពេលជាច្រើននៅវត្តក្បែរនោះដើម្បីរៀនធម៌ ហើយម្តងម្កាលកំដរអ្នកសិក្សាស្រាវជ្រាវទៅទស្សនាអតីតគុកខ្មែរក្រហមនៅក្រាំងតាចាន់ ជាកន្លែងដែលខ្ញុំធ្លាប់ជាប់ និងរួចរស់រានមានជីវិត ក្នុងចំណោមអ្នករស់រានមានជីវិតពីរនាក់ ។

**សុខ យ៉ាង**

# ដំណឹងស្វែងរកឪពុកម្តាយ និងបងប្អូន

ខ្ញុំបាទឈ្មោះ ស៊ាង សូឆាត ភេទប្រុស អាយុ៤២ឆ្នាំ រស់នៅភូមិកំប៉ាង ឃុំកន្ទឺ២ ស្រុកបាណន ខេត្តបាត់ដំបង សូមប្រកាសរក ១) ឪពុកឈ្មោះ ស៊ាង ឈឿត ទាហានពាក់ស័ក្តិ៤ (ខាង លន់ នល់) , ២) ម្តាយឈ្មោះ សាន ណន, ៣) បងស្រីឈ្មោះ ស៊ាង មីឡា និង ៤) បងប្រុសឈ្មោះ ស៊ាង ប៊ីណូ ។

នៅក្នុងរបប លន់ នល់ ឪពុកខ្ញុំបានប្រចាំការនៅបន្ទាយទាហានជិតវត្តសំពៅ សង្កាត់ស្វាយប៉ោ ស្រុកសង្កែ ខេត្តបាត់ដំបង ។ រហូតដល់ឆ្នាំ១៩៧៣ ឪពុកខ្ញុំត្រូវបានផ្លាស់ប្តូរឲ្យទៅប្រចាំការនៅបន្ទាយទាហាន ដែលមានទីតាំងស្ថិតនៅក្បែរវត្ត ក្នុងក្រុងកំពង់ធំ ដោយពេលនោះ ឪពុកខ្ញុំបានយកម្តាយខ្ញុំ និងបងពីរនាក់ទៅនៅជាមួយ ។ ចំណែកខ្ញុំ និងប្អូនស្រីពៅម្នាក់ឈ្មោះ ស៊ាង ពិសី (សព្វថ្ងៃរស់នៅប្រទេសបារាំង) គាត់បានយកទៅឲ្យយាយចិញ្ចឹមបីបាច់ថែរក្សា ហើយចាប់តាំងពេលនោះខ្ញុំបែកគាត់រហូត ។

នាពេលថ្មីៗនេះ ខ្ញុំបានទៅសាកសួរដំណឹងឪពុកខ្ញុំនៅអតីតបន្ទាយទាហាន លន់ នល់ នៅខេត្តកំពង់ធំ ហើយចាស់ៗដែលរស់នៅក្បែរវត្តប្រាប់ថា ឪពុកខ្ញុំត្រូវខ្មែរក្រហមបញ្ជូនចេញពីបន្ទាយទាហានក្រោយគេ ។

ប្រសិនបើបងប្អូនណាបានស្គាល់ ឬឮឈ្មោះដូចបានរៀបរាប់ខាងនេះ សូមមេត្តាទាក់ទងមកខ្ញុំបាទ តាមរយៈទូរស័ព្ទ ៖ ០៧៧ ៩៩២ ៨៦៦ ឬតាមរយៈអាសយដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦, ផ្លូវព្រះសីហនុ, សង្កាត់ទន្លេបាសាក់, ខណ្ឌចំការមន, ក្រុងភ្នំពេញ ឬទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ **សូមអរគុណ!**

# ដំណឹងស្វែងរកបង ឪពុកមា និងម្តាយមីង

ខ្ញុំបាទឈ្មោះ សួរ វីណារិន ជាមន្ត្រីរាជការនៅក្រសួងបរិស្ថាន ទីលំនៅបច្ចុប្បន្នផ្ទះលេខ ១៧៨ (មុំវត្តពោធិ៍ចិនតុង) ផ្លូវ២០០១ កែងមហាវិថីសហព័ន្ធរុស្ស៊ី ភូមិប៉ប្រកខាងត្បូង សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។

ខ្ញុំបាទសូមប្រកាសរកបងប្រុសឈ្មោះ សួរ វីឡា កើតឆ្នាំ១៩៦៥ (ឆ្នាំថោះ) មានឪពុកឈ្មោះ សួរ គីមចេក ស្លាប់ខែមករា ឆ្នាំ២០១២ និងម្តាយឈ្មោះ បេ គីម ជីង នៅរស់ ។ ឪពុកម្តាយខ្ញុំបាទមានកូនចំនួន៣នាក់ គឺ ៖

១) សួរ វីឡា ភេទប្រុស (បាត់ដំណឹង)

២) សួរ វីណារ៉ា ភេទប្រុស

៣) សួរ វីណារិន ភេទប្រុស

ចំណែកមា-មីងមានឈ្មោះ ៖ ទី១) បេ គីមយ៉ុង (ស្រី) ,ទី២) បេ គីម ស៊ិន (ស្រី) ,ទី៣) បេ គីមហួរ (ស្រី) ទី៤) បេ គីមលេច, ទី៥) បេ គីមរ័ត្ន (ប្រុស) និង ទី៦) បេ គីមមុំ (ស្រី) ដែលបានបែកគ្នាក្នុងខែមេសា ឆ្នាំ១៩៧៥ ពេលរបប ប៉ុល ពត ជម្លៀសចេញពីទីក្រុងភ្នំពេញ ។

ប្រសិនបើ បង និងមីង-មា ឬញាតិមិត្តណាបានឮដំណឹងនេះ សូមទាក់ទងមកប្អូន ឬក្មួយឈ្មោះ សួរ វីណារិន តាមរយៈ ទូរស័ព្ទលេខ ០៩៧ ៨ ៨១១ ១០៧ និង ០៧៧ ៨៨៧ ០៦៧ ឬតាមរយៈអាសយដ្ឋានមជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦, ផ្លូវព្រះសីហនុ, សង្កាត់ទន្លេបាសាក់, ខណ្ឌចំការមន, ក្រុងភ្នំពេញ ឬទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ **សូមអរគុណ!**

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម

មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៩៥៥ ៨៥៨ ឬ អ៊ីម៉ែល ៖ truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

***សូមផ្តល់ព័ត៌មានដូចខាងក្រោមៈ***

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ៈ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ៈ លេខទូរស័ព្ទ អាស័យដ្ឋាន) ។

***ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោមៈ***

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។










ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយ ដោយរដ្ឋាភិបាល សហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 160, April 2013 ◆ Funded by USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.